ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពិរ

### សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៣៤**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2017, 14:38
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ស្រ៊ា រតនៈ

លោក ចូសេហ្វ អេនឌ្រូ ប៊យលី

*(Mr. Joseph Andrew BOYLE)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក សួន វិសាល | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជូ គឹមឡុន | ខ្មែរ |
| ព្រះតេជគុណ អែម អឿង | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ជុំ គឹមឡូន** (2-TCCP-238)

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី....................ទំព័រ ៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៨

សួរដោយលោក សួន វិសាល ផ្តើមពី ....................ទំព័រ ១៣

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................ទំព័រ ២២

សួរដោយកញ្ញា អង់តា ហ៊្គីសសេ ផ្តើមពី ....................ទំព័រ ៣៨

សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៥០

**ការសួរសំណួរទៅដើមបណ្តឹងសាក្សី៖ ព្រះតេជគុណ អែម តឿង** (2-TCW-954)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:៥៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្ដាប់ សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បញ្ចប់ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-954។

ជាបន្តទៅនេះលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជាមានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីលោកស្រី ជូ គឹមឡូន មានវត្តមាននៅក្នុងបន្ទប់សវនាការនេះហើយ។ រីឯសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់មានរហស្សនាម 2-TCW-954 សាក្សីបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ សាក្សីនឹងមានវត្តមាននៅបន្ទប់រង់ចាំនៅម៉ោងដប់ព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៧:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

បាទ ឥឡូវនេះយើងសម្រេចលើបញ្ហាសំណើសុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបាន

ទទួលលិខិតស្នើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក នួន ជា ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ដែលបញ្ជាក់ថាដោយមានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះមិនអាចនិយាយយូរបាន និងមិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥។ ដោយមេធាវីរបស់គាត់បានជម្រាបគាត់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះរួចហើយថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញឬ ដាក់ជូនតុលាការគ្រប់ពេលវេលានៃសវនាការចំពោះរឿងក្ដីរបស់ខ្លួននោះឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក នេះ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មិនមានការប្រែប្រួលទេ ប៉ុន្តែគាត់មិនអាចអង្គុយបានយូរ និងបានផ្ដល់អនុសាសន៍ថាសូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត .ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៩:៤៥]

ជាបន្តទៅនេះអង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប៉ុន្តែមុននឹងផ្ដល់ជូនអង្គជំនុំជម្រះសូមផ្ដល់ -- អ៎! សូមសួរទៅចៅក្រម តើអស់លោក លោកស្រីមានសំណួរអ្វីចង់សួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូប

នេះដែរឬទេ?

បាទ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ខ្ញុំមានសំណួរពីរបី <បន្ថែម>ទាក់ទងទៅនឹងបញ្ហា<>ប្រឈមមុខ <ដែលលោកស្រីបានលើកឡើង>កាលពីម្សិលមិញជាមួយ ខៀវ សំផន, នួន ជា, ប៉ុល ពត, តាម៉ុក នៅទីកន្លែងដែលលោកស្រីជីកប្រឡាយ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** មុននឹងខ្ញុំចាប់ផ្ដើមសួរលោកស្រី ខ្ញុំសុំសង្កត់ទៅលើបញ្ហាមួយ។ ខ្ញុំនឹងសួរសំណួរមួយចំនួនប្រហែលជាពិបាកនឹងឆ្លើយបន្តិច<ក្រោយ>ពី<>រយៈពេល<>៤០ឆ្នាំ<>។ ដូច្នេះ បើលោកស្រី<មិន>ចងចាំចំណុចណាមួយ <សូមប្រាប់ខ្ញុំ>។ សូមមេត្តាកុំព្យាយាមស្មានៗ។ ទាក់ទងទៅនឹងកិច្ចប្រជុំដែលលោកស្រីនិយាយពីម្សិលមិញថា លោកស្រី បានជួប ប៉ុល ពត, ខៀវ សំផន, នួន ជា, តាម៉ុក នៅពេលដែលលោក<ស្រី>កំពុងជីក<ដី>។ តើនេះជាឱកាសតែម្ដងទេ<នៅថ្ងៃនោះ>ដែល<>លោកស្រីបានជួបមេដឹកនាំទាំងនោះ ឬក៏លោកស្រីបានជួបច្រើនដងដែរ?

[០៩:១១:៣១]

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** ខ្ញុំបានជួបគាត់ ចាសខ្ញុំបានជួបគាត់តែម្ដងទេពេលដែលខ្ញុំកំពុងជីកប្រឡាយ រែកប្រឡាយ គាត់ចុះការដ្ឋាន បានតែម្ដងទេចាស។

**ស៖** ប្រសិនបើអាចសុំលោកស្រីជម្រាបជូនអង្គជំនុំជម្រះថាលោកស្រីបានឃើញមេដឹកនាំហ្នឹងរយៈពេលប៉ុន្មានដែរ<នៅពេលនោះ>? មួយនាទី <កន្លះ>ម៉ោង កន្លះថ្ងៃ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស បានឃើញគាត់ប្រហែលជា១៥នាទីដែរ គាត់ដើរចុះតាំងពីឡានមក មើលគាត់រហូតចាស។ ១៥នាទីដែរចាស។

**ស៖** លោកស្រីចាំទេ <តើ>លោកស្រី<នៅ>ចម្ងាយប្រហែលជាប៉ុន្មានម៉ែត្រ<>ពី<ពួកគេ><ពេលដែលលោកស្រីបានឃើញគេដើរចេញពីរថយន្ត>?

**ឆ៖** ជិតគ្នា ចាស តែប្រវែងហ្នឹងទៅកន្លែងតុមុខហ្នឹងចាស ប្រវែងហ្នឹង វានៅថ្នល់ហ្នឹងអ៊ីចឹង

គាត់ចុះ ដើរនៅក្រោមថ្នល់ ហើយយើងនៅប្រឡាយជិតគ្នាៗជាទីបំផុតចាស។

**ស៖** ដើម្បីប្រតិចារឹក យើងមានអ្នកដែលអញ្ជើញមកបញ្ជារដ្ឋបាល គាត់អាចនឹងវាស់ចម្ងាយនេះបានតាមលោកស្រីឆ្លើយអម្បាញ់មិញ ដើម្បីទុក<ក្នុងសំណុំរឿង ដែលនឹងធ្វើឲ្យ>ឯកសារយោង<កាន់តែងាយស្រួលថែមទៀត>។ គឺចន្លោះពីប្រហែលជាដើមបណ្តឹងរដ្ឋប្បវេណីកំពុងអង្គុយមកអាសនៈចៅក្រម អ៊ីចឹង ចម្ងាយប្រហែល<៩ម៉ែត្រ>ប៉ុណ្ណឹង។ លោកស្រីអាចស្តាប់ឮមេដឹកនាំហ្នឹងនិយាយថាម៉េចដែរឬទេ បើអាចស្តាប់ឮ?

**ឆ៖** ចាស ស្តាប់ឮទាំងអស់។ គាត់ថា៖ “ខំសម្រុកជីកប្រឡាយឲ្យបានជ្រៅ រហ័សបំផុតដើម្បីបង្ហូរទឹកពីបឹងអូរចំបក់តាមស្ពានីយហ្នឹងទៅខាងស្រែ -- វាលស្រែខាងលិចថ្នល់រទេះភ្លើងទៅដល់វាលសំរោងទៅដល់លាយបូរ ធ្វើស្រែបាន១ហិកតា ៣តោន ទៅ៦តោន”។ គាត់និយាយឮ ហើយនិងតាម៉ុកថាឲ្យ “ទឹកត្នោត គេកំពុងរែកទឹកត្នោតមកចែក”។ ចាស ឈរហូបទឹកត្នោតបានមើលគាត់បណ្តើរថាឲ្យ “ដាក់ទឹកត្នោតហ្នឹងឲ្យផ្អែមឲ្យគាត់ ហូបកុំឲ្យឈឺពោះ”។ ចាសប៉ុណ្ណឹង។

[០៩:១៤:២៥]

**ស៖** <> តើមេដឹកនាំទាំងហ្នឹងគេនិយាយគ្នានៅក្នុងចំណោមពួកគាត់ទាំងហ្នឹង ឬក៏ពួកមេដឹកនាំទាំងហ្នឹងនិយាយមកកាន់លោកស្រី?

**ឆ៖** គេនិយាយគ្នាគេ តែ តាម៉ុក និយាយមកកាន់ប្រជាពលករដែលកំពុងធ្វើការ ហើយនិងមេកង អ្នករែកទឹកត្នោត។ ចាស ហើយគាត់និយាយគ្នាគាត់ដើរទៅរហូត មេដឹកនាំនិយាយគ្នាគាត់ដើរទៅរហូត ចាស ឈរមួយសន្ទុះ។

**ស៖** តើលោកស្រី ហើយនិងអ្នកធ្វើការដទៃទៀតនោះ <ត្រូវបានគេប្រមូលផ្តុំ>នៅទីហ្នឹង ឬក៏<>បានជួបដោយចៃដន្យអីទេ?

**ឆ៖** ប្រជាពលករទាំងអស់ មកធ្វើការជីកប្រឡាយ រែកប្រឡាយហ្នឹងទាំងអស់គ្នា មានគ្នាច្រើនផុតមួយប្រឡាយហ្នឹងតែម្តង មិនដឹងជាប៉ុន្មានទេ។ ចាស ច្រើន។

**ស៖** ដើម្បីឲ្យវាច្បាស់ អ៊ីចឹងមានន័យថា <គេកំពុងតែធ្វើការ> គេមិនបានប្រមូលអ្នកទាំងនោះឲ្យមកប្រជុំដើម្បីស្តាប់មេដឹកនាំហ្នឹងនិយាយថាម៉េចៗទេ ឬក៏យ៉ាងណា?

**ឆ៖** ចាស អត់ទេ យើងមកធ្វើការ។ តែកងខ្ញុំ នៅមុខ និងកងយុវជននៅមុខ។ តែក្រោយកងកសិករដែលកូនតូចៗ ហើយប្តីប្រពន្ធអីគេនៅក្រោយ តែខ្ញុំចល័ត នារី ស្ត្រីមេម៉ាយនៅមុខ និងយុវជន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានតែខ្ញុំទេ ដែលបានឃើញគាត់មុនគេ ហើយនិងកងយុវជនមុខ ចាស។

[០៩:១៦:៣៣]

**ស៖** ខ្ញុំមានសំណួរពីរបីទៀត ថាតើលោកស្រីអាចចងចាំមេដឹកនាំណាបានខ្លះ ជាពិសេស ខៀវ សំផន និង នួនជា។ ឥឡូវខ្ញុំសូមចាប់ផ្ដើមសួរពាក់ព័ន្ធទៅលោក ខៀវ សំផន។ ពីម្សិលមិញ លោកស្រីនិយាយ<>ពីរចំណុចដែលខ្ញុំបានកត់ត្រា។ ទី១៖ លោកស្រីបាននិយាយថា ខៀវ សំផន <ត្រូវ>បាន<គេ>ចង្អុល<ប្រាប់>លោកស្រី <ហើយ>មេកងរបស់លោកស្រី<បាននិយាយថា "នេះគឺលោក ខៀវ សំផន"> ហើយក្រោយមកទៀតលោកស្រីនិយាយថា លោកស្រីក៏បានឃើញរូបថត ខៀវ សំផន ប៉ុន្មានឆ្នាំមុននោះ។ សំណួររបស់ខ្ញុំ គឺទាក់ទងទៅនឹងរូបថតរបស់ ខៀវ សំផន។ តើ<>លោកស្រីបានឃើញរូបថតគាត់ហ្នឹងរយៈពេលប៉ុន្មានឆ្នាំដែរ មុននឹងបានៗជួបដោយផ្ទាល់ បានឃើញដោយផ្ទាល់នោះ? <តើលោកស្រីចាំទេ?>

**ឆ៖** ខ្ញុំឃើញរូបថតគាត់តាំងពីសង្គមរាស្ត្រនិយម ដែលគាត់ធ្វើនៅជាតំណាងរាស្ត្ររដ្ឋសភា។

**ស៖** ខ្ញុំមិនចង់<>ប្រាប់តម្រុយអីទេ គ្រាន់តែសួរថា តើ<>រយៈពេលប៉ុន្មានឆ្នាំ គិតពីពេលឃើញរូបថត<គាត់>មកដល់ពេលលោកស្រីជួបគាត់ដោយផ្ទាល់នោះ? <បើលោកស្រីចាំ សូមប្រាប់ខ្ញុំ ប៉ុន្តែបើមិនចាំ សូមប្រាប់ខ្ញុំថា លោកស្រីមិនចាំទេ។>

**ឆ៖** យូរឆ្នាំដែរ មិនអាចចាំបាន ដឹងថាសង្គមសម្ដេច។ ចាស យូរឆ្នាំដែរ តែមុខគាត់អត់មានប្លែកទេ កាលគាត់ចូលមកឆ្នាំ៩២ គាត់ចូលមក គេកោះហៅមកម្ដង មុខអត់មានប្លែកកាលពីចុះទៅការដ្ឋានទេ ចាស។

**ស៖** តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានឬទេ នៅពេលណាដែលប្រធានកង<>លោកស្រីប្រាប់លោកស្រីថា "នេះគឺជា ខៀវ សំផន"<? តើគាត់ប្រាប់>មុនពេលជួបជុំគ្នាហ្នឹង ឬក្នុងពេល<លោកស្រីឃើញគាត់>ហ្នឹង ឬក៏ក្រោយពេលជួបជុំគ្នាហើយ?

**ឆ៖** ពេលដែលគាត់ធ្វើដំណើរតាមប្រឡាយដែលខ្ញុំលើកក្បែរថ្នល់ហ្នឹង គាត់ធ្វើដំណើរតាមក្បែរថ្នល់ហ្នឹងប្រធានកងខ្ញុំគាត់ប្រាប់ថា៖ "នោះ លោក ខៀវ សំផន និងលោក ប៉ុល ពត ចុះមកមើលពលករ"ចាស។ ហើយក៏ប្រធានកងខ្ញុំ និងគណៈឃុំៗ គណៈមេកងអីដើរទៅជាមួយគាត់ទាំងអស់ទៅលិចចាស។

[០៩:២០:០១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅលោក ខៀវ សំផន គឺខ្ញុំ<ព្យា>យាមសួរឲ្យងាយៗយល់។ តើលោកស្រីចំណាំគាត់បានដោយសារតែបានឃើញរូបថត<គាត់ដោយខ្លួនឯង មិនមែន>ដោយសារតែប្រធានកងប្រាប់<លោកស្រីទេ>? ឬក៏<លោកស្រីចាំថា លោកស្រីបានឃើញរូបថតគាត់ក្រោយពេលប្រធានកងប្រាប់ថា>ថានេះគឺ ខៀវ សំផន<ក្នុងចំណោមមនុស្សផ្សេងៗទៀតនោះ>?

**ឆ៖** ការយល់ឃើញ និង ការស្គាល់ និងការប្រាប់ សមស្របគ្នាតែមួយ ព្រោះគាត់មេដឹកនាំសង្គម ប៉ុល ពត ខ្មែរក្រហមហ្នឹង គឺគាត់មានឡានជិះ។ ចាស អាចសមស្របនឹងពេលដែលយើងយល់ដឹង និងយល់ឃើញទាំងអស់ ចាស។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរសំណួរពាក់ព័ន្ធទៅនឹងលោក នួន ជា។ លោកស្រីបាននិយាយថា <> នួន ជា <ត្រូវ>បានចង្អុល<ប្រាប់>មកលោក<ស្រី ដោយប្រធានកង>។ តើលោកស្រីធ្លាប់បានឃើញ<គាត់ ឬ>រូបថតគាត់មុនពេលឃើញគាត់ដោយផ្ទាល់ហ្នឹង<ទេ>?

[០៩:២១:៤៣]

**ឆ៖** គាត់ចង្អុលនៅក្នុងប្រឡាយ។ គាត់ថា៖ "ប្រឡាយហ្នឹងជីកឲ្យបានលឿនបំផុត"។ គាត់ចង្អុលជាទូទៅអ្នះ! ជីកប្រឡាយហ្នឹងឲ្យបានលឿនជាទីបំផុត ដើម្បីបូមទឹកពីស្ពានីយមកចុះតាមស្រែតាមប្រព័ន្ធប្រឡាយទៅស្រែ ទៅខាងលិចៗទៀត ដើម្បីធ្វើស្រែហ្នឹងឲ្យបាន១ហិកតា ៣តោន ទៅ៦តោន គាត់ចង្អុលជាចល័ត មិនមែនចង្អុលចំបុគ្គលណាទេ។ ចង្អុលប្រាប់ឲ្យលើកឲ្យរហ័សចាស។

**ស៖** ខ្ញុំគិតថា ប្រហែលជាមានបញ្ហាដោយសារការបកប្រែ ខ្ញុំព្យាយាមសួរម្តងទៀត។ ខ្ញុំចង់ដឹង <> ថាតើលោកស្រីធ្លាប់បានឃើញលោក នួន ជា ឬក៏រូប<>ថតរបស់លោក នួន ជា មុនពេលឃើញនៅការដ្ឋានការងារហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** លោក នួន ជា ខ្ញុំអត់បានស្គាល់ទេ អត់ឃើញទេ តែមេកងនិងប្រធានភូមិខ្ញុំ ប្រធានកងខ្ញុំប្រាប់។ ប្រាប់នៅពេលដែលគាត់ចុះទៅជាមួយលោក ខៀវ សំផន ចាស។

**ស៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត។ លោក<ស្រី>និយាយអំពី<>ប្រធានភូមិ<បន្ថែមម្នាក់ទៀត>? តើបុគ្គលទាំងពីរនេះខុសគ្នា ឬក៏យ៉ាងណាដែលប្រាប់ថា នេះគឺជា នួន ជា។ តើជាប្រធានកង ឬក៏ប្រធានភូមិ ឬក៏ដោយបញ្ហាបកប្រែទៀត?

**ឆ៖** ប្រធានកងនិងប្រធានភូមិហ្នឹង ដូចគ្នា។ ប្រធានកង ប្រធានភូមិហ្នឹង វាមានបីនាក់ក្នុងមួយភូមិ អ្នកត្រួតពិនិត្យហ្នឹងមានបីនាក់ ដែលថាប្រធានធំអ៊ីចឹង គេនាំកងទៅមុខ។ ប្រធានភូមិអ្នកអោបក្តាប់

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

ប្រជាជនទាំងអស់ ហើយតែដល់ពេលចុះការដ្ឋានសម្រុកហ្នឹង គេមកទាំងពីរនាក់ទាំងប្រធានកង ទាំងប្រធានភូមិចាស។

[០៩:២៤:០០]

**ស៖** តើទាំងពីរនាក់ហ្នឹងឬដែលចង្អុលថា “នេះគឺជា នួន ជា?” <និយាយ>ទាំងពីរនាក់<ហ្នឹង> ឬ<>? <>

**ឆ៖** ប្រធានកងចាស។ ប្រធានកង -- ពេលគេទៅបាត់ៗ។ ដល់ពេល<បាយ>ថ្ងៃឡើង គេប្រមូលយើងប្រជុំ។ ប្រជុំប្រាប់ថា “អង្គការថ្នាក់លើលោកចុះមកពង្រឹងគោលជំហរឲ្យយើងប្រឹង ជីកប្រឡាយហ្នឹងឲ្យហើយឆាប់ បានដកទៅធ្វើការងារមួយកន្លែងទៀត”។ ពេលថ្ងៃគេត្រូវប្រមូលប្រជាជនអ្នកកម្មករជីកប្រឡាយហ្នឹង ប្រជុំគ្នានៅមួយក្រុមៗចាស។ មួយក្រុមខ្ញុំហ្នឹងមានគ្នា៣០នាក់ជាងអ៊ីចឹងទៅ។ ក្រុមគេនោះ មាន៣០-៤០នាក់ វាមានច្រើនក្រុម មួយកងៗចាស។ ហើយគេប្រាប់អ៊ីចឹង យើងដឹងថាមានលោកទាំងបីហ្នឹង ហើយឃើញទាំងបីហ្នឹងមែន ចាស។

**ស៖** អ្នកណាប្រាប់អ្នកនៅពេលជួបជុំគ្នាហ្នឹង ប្រធានភូមិ ឬក៏ប្រធានកង? ខ្ញុំសូមសួរម្តងទៀត។

**ឆ៖** ចាស ប្រធានកងឈ្មោះ អឿន។ ចាស ឈ្មោះអឿន ហើយនិងប្រធានភូមិឈ្មោះ ជឹម។

**ស៖** តើអ្នកទាំងពីរហ្នឹងនៅកន្លែងដែលជួបជុំគ្នាហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** គាត់នៅកន្លែងជួបជុំគ្នាហ្នឹង គាត់នៅដើរត្រួតពិនិត្យកងយុវជន កងលើកប្រឡាយទាំងអស់ហ្នឹងគាត់នៅដើរមើល។ ប្រធានកងដើរត្រួតពិនិត្យ បើប្រធានភូមិគេនៅចុះចលនាជាមួយយើង ចាស។

**ស៖** <តើពេលនោះឬដែលប្រធានភូមិនិយាយពីឈ្មោះអ្នកទាំងពីរនេះ?> តើ<នេះជាឱកាសដែលប្រធានភូមិនិយាយពី>ឈ្មោះ ខៀវ សំផន, នួន ជា ជាដើម ។ល។ហ្នឹង <>?

[០៩:២៦:៣៥]

**ឆ៖** ពេលដែលយើងជួបគាត់ហ្នឹង គេប្រាប់លើកទី១ គេនិយាយប្រាប់ជារឿយៗពីមុនមក។ គេថាលោកបីនាក់ហ្នឹងជាមេដឹកនាំ ប៉ុន្តែដល់ថ្ងៃយើងជួបបានគេប្រាប់ម្តងទៀត។ គេប្រាប់បានពីរដង។

**ស៖** តើ<គេមាន>និយាយ<>ឈ្មោះ<អ្នកទាំងនោះទេ ឬក៏គ្រាន់តែនិយាយថា អ្នកទាំងនោះជាមេដឹកនាំ>?

**ឆ៖** ចាសគេប្រាប់ទាំងឈ្មោះថា ស្មើនឹងប្រមុខរដ្ឋកម្ពុជាប្រជា -- ស្មើនឹងប្រមុខរដ្ឋយើងសង្គមសម្តេច។ គេនិយាយប្រាប់អ៊ីចឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកស្រី។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

[០៩:២៧:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមអរគុណលោកប្រធាន ជម្រាបសួរលោកស្រី។ ខ្ញុំមានសំណួរបន្តិចបន្តួចទេដើម្បីសួរបន្ត។ ជាដំបូងពាក់ព័ន្ធទៅនឹងការដ្ឋានដែលមេដឹកនាំមកទស្សនកិច្ច។ តើលោកស្រីអាចបញ្ជាក់បានទេថា តើការដ្ឋានហ្នឹងនៅឆ្ងាយពីសហករណ៍លាយបូរ<ទេ? តើវាស្ថិតនៅកន្លែងណាពិតប្រាកដ?> <តើវា> ស្ថិតនៅជិត<សហករណ៍> ឬក៏<នៅ>ប៉ុន្មានគីឡូ<ពី>សហករណ៍?

**លោកស្រី ជូ គឹមឡន៖**

**ឆ៖** ចាស ចម្ងាយប្រហែលជា ៤គីឡូម៉ែត្រ។

**ស៖** លោកស្រីរស់នៅក្នុងភូមិមួយដែលស្ថិតនៅក្រោមសហករណ៍លាយបូរ ឬក៏លោកស្រីរស់នៅក្នុងសហករណ៍តែម្តង? កាលពីម្សិលមិញលោកស្រីនិយាយអំពីសហករណ៍លាយបូរ ជាសហករណ៍គំរូ<ហើយខ្ញុំក៏ឮលោកស្រីលើកឡើងផងដែរអំពីទីកន្លែងមួយហៅថា ក->១ ខ្ញុំស្តាប់មិនសូវច្បាស់ទេពេលហ្នឹង លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំនិយាយថាកងទី១ហ្នឹង ជាសហករណ៍គំរូរបស់អ្នក១៨ អ្នកចាស់ ប៉ុន្តែសហករណ៍ខ្ញុំអ្នកថ្មី នៅខាងត្បូងសាលាឃុំប្រហែលជាមួយគីឡូ។ សហករណ៍ខ្ញុំពួក១៧ មេសា នៅខាងត្បូង ខ្ញុំនៅខ្ទមៗតូចៗ។ សហករណ៍គេៗធ្វើជារោងធំ កន្លែងបាយរួម។

**ស៖** ដូច្នេះលោកស្រីផ្ទាល់នោះ គឺលោកស្រីរស់នៅ <ក-១>ហ្នឹង ឬក៏រស់នៅផ្សេងពី<>ហ្នឹង?

[០៩:២៩:៥៨]

**ឆ៖** ខ្ញុំរស់នៅកង៣។ សហករណ៍ពួក១៧ ចាស។

**ស៖** លោកស្រីអាចរៀបរាប់បានទេថា លក្ខខណ្ឌរស់នៅហ្នឹងយ៉ាងម៉េចដែរ? លោកស្រីរស់នៅក្នុងខ្ទម ឬក៏គេមានជាផ្ទះ<ប្រក់ក្បឿង ប្រក់ស័ង្កសី ឬក៏រស់នៅតាមសំយ៉ាបផ្ទះ>? ខ្ញុំចង់ដឹងថាតើមនុស្ស<រាល់>គ្នាហ្នឹង មានផ្ទះដូចៗគ្នា<ដែរ>ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អត់ -- ចាស អត់ដូចៗគ្នាទេ។ យើងជាអ្នកថ្មីហ្នឹង គឺតយ៉ាកជារោង។ ខ្ញុំនឹងនៅតយ៉ាកពីរោងផ្ទះគេមក។ គេៗអ្នកចាស់មូលដ្ឋាន ផ្ទះគេរាងវែងបន្តិច ប៉ុន្តែស្លឹកដូចគ្នា ប៉ុន្តែរាងធំបន្តិច វែង ហើយផ្ទះយើងអ្នកថ្មី គេតឲ្យតូចៗ។ អ្នកថ្មីទាំងអស់ គឺគេសង់ៗជារោងតូចៗ អាចសម្រាន្តអស់ជិតគ្នាៗអ៊ីចឹងទៅ មួយកន្លែងបីនាក់ មួយកន្លែងពីរនាក់ បីនាក់អ៊ីចឹងបាន។ អត់មាន -- ហូបអាហារក៏ខុសគ្នា ដូចនិយាយជម្រាបពីម្សិលមិញ ចាស។

[០៩:៣១:៣៤]

**ស៖** តើលោកស្រីអាចរៀបរាប់អំពីផ្ទះសម្រាប់ដែលអ្នកនៅ<ក-១>ហ្នឹង ហើយអ្នក<ទាំងនោះ>ជាអ្នក<ណា>? តើ<លំនៅទាំងនោះ>ជាខ្ទម ឬក៏ជាផ្ទះ?

**ឆ៖** ចាស ជាផ្ទះគំរូ ផ្ទះក្បឿង។ គណៈឃុំ និងឈ្លបនៅទីនោះ។ គណៈឃុំទាំងអស់ គឺនៅផ្ទះគំរូ កង១ ទាំងអស់ គឺជាផ្ទះក្បឿង។ ឯយើងពលករនៅដោយឡែក។

**ស៖** ហើយចុះផ្ទះគំរូហ្នឹង ជាផ្ទះដែលយើងមើលទៅ គឺថាខុសពីផ្ទះផ្សេងដាច់តែម្តង ឬយ៉ាងម៉េច? <តើជាផ្ទះមានស្តង់ដារទេ?> លោកស្រីមើលឃើញថា ផ្ទះរបស់លោកស្រី ហើយនិងផ្ទះមេភូមិមេអីហ្នឹង ខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** ផ្ទះគំរូជាផ្ទះក្បឿង ជញ្ជាំងក្តារ មានវ៉ែនីរជិតៗ ដូចផ្ទះយើងពីដើម ហើយគេនៅតែគណៈឃុំ គណៈស្រុក គណៈឃុំទេ។ ហើយដល់ពេលយើងប្រជាជននៅផ្ទះស្លឹក ចងជញ្ជាំងជាធាងដូង ប្រក់ជាស្លឹកត្នោត ជញ្ជាំងជាស្លឹកត្នោត។ យើង -- តែខ្ញុំបានដើរតាមផ្លូវហ្នឹង ជាញឹកញាប់ ខ្ញុំទៅពេទ្យ យកកូនទៅពេទ្យៗពីខាងជើងសាលាឃុំ។ ចាស ខ្ញុំដើរតាមហ្នឹងញឹកញាប់។

**ស៖** តើអ្នកដែលនៅផ្ទះគំរូនោះ មានសួនច្បារមួយ ដែលគេអាចដាំបន្លែដាំអី ឬក៏ចិញ្ចឹមសត្វអីបានទេ លោកស្រី?

**ឆ៖** គេអត់ -- ចាស គេអត់មានចិញ្ចឹមសត្វទេ។ នៅកន្លែងផ្ទះគំរូហ្នឹងគេអត់មានចិញ្ចឹមសត្វទេ។ គេប្រធានកង ប្រធានធំៗ គេទៅតាមចល័ត តាមកងមុខអស់ហើយ។ គណៈឃុំនារី មិត្តណៅ មិត្តស៊ឹម ទៅដើរតាមកងចល័តនារី កងចល័តទៅខាងមុខ គឺអត់មានអ្នកណាអ្នកចិញ្ចឹមទេ គឺពេលបាយ គេហូបបាយរួម ជារោងបាយគេនៅកន្លែងហ្នឹង ខុសពីបាយយើងនៅកងអ្នក១៧។ គេជាសហករណ៍គំរូ។

[០៩:៣៤:២៨]

**ស៖** តើលោកស្រីដឹងថា តាម៉ុក រស់នៅកន្លែងណាទេ? តើរស់នៅក-១ ឬក៏នៅក្បែរ ក-១ ឬនៅ

កន្លែងផ្សេងទៀត?

**ឆ៖** តាម៉ុក គាត់រស់នៅផ្ទះគាត់ នៅតាកែវ នៅផ្លូវទៅវត្តបារាយណ៍ នៅក្បែរៗបឹង នៅពីខាងលិចផ្លូវ។ ផ្ទះគាត់មានទំហំធំ ស្អាត។ ផ្ទះគាត់មានសួនច្បារទៀត។

**ស៖** តើមានសាលារៀនទេនៅក្នុងសហករណ៍ហ្នឹង? ហើយអ្នកណាដែលអាចទៅរៀននៅសាលានោះបាន<>?

**ឆ៖** សាលារៀន គ្រូបង្រៀនមាន តែអត់មានសាលាទេ គេប្រក់ជាស្លឹកត្នោតនៅក្រោមដើមឈើ។ ប្រក់ជាស្លឹកត្នោតហើយ កូនយើងដែលនៅតូចៗ គេអាចឲ្យទៅរៀន ប៉ុន្តែរៀនច្រៀងប្ដេជ្ញា ក្ដាប់ដៃ ក្ដាប់ជើង ច្រៀងប្ដេជ្ញាគឺប្ដេជ្ញាខាង ពួកខាងគេខ្មែរក្រហម។ បង្កបង្កើនផល ប្ដេជ្ញាខាង -- គេបង្កបង្កើនផលខ្មែរក្រហមអត់មានរៀនអក្សរសាស្ត្រពីវប្បធម៌ខ្មែរអត់ទេ ចាស។

**ស៖** លោកស្រីបាននិយាយអំពីកន្លែង<ហូប>រួម។ នៅកន្លែង<ហូប>រួមហ្នឹង,<>តើនៅកន្លែងនោះមានអ្នកហូបចុកប៉ុន្មាននាក់? <តើមនុស្សទាំងអស់នៅក្នុងសហករណ៍ហូបរួមគ្នា> ឬក៏មាន<>កន្លែងហូបចុករួមនោះ<ច្រើន>? <តើគេហូបយ៉ាងម៉េចទៅ?>

[០៩:៣៦:៣៤]

**ឆ៖** កន្លែងហូបរួមហ្នឹង សហករណ៍។ ក្នុងមួយតុបួននាក់។ បួននាក់អីចឹង សម្លមួយកូនឆ្នាំងបាយបួនចាន ម្នាក់មួយវែកៗបាយ បបរ។ ហើយសម្លគេដាក់កណ្ដាលអីចឹង ហូបអស់តែប៉ុណ្ណឹង ចប់ហើយ។ ប្រុសៗគេហូប ដោយប្រុសៗទៅ ស្រីៗហូបដោយស្រីៗ។ របបមានតែប៉ុណ្ណឹងដូចគ្នា អត់មាននរណាថា ប្រុសហូបច្រើនឲ្យច្រើន អត់ទេ។ ចាស គឺមួយវែកស្មើគ្នា។

**ស៖** បាទ ខ្ញុំយល់ហើយ ដឹងថាលោកស្រី<>ពិសាជាក្រុម ក៏ប៉ុន្តែក្រុមទាំងអស់នោះជុំគ្នា សួរថាមានប៉ុន្មាននាក់ដែរ? លោកស្រីដឹងទេ ប្រហាក់ប្រហែលប៉ុន្មាន? ប្រសិនបើលោកស្រីមិនដឹង ក៏មិនជាបញ្ហាអ្វីដែរ។

**ឆ៖** ចាស ខ្ញុំអត់ដឹង អត់បានរាប់ទេ។ ព្រោះហូបជាក្រុមហ្នឹង គឺមនុស្សមួយភូមិ។ មានអ្នកខ្លះគេហូបអីចឹង អ្នកខ្លះគេយកបាយទៅហូបផ្ទះ។ គេមានបញ្ហាគេយកបាយហូបផ្ទះ មិនដឹង មិនអាចដឹងថាក្នុងមួយភូមិហ្នឹងហូបនៅសហករណ៍ហ្នឹងប៉ុន្មាននាក់។ ចាស អត់ដឹងទេ។

**ស៖** បាទ លោកស្រីបាននិយាយអំពី<ការ>ធ្វើទស្សនកិច្ចរបស់មេដឹកនាំដែលលោកស្រីបានឃើញ។ តើលោកស្រីបានឃើញអ្នកធ្វើទស្សនកិច្ចផ្សេងទៀតទេ នៅសហករណ៍លាយបូរហ្នឹង?

[០៩:៣៨:៣០]

**ឆ៖** ចាស អត់មានទេ។ មានតែគាត់មេដឹកនាំខ្មែរក្រហមបីរូបហ្នឹង ហើយនិងលោក តាម៉ុក–ប្អូនរូបហ្នឹង ចុះទៅការដ្ឋានហ្នឹង ខ្ញុំនៅការដ្ឋានហ្នឹងប្រហែលជាជាង ១០ថ្ងៃ ប្រហែលជាកន្លះខែ។ ហើយហ្នឹងដកទៅតាមប្រព័ន្ធការដ្ឋាននៅតាមភូមិ នៅក្បែរភូមិវិញ។

**ស៖** អ៊ីចឹង ដើម្បីឲ្យច្បាស់ទាំងអស់គ្នា គឺថាលោកស្រីមិនដែលឃើញគណៈប្រតិភូផ្សេងទៀតទេ <>ដែលមានលោកបស្ចិមប្រទេស បរទេស <ចូលរួម> ឬក៏មានជនជាតិចិនអ៊ីជាដើមទេឬក៏ឥស្សូរជនបរទេសផ្សេងទៀត<ទេ>?

**ឆ៖** ចាស ឃើញម្ដង ពេលខ្ញុំចុះស្ទូង។ សម្រុកស្ទូង គេ -- ខ្ញុំស្ទូង គេដាក់ស្ទូងស្មើគ្នា តែគេបរទេស មិនដឹងជាអីទេ គេមកថតៗប្រជាពលករស្ទូង យកទៅស្រុកគេ។ ហ្នឹងមេកងខ្ញុំប្រាប់។ គេមានថតរូបទៀតចាស។ ថតរូបយកទៅប្រជាពលករស្ទូង។

**ស៖** <អ៊ីចឹង> លោកស្រីបានឃើញតែម្ដងទេ<ឬ>? ហើយលោកស្រីចាំទេ? គឺមេឃុំ<> ប្រាប់លោក<ស្រីអំពីរឿងនោះ> ឬក៏លោកស្រីបានឃើញដោយខ្លួនឯង? ហើយបើបានឃើញ គឺនៅពេលណាដែរ កាល បរិច្ឆេទប្រហាក់ប្រហែល?

**ឆ៖** ខ្ញុំស្ទូងនៅប្រហែលជាឆ្នាំ៧៦ ស្ទូងហ្នឹង ហើយគេចុះមកថតៗយកទៅស្រុកគេ ហើយខ្ញុំមើលអ្នកថតអត់ដឹងអ្នកណាទេ ព្រោះខ្ញុំគេឲ្យស្ទូង អត់មានឲ្យងើបទេណា។ ស្ទូងឲ្យលឿនទៅស្មើគ្នាដង្ហែគ្នាអ៊ីចឹង គេថតៗយកទៅ។ ហើយមិនដឹងជាបរទេស ឬក៏ខ្មែរជាន់ខ្ពស់ អត់ដឹងទេ អត់ដឹងអ្នកណាជាអ្នកថតទេ ប៉ុន្តែមេកងខ្ញុំប្រាប់ថា "ស្ទូងឲ្យទន្ទឹមៗគ្នា ឲ្យដង្ហែគ្នាចាប់ផ្ដើមលឿនអ៊ីចឹងទៅគេថត"។ ចាស មេកងខ្ញុំប្រាប់ប៉ុណ្ណឹង។

[០៩:៤១:១៨]

**ស៖** បាទ លោក<ស្រី>ប្រាប់ថា មេកងរបស់លោកស្រីឈ្មោះ <អឿន> <>លោកស្រីបានប្រាប់ថាមេភូមិរបស់លោក<ស្រី> ឈ្មោះ ឈិន។ តើលោកស្រីអាចរៀបរាប់ឈ្មោះមេនៅសហករណ៍ ឬក៏ មេនៅថ្នាក់ស្រុកអីជាដើមហ្នឹង មានឈ្មោះអីខ្លះលោកស្រី ជួយរៀបរាប់បានទេ?

**ឆ៖** ឈ្មោះមេភូមិដែលចុះមុនដំបូងនៅពោធិ៍ព្រះសង្ឃនោះ ហ្នឹងដោយខ្លួន ហ្នឹងឈ្មោះលោកថាអំមិញហ្នឹង ឈ្មោះឈិន។ នៅពោធិ៍ព្រះសង្ឃចុះមកដំបូងឈ្មោះ ឈិន មេៗភូមិ។ ដល់បន្ទាប់មក នៅធ្វើខ្ទមហើយ បញ្ជូនមកនៅខាងជើងសាលាឃុំហ្នឹង ឈ្មោះ តាវិត មកដល់កន្លែងខាងជើងសាលាឃុំលាយ

បូរហ្នឹងឈ្មោះ តាវិត មេកង។ ដល់បន្ទាប់ពីចេញពីភូមិតាវិត ទៅនៅកង៣៖ ឈ្មោះ អឿន, ឈ្មោះ ជឹម, ឈ្មោះ អន។ ចាស គេមេភូមិ ហើយនិងគណៈឃុំ គណៈស្រុក ចាស គណៈឃុំ គណៈស្រុក តាធំជាងគេ តាហួញៗ, តានៅ, តាកិ, តាប៉ូ ហើយនិងគណៈស្រុក – តាសាន។ ស្គាល់ប៉ុណ្ណឹងចាស។

**ស៖** តាសានហ្នឹង គាត់មកសហករណ៍ហ្នឹងញឹកញាប់ទេ? លោកស្រីបានឃើញគាត់ច្រើនដងទេ?

**ឆ៖** ខ្ញុំឃើញលោក តាសាន គណៈស្រុក ឃើញញឹកញាប់ដែរ ព្រោះខ្ញុំជីប្រឡាយ។ តាមប្រឡាយភូមិក៏គាត់ទៅ ប្រឡាយថ្នល់ជាតិក៏គាត់ទៅ គាត់ទៅគ្រប់ប្រឡាយ។ គាត់នៅស្រុក នៅត្រឹមអង្គតាសោមហ្នឹង គាត់ចុះមកលាយបូរហ្នឹងរហូតដែរចាស។

[០៩:៤៣:៤៩]

**ស៖** តើ<>លោកស្រីបានឃើញ និងបានឮ<គេ>និយាយពីក្រុមសិល្បៈសៀកចិនដែលបានទៅសហករណ៍លាយបូរនោះ ធ្លាប់បានឮ ឬបានឃើញទេ?

**ឆ៖** ខ្ញុំអ្នក១៧ មិនអាចឃើញសិល្បៈសៀកចិនទេ គេមើលតែមេ -- អ៎! គណៈឃុំ គណៈអីទេ យើងជាអ្នកប្រជាពលរដ្ឋ១៧ អត់អាចចូលទៅបានមើលជិតអស់ហ្នឹងបានទេ។

**ស៖** បាទ សំណួរចុងក្រោយ។ តើនៅសហករណ៍លាយបូរហ្នឹងមានវត្តអីទេ? ហើយបើមានតើវត្តហ្នឹង<បានក្លាយជាកន្លែងអ្វីដែរ>?

**ឆ៖** វត្តលាយបូរ កាលពីជំនាន់សង្គមប្រជាធិបតេយ្យខ្មែរក្រហមហ្នឹងក្លាយជាកន្លែងដាក់កុមារ ហើយអ្នកទោសក៏មានដាក់នៅកន្លែងហ្នឹងដែរ ហើយនិងកុមារ។ អ្នកទោសមានទោសក៏នៅ ដាក់នៅវត្តលាយបូរដែរ តែមានច្រើនកន្លែង មានវិហារ មានសាលា មានកុដិលោក។ កន្លែងវត្តអារាមហ្នឹងក្លាយជាកន្លែងអ្នកទោសពីសង្គម ប៉ុល ពត តែឥឡូវគេជឿនលឿនល្អ។

**ស៖** បាទ សូមអរគុណលោកស្រី។ ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[០៩:៤៦:០៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក សួន វិសាល៖**

សូមគោរពលោកប្រធាន! សូមជម្រាបសួរលោក -- លោកស្រី គឹមឡុន បាទ។

**ស៖** ខ្ញុំបាទឈ្មោះ សួន វិសាល ខ្ញុំជាមេធាវីឲ្យលោក នួន ជា បាទ។ ហើយបន្ទាប់ទៅនេះ ខ្ញុំបាទសុំសួរសំណួរមួយចំនួនទាក់ទងទៅនឹងស្ថានភាពនៅក្នុងសហករណ៍របស់អ្នកស្រី ហើយទាក់ទងទៅនឹងការកាប់សម្លាប់ ហើយនិងចំណុចទី៣ គឺទាក់ទងទៅនឹងអាពាហ៍ពិពាហ៍បាទ។ ជាដំបូងនេះ ខ្ញុំចង់សួរអ្នកស្រីទាក់ទងទៅនឹងសហករណ៍។ តើនៅពេលដែលអ្នកស្រីចាកចេញពីទីក្រុងភ្នំពេញទៅៗដល់ឃុំលាយបូរហ្នឹង តើគេចាប់ផ្តើមធ្វើសហករណ៍ភ្លាមតែម្តង ឬក៏អ្នកស្រីរស់នៅជាធម្មតាជាមួយនឹងក្រុមគ្រួសារទេបាទ?

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** យើងទៅដល់ដំបូង គេអត់ទាន់ចាប់ផ្តើមហូបបាយរួមទេ ហូបជាឯកជនសិន តែគេចែកជាពោតសាលីឲ្យយើងហូប។ ដល់តែបានយូរខែ ដល់ខែ -- យូរខែបន្តិច គេមកប្រមូលចានយើង ឆ្នាំងយើងយកទៅដាក់រួម បានគេចាប់ផ្តើមហូបបាយរួម។

**ស៖** តើគេចាប់ផ្តើមហូបបាយរួមនៅ -- តើអ្នកស្រីអាចចាំច្បាស់លាស់ទេតើពេលណាដែរ? ប្រហែលប្រាំខែ ប្រាំមួយខែ ឬក៏មួយឆ្នាំ?

**ឆ៖** ហូបបាយរួមពេលដែលយើង ពេលយើងចុះស្នងខែ៨១ ចាសខែ៨ ខែ៨ ចាប់ផ្តើមប្រមូលខែ៨ ១៩៧៥។

**ស៖** បាទ សូមអរគុណ។ នៅក្នុងភូមិរបស់អ្នកស្រី តើមានប្រជាពលរដ្ឋដែលចាកចេញពីទីក្រុងទៅភ្នំពេញទៅ តើមានគ្នាប៉ុន្មាននាក់ដែរ?

[០៩:៤៨:១៥]

**ឆ៖** ប្រជាពលរដ្ឋដែលចាកចេញពីទីក្រុងភ្នំពេញនៅភូមិខ្ញុំមានច្រើន។ ហើយនិងចេញពីទីក្រុងតាកែវ ហើយនិងភ្នំពេញមានច្រើន។

**ស៖** មានច្រើនហ្នឹង មានចំនួនប៉ុន្មាននាក់ដែរ អ្នកស្រីអាចដឹងទេ?

**ឆ៖** អត់ដឹងថាមានប៉ុន្មានគ្រួសារ ប៉ុនដឹងតែមានច្រើន។ គ្រួសារខ្ញុំ ប្រាំ-ប្រាំមួយ-ប្រាំពីរគ្រួសារ ហើយទម្រាំគ្រួសារគេទៀត ច្រើន។ ចាស ច្រើនមែនទែន។ មានអ្នកមូលដ្ឋានតិចតួច។ អ្នកមូលដ្ឋានអ្នក១៨ហ្នឹង តិចតួចគេត្រួតលើយើងអ្នក១៧។

**សៈ** បាទ ខ្ញុំចង់ដឹងចំណុចមួយទៀត នៅពេលដែលអ្នកស្រីទៅទីនោះ តើគេមានបែងចែកថាឲ្យការរស់នៅបែកគ្នារវាងអ្នកមូលដ្ឋាន និងអ្នកថ្មីទេ?

**ឆៈ** អត់មានបែងចែកអីទេ។ តែផ្ទះនៅជិតៗគ្នាជាប់ៗគ្នាអ៊ីចឹង តែហូបរួមគ្នាដែរ តែគេមានស្រគួរនៅផ្ទះគេទៀត។ តែយើងអ្នកថ្មីអត់មានទេ។

**សៈ** បាទ សូមអរគុណ។ កាលពីម្សិលមិញ អ្នកស្រីបានលើកឡើងថាអ្នកស្រី -- នៅពេលដែលអ្នកស្រីខ្វះម្ហូបអាហារអី អ្នកស្រីអាចយកសារុងអាចយកអីទៅដូរម្ហូបអាហារហ្នឹងបានហូបមកដាំបាយក្រៅបាន។ តើអ៊ីចឹងមែនទេ?

**ឆៈ** នេះជាការលបលួច។ លបលួចដូរហ្នឹង អត់មានដូរអ្នកឆ្ងាយទេ ដូរអ្នកនៅក្បែរៗយើងហ្នឹង។ អាចគេឲ្យយើងលួចដាំបាយហូប ដាំគេប្រយ័ត្នទៀត។ អត់មានឲ្យពួកដែលឈ្លបឃើញ។ ហើយអ្នកដែលទុកចិត្តបំផុតនៅក្បែរយើង យើងអាចដូរមកបាន ចាស។

[០៩:៥០:៣៧]

**សៈ** បាទ សូមអរគុណ។ អ្នកស្រីអាចលួចដោះដូរបាន។ តើអ្នកស្រីគិតថា អ្នកផ្សេងទៀតនៅក្នុងមូលដ្ឋាន ក៏គេអាចលួចដូរហូបចុកអ៊ីចឹងបានដូចអ្នកស្រី ទេ?

**ឆៈ** លួចដូរបានតែឆ្នាំយើងចុះទៅដំបូងទេណា យើងនៅមានតែសារុងចុះទៅដំបូងហ្នឹងមានអាចដោះដូរបាន រហូតដល់៧៧ អត់មានទេ អស់ហើយ។ ៧៦ អស់ហើយ មានតែ ៧៥ ទេ។ ៧៦ គឺថាស្អាត ទទេស្អាត តែម្តង អត់មានអីមានដូរទៀតទេ មានតែពេលហ្នឹងមានតែលួចដកដំឡូងគេ លួចអីគេគេរើចោល មានតែប៉ុណ្ណឹង។

**សៈ** បាទ សំណួររបស់ខ្ញុំ អ៊ីចេះ ថាតើបើសិនណាអ្នកស្រីលួចដូរបានអ៊ីចឹងសួរថា តើអ្នកដែលមូលដ្ឋាន ឬ អ្នកផ្សេងទៀតដែលគេមានសារុង មានអីដូចអ្នកស្រី តើគេអាចធ្វើបានអត់បើអ៊ីចឹង?

**ឆៈ** គេយើងមិនដឹងដែរ។ គេនៅផ្ទះគេផ្សេង នៅឆ្ងាយៗពីគ្នា។ ហើយយើង មានអ្នកដូចថាជាប់ខ្សែអីតិចៗ យើងអាចពឹងពាក់គេឲ្យយកសារុងដូរឲ្យ ដូរឲ្យអ៊ីចឹង គេយកអង្ករឲ្យយើង។ យើងដាំបាយហូប។ តែគេដូរមកពីខាងណាយើងអត់ដឹងទេ ដឹងតែគេឲ្យអង្ករមកយើងដាំបាយហូប។

**សៈ** ដូច្នេះនៅពេលដែលស្ថានភាពម្ហូបម្ហាមិនសូវគ្រប់គ្រាន់គឺថា យើងប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់អ្នកស្រីអាចដោះដូរអីបាន រកម្ហូបអាហារថែមបានសម្រាប់បំពេញតម្រូវការទាំងប្រជាពលរដ្ឋចាស់និងថ្មី។ អ៊ីចឹងមែនទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹង ១៩៧៥ ដែលទើបទៅដល់ថ្មី អាចដោះដូរបាន តែ៧៦ អត់មានទេ។ ៧៦ គឺចាប់ចម្រាញ់ពី ៧៦ ហ្នឹងទៅរហូត អត់មានដោះដូរ អត់មានលបដាំអីបានទេ។ សូម្បីតែឃើញភ្លើងពេលយប់ក៏គេមកសួរដែរ។ សួរថា៖ "មានដាំអី?" ថា៖ "ដាំទឹកក្តៅហូប"។ ដើរធ្វើការតាមកងកុំឲ្យវាឈឺពោះ ឈឺអី។ ពី៧៦ ទៅចម្រាញ់រហូត។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរ បន្ទាប់ទៀត ទាក់ទងទៅនឹងការធ្វើការងារម្តង។ នៅពេលដែលអ្នកស្រីទៅដល់ទីនោះ គឺថាយើងអ្នកស្រីចូលធ្វើការនៅក្នុងសហគមន៍ ឬក៏សហករណ៍ហ្នឹងតែម្តង តើគេមានបែងចែកថា អ្នកថ្មីទៅធ្វើការងារផ្សេង ហើយអ្នកមូលដ្ឋានត្រូវធ្វើការងារផ្សេងឬទេ?

[០៩:៥៣:៣៨]

**ឆ៖** ធ្វើការងារជាមួយគ្នា។ អ្នកថ្មីចាំលបឱបក្តាប់ -- អ៎! អ្នកចាស់ ១៨ ចាំលបឱបក្តាប់អ្នកថ្មី តើមាននិយាយអ្វីដែលខុសហ្នឹងមាត់គេឬអត់? ឃ្លានបាយ ហេវបាយ ហូបមិនឆ្អែត ឲ្យអ្នកចាស់ធ្វើការជាមួយនឹងអ្នកថ្មីហ្នឹងគឺលបឱបក្តាប់ បើមាននិយាយខុស គេនឹងយកយើងទៅកសាង។ បើកសាងបើមានទោសឡើងគេស្អប់យើង គេដាក់ទោសធ្ងន់ គេយកយើងទៅរៀនសូត្របាត់។ ហ្នឹងអ្នកចាស់គេធ្វើការជាមួយយើងដើម្បីឱបក្តាប់យើងអ្នកថ្មី។ អត់មានអ្នកចាស់ធ្វើដោយខ្លួនទេ ធ្វើជាមួយគ្នាទាំងអស់។

**ស៖** បាទ សូមចង់រំឭកអ្នកស្រីបន្តិចថា ខ្ញុំ អ្វីដែលខ្ញុំសួរខ្ញុំចង់បានឆាប់ពេលវេលាដែរ។ ព្រោះថា ខ្ញុំសួរចំណុចណា គឺថាអ្នកស្រីឆ្លើយហ្នឹង កាលណាឆ្លើយវែងពេក គឺថាអាចបាត់បង់ពេលវេលា ព្រោះអ្នកស្រីបានឆ្លើយទៅសំណួររបស់ព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ។ អ៊ីចឹង ខ្ញុំអ្វីដែលខ្ញុំគ្រាន់តែចង់បញ្ជាក់បន្ថែមប៉ុណ្ណោះ ខ្ញុំមិនចង់ឲ្យឆ្លើយវែងឆ្ងាយទេ។ ឥឡូវ ខ្ញុំចង់សួរអ្នកស្រីបន្តទៀត។ នៅពេលដែលអ្នកស្រីមានជំងឺ តើគេឲ្យអ្នកស្រីសម្រាកដែរទេ?

**ឆ៖** បើវាឲ្យសម្រាកមានបញ្ហាអី ទាស់រឿងគេអត់ឲ្យសម្រាកហ្នឹងតើ។ បានតែអត់ឲ្យសម្រាកហ្នឹងហើយ ហើយបើយើងសម្រាកតែកន្លះថ្ងៃ កន្លះថ្ងៃ តែឃើញបាត់លើសហ្នឹង គេផ្តាច់របប។

**ស៖** កាលពីម្សិលមិញ អ្នកស្រីបានលើកឡើងថា នៅពេលដែលកូនអ្នកស្រីឈឺ ឬក៏អ្នកស្រីឈឺ អ្នកស្រីអាចមានពេលឲ្យឈប់សម្រាក ប៉ុន្តែគេមិនឲ្យអាហារពេញលេញទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនអ៊ីចឹងទេ។ គេ -- យើងឈប់កូនឈឺ គេផ្តាច់អាហារយើង។ យើងហូបអាហាររបស់កូន ដែលកូនឈឺហ្នឹង ម្តាយហ្នឹងក៏អាចទៅសុំអាហារគេមក ហើយយើងហូបអាហាររបស់កូន។ យើងអត់បានអាហារទេ។

**ស៖** ខ្ញុំសួរបន្ទាប់ទៀតទាក់ទៅនឹងអ្នកស្រី កាលពីម្សិលមិញបានលើកឡើងថា អ្នកស្រីមានបាន សម្រាលកូន ហើយអ្នកស្រីបានឈប់សម្រាក បើគេឲ្យឈប់សម្រាកដូចអ្នកស្រីលើកឡើងហ្នឹងឬទេ?

**ឆ៖** សម្រាលកូន គេឲ្យសម្រាកហើយ យើងសម្រាលកូន។ សម្រាលកូនដេកភ្លើង ដេកភ្លើង ហើយបាន ដេកភ្លើងបានប្រាំថ្ងៃ ហើយយើងសម្រាកបាន២៧ថ្ងៃគត់ គេឲ្យយើងទៅច្រូត។

[០៩:៥៦:៤៣]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីក៏បានលើកឡើងទៀតដែរថា ម្សិលមិញអ្នកស្រីនៅពេលអ្នក ស្រីមានកូនតូចអ៊ីចឹង គឺអ្នកស្រីធ្វើការមិនពេញម៉ោងដូចគេទេ គឺអ្នកស្រីធ្វើត្រឹមតែម៉ោងដប់អីប៉ុណ្ណឹង គឺ អ្នកស្រីអាចឈប់សម្រាកបានហើយ។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** ចាស អ៊ីចឹងមែន បើយើងកូនខ្ចីយើង ២៧ថ្ងៃ ត្រឹមមួយខែអីហ្នឹង យើងឈប់ធ្វើច្រូតស្រូវអី ហ្នឹងត្រឹមម៉ោងដប់ ឬដប់កន្លះចាស។

**ស៖** បាទ សូមអរគុណ។ ចុះចំពោះស្ត្រីផ្សេងទៀតដែលមានកូនដូចអ្នកស្រីដែរ តើគេឈប់ដូច គ្នាអ៊ីចឹងដែរឬទេបាទ?

**ឆ៖** អ្នកថ្មីៗដល់ពេលចេញទៅ អត់មានអ្នកណាប្រសូត្រកូននៅកន្លែងហ្នឹងផង មានតែកូនគេ កើតពីភ្នំពេញទៅ មានតែគេអី។ ហើយប៉ុនដល់មកយូរមក គេមានប្រសូត្រ តែគេឈប់បានយូរជាងខ្ញុំ ព្រោះខ្ញុំទើបតែបែកថ្មីៗ កំពុងជាចំណាប់ខ្មាំងចាស។ ក្រោយមក គេឈប់បានមួយខែ បានមួយខែពីរបី ថ្ងៃអ៊ីចឹងទៅ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមទៅប្រធានបទថ្មីមួយទៀត គឺទាក់ទងទៅនឹងការសម្លាប់ មនុស្សម្តង។ អ្នកស្រីបានលើកឡើងថា មានក្មួយអ្នកស្រីម្នាក់– កាលពីម្សិលមិញ អ្នកស្រីបានលើកឡើង ក្មួយស្រីម្នាក់– ត្រូវបានគេសម្លាប់ដោយសារគេដឹងថាជាកូនកម្មាភិបាលជំនាន់មុន។ ហើយប្រពន្ធរបស់ គាត់ហ្នឹង ត្រូវសម្លាប់ផ្ទាល់តែម្តងដោយវះពោះអ៊ីចឹង។ តើអ៊ីចឹងមែនទេបាទ?

[០៩:៥៨:៤៩]

**ឆ៖** ចាសអ៊ីចឹងមែន ពិតប្រាកដ។

**ស៖** នៅពេលដែលអ្នកស្រីលើកឡើងពីបញ្ហានោះ អ្នកស្រីបានលើកឡើងថាអ្នកស្រីបានឮតែគេ និយាយប្រាប់អ្នកស្រីទេ អ្នកស្រីមិនបានឃើញព្រឹត្តិការណ៍ហ្នឹងពិតប្រាកដទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** យាយបង្កើតអ្នកឃើញៗ ព្រោះចៅហ្នឹងនៅជាមួយគាត់ផ្ទាល់ដៃ។ យាយបង្កើតនៅជាមួយ

គ្នា នៅជិតកន្លែងពាណិជ្ជ សង្គមកិច្ច យាយបង្កើតឃើញផ្ទាល់។

**ស៖** បាទអ្វីដែលខ្ញុំសួរអ្នកស្រីគឺអ៊ីចេះទេ ថាតើអ្នកស្រីបានឃើញផ្ទាល់ ឬក៏មិនផ្ទាល់បាទ? បាទឆ្លើយតែប៉ុណ្ណឹងបានហើយបាទ។

**ឆ៖** ខ្ញុំអត់បានឃើញផ្ទាល់ទេ តែដន្លងមក--

**ស៖** បាទៗសូមអរគុណ។ ខ្ញុំចង់បានតែប៉ុណ្ណឹងទេបាទចម្លើយ។ ហើយអ្នកស្រីក៏បានលើកឡើងផងដែរថា នៅពេលដែលមានអ្នកណាជាប់ប្រវត្តិរូបពីកម្មាភិបាលថ្នាក់មុនអ៊ីចឹង គឺថានៅក្នុងសហគមន៍អ្នកស្រី គឺត្រូវសម្លាប់ គឺត្រូវគេចាប់សម្លាប់ កាលណាគេដឹង។ អ៊ីចឹងមែនទេបាទ?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរមួយទៀតបាទ។ នៅក្នុងចម្លើយរបស់អ្នកស្រីកាលពីម្សិលមិញអ្នកស្រីបានលើកឡើងថា ឪពុកអ្នកស្រីធ្វើមន្ត្រីរាជការតាំងពីសម័យសង្គមរាស្ត្រនិយមរហូតដល់ជំនាន់ លន់ នល់។ តើគាត់ធ្វើអ្វីដែរបាទ?

**ឆ៖** ចាស គាត់ធ្វើមេឃុំលាយបូរ–ចៅសង្កាត់។

**ស៖** តើនៅក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ តើគាត់រស់នៅទីនោះឬទេ?

**ឆ៖** ចាស គាត់រស់នៅជាមួយខ្ញុំរហូត ប៉ុន្តែមេកងគេគណៈឃុំ គេយកគាត់ទៅរៀនសូត្រពីរដងទៅចម្រាញ់ឲ្យគាត់ព្រមចូលធ្វើការជាមួយគេ ប៉ុន្តែគាត់បដិសេធដាច់ខាតអត់ធ្វើ គាត់នៅធ្វើបង្គីឲ្យពលករវែកដី។

[១០:០១:១៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់បន្ថែមទៀតថា នៅពេលនោះគឺខាងទាហាន ឬក៏មេឈ្លបអ៊ីចឹង គេមិនបានចាប់ឪពុកអ្នកស្រីទៅដាក់ពន្ធនាគារឬអីទេ។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** ចាស គណៈឃុំ តាហួយ និង តានៅ គេមកសម្ភាសដល់ផ្ទះ គេមកសម្ភាសឲ្យសុំស្នើគាត់ឲ្យជួយធ្វើការអង្គការជាមួយគេ ធ្វើឲ្យជួយធ្វើការ គេធ្វើអីឲ្យធ្វើហ្នឹងវិញ ឪពុកខ្ញុំថាគាត់មានជំងឺលើសឈាមមិនអាចធ្វើបានទេចាស អត់បានចាប់ទេ។ ប៉ុន្តែគេមកបញ្ចុះបញ្ចូល។

**ស៖** បាទ សូមអរគុណ។ កាលពីម្សិលមិញ អ្នកស្រីបានលើកឡើងចម្លើយរបស់អ្នកស្រីចំពោះមុខសហព្រះរាជអាជ្ញាថានៅក្នុងភូមិរបស់អ្នកស្រីទាំងអស់ គឺក្នុងរយៈពេលដែលអ្នកស្រីរស់នៅរហូតដល់បែកឆ្នាំ១៩៧៩ គឺមានការចាប់ខ្លួនតែពីរនាក់ទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ហ្នឹងនៅកង៣ កន្លែងខ្ញុំទៅហ្នឹង ចាប់ខ្លួនពីរនាក់ដែលខ្ញុំមកដល់នៅខាងជើងសាលាឃុំមានចាប់ច្រើន កាលមកដល់ដំបូង ឆ្នាំ៧៥ ហ្នឹងមានចាប់ច្រើន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរសំណួរមួយទៀតទាក់ទងទៅនឹង ប្រធានបទមួយទៀតទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ម្តង។ កាលពីម្សិលមិញក៏អ្នកស្រីលើកឡើងផងដែរថា នៅក្នុងសហ-គមន៍របស់អ្នកស្រីមានការរៀបអាពាហ៍ពិពាហ៍តែពីរគូតែប៉ុណ្ណោះ។ តើគេធ្វើនៅពេលណាដែរ?

**ឆ៖** ពេលយប់ សម្រាកពីរែកដី។

**ស៖** តើគេវិធីនៃការរៀបអាពាហ៍ពិពាហ៍នៅពេលនោះ តើគេរៀបចំរបៀបណាដែរ?

**ឆ៖** គេៗឲ្យហៅយើងទៅកន្លែងប្រជុំប្តេជ្ញា ហៅទាំងប្រុស ហៅទាំងស្រីដែលមានឈ្មោះត្រូវប្តេជ្ញា បីគូ រៀបអាពាហ៍ពិពាហ៍ហ្នឹងមិនមែនពីរទេ បីគូចាស។

**ស៖** អ្នកស្រីបានទៅចូលរួមផ្ទាល់ឬទេ?

**ឆ៖** ចាស ទៅ។

[១០:០៣:៥៧]

**ស៖** សូមអរគុណបាទ។ សូមអ្នកស្រីបញ្ជាក់ទៅមើលថាតើ អ្នកនោះឈ្មោះអ្វីខ្លះដែរបាទ?

**ឆ៖** អ្នកនោះ អ្នក១៧ ពីរគូ អ្នកចាស់មួយគូ។ អ្នក១៧ហ្នឹងឈ្មោះ អ៊ី ឆាន់ ហើយនិងម្នាក់ទៀតឈ្មោះ សុខ ហៀង ហើយអ្នកចាស់គេជាអតីតគ្រូកុមារខាង១០មូលដ្ឋានគេឈ្មោះ តុប។

**ស៖** អ៊ីចឹង ដូចជាអ្នកស្រីទើបតែរៀបរាប់បានតែបីនាក់តែប៉ុណ្ណោះ តើមែន ពីព្រោះបីគូ វាមានប្រាំមួយនាក់។ តើអ្នកណាខ្លះទៀតបាទ បីនាក់ទៀតបាទ?

**ឆ៖** ប្រុសជាស្វាមី ជាប្តីហ្នឹងគឺឈ្មោះ កែវ ឈាង ហើយនិងមួយទៀតអ្នកមូលដ្ឋានឈ្មោះ ផ្កា ហើយម្នាក់ទៀតដូចជាឈ្មោះ ហេង– ឈ្មោះហេងអ៊ីចឹងហើយចាស ហេង។ បីនាក់ហ្នឹងប្រុស។

**ស៖** នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ តើមានអ្នកដឹកនាំណាខ្លះដែលមកចូលរួមនៅពេលនោះ?

**ឆ៖** មេកងៗ និងប្រធានភូមិ។ ប្រធានភូមិគេបីបួននាក់ហ្នឹង។

**ស៖** នៅមុនពេលរៀបការ ឬក៏នៅពេលដែលលោកស្រីចូលទៅរស់នៅក្នុងសហគមន៍ហ្នឹង តើសហករណ៍ ឬក៏អ្នកដឹកនាំគេមានប្រកាសថា តើពេលយុវជន ឬក៏យុវនារីណាម្នាក់ចង់រៀបការ ត្រូវរៀបចំរបៀបណាទេ? ឬក៏មានសិទ្ធិជ្រើសរើសគូស្រករបៀបណាដែរ មានបានដឹងមុនទេ?

**ឆ៖** ចាស អត់ទេ។ យើងអត់មានសិទ្ធិជ្រើសរើសទេ។ មេកងនិងមេភូមិគេ។ គេវិភាគគ្នាគេវិភាគគ្នាហើយ គេហៅយើងទៅចូលរួមប្រជុំ ថាថ្ងៃនេះ ទៅចូលរួលប្រជុំប្តេជ្ញា។ គេប្រាប់ថា ប្តេជ្ញា ប៉ុន្តែគេអត់ឲ្យយើងជ្រើសរើសទេ គេហៅបុរសណាដែលពោះម៉ាយ នារីណាដែលពោះម៉ាយ ចូលប្តេជ្ញា ហើយឯ តុប ជាគ្រូនោះ គ្រូអ្នកចាស់នោះ គេមានសិទ្ធិនឹងផ្គូផ្គង គេចាស់ដូចគ្នា។ យើងអ្នកថ្មីអត់មានសិទ្ធិទេ ចាប់ដោយបង្ខំ។

[១០:០៦:៤៦]

**ស៖** អ្នកស្រីថា អ្នកស្រីមិនបានចូលរួមនៅក្នុងពេលដែលគេប្រជុំនោះទេ។ អ្នកស្រីធ្វើម៉េចបានដឹងពីបញ្ហាហ្នឹង?

**ឆ៖** ខ្ញុំទៅមើលដោយផ្ទាល់។ ទៅមើលមិនដឹងគេប្តេជ្ញាអ្នកណាគេខ្លះ ខ្ញុំទៅមើល។ ដល់ទៅមើល ឃើញគេហៅប្តេជ្ញាបីគូហ្នឹង។

**ស៖** អ្នកធ្វើយ៉ាងម៉េចបានដឹងថាគេបង្ខំ? បើអ្នកស្រីមិនបានចូលរួមប្រជុំជាមួយនឹងមេកងរបស់គេផងនៅពេលនោះបាទ។

**ឆ៖** ដល់ពេលស្អែកឡើង យើងដឹងៗថាគេអត់ពេញចិត្ត ចាស។ គេបាននិយាយត្អូញត្អែរថាគេអត់ពេញចិត្ត តែគេប្តេជ្ញាអត់ឲ្យយើងដឹង។ យើងនៅក្រោមរបបអង្គការ យើងត្រូវតែទ្រាំៗទាំងឈឺចាប់ យកអ្នកណាក៏ចេះតែយក ឲ្យតែរស់។ ទ្រាំអ៊ីចឹង តាមហ្នឹងទៅ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរសំណួរមួយទៀត ទាក់ទងទៅនឹងការចាប់ខ្លួនជនជាតិវៀត-ណាម និងកម្ពុជាក្រោមពីរគ្រួសារ។ តើនៅពេលមុន ពេលគេចាប់ខ្លួនហ្នឹង តើក្នុងសហគមន៍របស់អ្នកស្រី មានបាន គេមានបានប្រកាសថាឲ្យតែជនជាតិវៀតណាម ឬក៏ខ្មែរកម្ពុជាក្រោម ត្រូវតែបោសសម្អាតឬទេបាទ?

**ឆ៖** ចាស គេបានប្រាប់។ គេបានប្រាប់ថា ជនជាតិវៀតណាម បើមានជនជាតិវៀតណាមនៅក្នុងភូមិយើង ត្រូវតែប្រមូលបញ្ជូនទៅស្រុកគេវិញ។ គេបោសសម្អាតប្រមូលទៅស្រុកគេវិញ ដើម្បីកុំមានវៀតណាម--

**ស៖** បាទ សូមអរគុណ។ ក្នុងនោះគេមិនៗប្រកាសជាទូទៅថាត្រូវតែសម្លាប់ទេ គ្រាន់តែអ្នកទាំងនោះត្រូវតែប្រមូលទៅប្រទេសវៀតណាមវិញ។ តើអ៊ីចឹងមែនទេ បាទ?

[១០:០៨:៥៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាស គេថា មេកងគេប្រាប់គាត់ថាអ៊ីចឹងថា "គេឲ្យខ្ញុំទៅស្រុកវិញ។ គេថាឲ្យខ្ញុំទៅតាមកាត់ទៅតាមត្រាំកក់។ ទៅតាមកំពត តាមទូក តាមកប៉ាល់"។ តែអ្នកទាំងអស់នុ៎ង ពេលដែលទៅបាត់ យើងបានដឹងតាមខ្សឹបខ្សៀវ អ្នកដែលមូលដ្ឋានគេប្រាប់យើងថា "មិនមែនជាការពិតទេ"។ គេប្រាប់តែប៉ុណ្ណឹង។ គេថាវគ្គរៀនសូត្រ មិនមែនជាការពិតទេ យកទៅរៀនសូត្រហើយ។

**ស៖** ដូច្នេះ អ្វីដែលអ្នកស្រីលើកឡើងអម្បាញ់មិញថា ប្រហែលជារៀនសូត្រ គឺគ្រាន់តែជាការស្មានរបស់អ្នកស្រី ឬតាមគេប្រាប់តែប៉ុណ្ណោះ មិនបានដឹងពិតប្រាកថាមានការសម្លាប់ ឬក៏អ្វីទេ។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** គេអ្នកចាស់ គេអ្នកមូលដ្ឋាន គេអាចដឹងការពិត បានគេហ៊ានប្រាប់យើងថា មិនមែនបញ្ជូនទៅស្រុកទេ គឺជាការកុហកទេ។

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែអ្វីដែលខ្ញុំបញ្ជាក់គឺ ចង់បញ្ជាក់ថា តើអ្នកស្រីបានឮហ្នឹង សម្ដីដែលគេកម្ទេចហ្នឹង តាមគេតែប៉ុណ្ណោះ មិនបានឮផ្ទាល់ខ្លួន ឬក៏ដឹងផ្ទាល់ខ្លួនទេ។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** ខ្ញុំពេលប្រជុំតាមភូមិ ខ្ញុំឮតើ។ ឮគេថា ធ្វើការកុំឲ្យយកជើងខ្មាស់នឹងកងប្រវត្តិសាស្ត្រ បើអ្នកណានឹងខ្មាស់នឹងកម្ទេច។

**ស៖** បាទ សូមអរគុណ។ មិននេះមែនជាសំណួររបស់ខ្ញុំ។ បាទ ខ្ញុំសួរថា អ្វីដែល -- ប្រហែលជាយល់ច្រឡំសំណួររបស់ខ្ញុំ។ ខ្ញុំសួរថា អ្វីដែលអ្នកស្រីដឹងថាជនជាតិវៀតណាមទាំងពីរនាក់នោះទៅត្រូវបានគេសម្លាប់ ឬក៏អប់រំហ្នឹង ឮគេនិយាយក្រោយពេលដែលគាត់ចាកចេញទៅស្រុកទេ។ អ៊ីចឹងមែនឬទេបាទ?

**ឆ៖** ចាស។

**លោក សួន វិសាល៖**

សូមអរគុណ។ ខ្ញុំអស់សំណួរប៉ុណ្ណោះ ហើយសហការីរបស់ខ្ញុំនឹងបន្តសំណួរទៀត។

សូមអរគុណលោកតុលាការបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះក្នុង

រយៈពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា បន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើសម្បទារបស់ជនជាប់ចោទ។

នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចផ្ទាល់មាត់លើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ។ អនុលោមតាមវិធាន៣២ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានចាត់តាំងអ្នកជំនាញពីររូប ដើម្បីពិនិត្យវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ ថាតើជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ។ វេជ្ជបណ្ឌិត ចាន់ គីនមិង ជាវេជ្ជបណ្ឌិតផ្នែកព្យាបាលថែទាំជំងឺមនុស្សចាស់ និងវេជ្ជបណ្ឌិត ហួត លីនណា ជាឯកទេសវេជ្ជបណ្ឌិតវិកលវិទ្យា ដើម្បីពិនិត្យវាយតម្លៃលើសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទទាំងពីររូប កាលពីថ្ងៃទី១៩ និងថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥។

កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់អ្នកជំនាញ នៅក្នុងសវនាការដែលធ្វើឡើងជាសាធារណៈ ដោយអ្នកជំនាញបានឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគី។ ដោយពិចារណាលើសក្ខីកម្មនិងរបាយការណ៍របស់អ្នកជំនាញ ពាក់ព័ន្ធនឹងវាយតម្លៃលើសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះរកឃើញថាជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ជនជាប់ចោទនីមួយៗនៅមានសមត្ថភាពក្នុងការចូលរួមសវនាការ ដោយអត្ថន័យក្នុងការការពារខ្លួន និងអាចយល់ដឹងពីសារៈសំខាន់នៃ

កិច្ចដំណើរការនីតិវិធី។

[១០:៣៥:៣០]

ដោយយោងទៅតាមអនុសាសន៍របស់អ្នកជំនាញ អង្គជំនុំជម្រះនឹងបង្គាប់ឲ្យមានការពិនិត្យ និងតាមដានលើស្ថានភាពសុខភាពរបស់ជនជាប់ចោទឲ្យបានសមស្រប។ ជាផ្នែកមួយនៃសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះក៏នឹងកែសម្រួលកាលវិភាគនៃការធ្វើសវនាការក្នុងពេលបច្ចុប្បន្ននេះផងដែរ។ ដោយសារស្ថានភាពសុខភាពបច្ចុប្បន្នរបស់ ខៀវ សំផន អ្នកជំនាញបានផ្ដល់អនុសាសន៍ឲ្យធ្វើការកាត់បន្ថយពេលវេលាសវនាការ ដើម្បីឲ្យមានពេលវេលាសម្រាកបានច្រើនជាងមុន។ ហេតុដូច្នេះ ចាប់ពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៥នេះតទៅ អង្គជំនុំជម្រះនឹងចាប់ផ្ដើមសវនាការពីម៉ោងប្រាំបួនព្រឹក ហើយសម្រាកអាហារថ្ងៃត្រង់នៅវេលាម៉ោងដប់មួយ និង សាមសិបនាទី។ អង្គជំនុំជម្រះនឹងបន្តសវនាការ នៅរសៀលម៉ោងមួយនិងសាមសិបនាទី ហើយនិងសម្រាកនៅវេលាម៉ោងបួន។

ចាប់ពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ខាងមុខនេះតទៅ អង្គជំនុំជម្រះនឹងធ្វើសវនាការបួនថ្ងៃ ក្នុងមួយសប្ដាហ៍ គឺពីចន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍តាមដែលអាចធ្វើទៅបាន។ អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីក្នុងពេលឆាប់ៗខាងមុខនេះ ពីកាលវិភាគសវនាការដែលបានកែតម្រូវ។ ទាក់ទងនឹងលំដាប់លំដោយនៃការកោះហៅសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនាពេលបច្ចុប្បន្នេះ។ អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដោយឡែកនៅលើសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទនីមួយៗ នៅក្នុងពេលសមស្របឆាប់ៗខាងមុខនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១០:៣៧:៣៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រី គឹមឡុន។ ខ្ញុំជាមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរទៅលោកស្រីនៅព្រឹកនេះ។ លោកស្រីកើតនៅក្នុងឆ្នាំ១៩៥១ នៅភូមិលាយបូរ។ តើលោកស្រីចម្រើនវ័យ មានន័យថា រស់នៅធំធាត់នៅភូមិកំណើតនោះ <ឬនិយាយម្យ៉ាងទៀតថា មុនពេលលោកស្រីបានទៅរស់នៅភ្នំពេញ តើលោកស្រីបានរស់នៅភូមិកំណើតនោះទេ? តើលោកស្រី

បានទៅរៀនទេ?> សូមលោកស្រីរៀបរាប់ជូនអង្គជំនុំជម្រះបន្តិច?

**លោកស្រី ជូ គឹមឡូន៖**

**ឆ៖** ខ្ញុំរស់នៅ នៅឃុំលាយបូរ នៅតាំងពីក្មេងមក តាំងពីកើតមក នៅឃុំលាយបូរ ចាស។ ធំធាត់នៅទីនោះ ដល់ពេលមានគ្រួសារបានមកនៅភ្នំពេញ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកស្រីរៀបការនៅអាយុ១៩ឆ្នាំ គឺរៀបការនៅឆ្នាំ១៩៧០ ហើយបានចូលមករស់នៅក្រុងភ្នំពេញឆ្នាំ១៩៧២។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ត្រូវហើយ។

**ស៖** ចុះបងប្អូនស្រីរបស់លោកស្រី គឺថាកើតហើយនិងរស់នៅធំធាត់ក្នុងភូមិកំណើតដូចគ្នាហ្នឹងដែរឬទេ?

**ឆ៖** បងខ្ញុំស្រីៗរស់នៅលាយបូរទាំងអស់។ ចាស មានប្ដីមកនៅភ្នំពេញ ពីរនាក់ ម្នាក់ទៀតនៅតាមខេត្ត។

**ស៖** ឪពុករបស់លោកស្រីធ្វើជាមេឃុំ។ តើលោកស្រីនៅចាំទេថា តើគាត់បានឡើងធ្វើជាមេឃុំលាយបូរនៅឆ្នាំណាដែរ?

[១០:៤០:០១]

**ឆ៖** តាំងៗខ្ញុំនៅតូច តាំងខ្ញុំនៅតូចៗ យូរឆ្នាំហើយចាស។ តាំងខ្ញុំនៅតូចៗ គាត់ធ្វើរហូតតាំងពីខ្ញុំនៅតូច។ កាលគាត់នៅកម្លោះ គាត់ធ្វើស្មៀន ដល់ពេលការជាមួយម្ដាយខ្ញុំបានប្រហែលបួនដប់ឆ្នាំបានគាត់បានឡើងជាមេឃុំ។ គាត់ធ្វើស្មៀនតាំងនៅកម្លោះ។

**ស៖** តើលោកស្រីដឹងថាគាត់កើតហើយៗរស់នៅដឹងក្ដីរហូតដូចដែលលោកស្រីនៅភូមិលាយបូរដែរឬយ៉ាងម៉េច?

**ឆ៖** លោកឪពុកខ្ញុំគាត់កើតនៅឃុំលាយបូរ ប៉ុន្តែមិនមែនភូមិជាមួយខ្ញុំទេ។ តែឃុំលាយបូរដូចគ្នា តែគាត់នៅជិតថ្នល់រទេះភ្លើង។ អាហ្នឹងកំណើតគាត់ ហើយបានគាត់មកការជាមួយម្ដាយខ្ញុំ បាននៅៗនឹងភូមិដែលខ្ញុំរស់នៅសព្វថ្ងៃ។

**ស៖** លោកស្រី គឹមឡូន ចុះម្ដាយរបស់លោកស្រី តើគាត់កើតនៅឃុំលាយបូរដែរ ហើយគាត់រស់នៅរហូតដល់ធំដឹងក្ដីនៅទីនោះដែរឬ?

**ឆ៖** ចាស ម្ដាយខ្ញុំក៏កើតនៅឃុំលាយបូរដែរ កើតនៅឃុំលាយបូរ ឪពុកក៏នៅឃុំលាយបូរ តែ

ភូមិខុសគ្នា។

**ស៖** ចុះឪពុកម្ដាយលោកស្រីគាត់មានបងប្អូនបង្កើតរបស់គាត់រស់នៅឃុំលាយបូរដែរឬ?

**ឆ៖** បងប្អូនគាត់រស់នៅឃុំលាយបូរដែរ រស់នៅទាំងអស់ តែឥឡូវស្លាប់អស់ហើយអត់សល់មួយទេ។ ទាំងពីម្ដាយខ្ញុំគាត់ស្លាប់តាំងពី៨៦–តាំងពីឆ្នាំ១៩៨៦ ស្លាប់អស់ហើយ។ ម្ដាយខ្ញុំទើបតែស្លាប់ឆ្នាំ២០០១ ឪពុកខ្ញុំស្លាប់១៩៨៦ ចាស។

[១០:៤២:២៥]

**ស៖** តើបងប្អូនរបស់ឪពុក និងម្ដាយលោកស្រីរស់នៅ<ឃុំ>ហ្នឹងជាមួយគ្នាឬក្នុងពេលដែលលោកស្រីរស់នៅឯលាយបូរហ្នឹងដែរនោះ?

**ឆ៖** កាលពីសង្គមរាស្ត្រនិយម គឺរស់នៅក្នុងភូមិហ្នឹងទាំងអស់។ ដល់ពេលសង្គម លន់ នល់ បែកៗគ្នាអស់ហើយ។ អ្នកខ្លះគេរត់ទៅខាងព្រៃមូលដ្ឋាន តែខាងខ្ញុំ សង្គម លន់ នល់ ខ្ញុំរត់ចូលទីក្រុង តាកែវ។ ដល់រត់ចូលទីក្រុងតាកែវ ចេញពីតាកែវចូលភ្នំពេញចាស។

**ស៖** នៅពេលលោកស្រីបានរៀបការនៅអាយុ១៩ឆ្នាំ តើលោកស្រីចាំបានទេថា មានបងប្អូនជីដូនមួយ ក្មួយប្រុស ក្មួយស្រី ពីខាងឃុំលាយបូរហ្នឹងទៅចូលរួមក្នុងពិធីការលោកស្រីដែរទេ?

**ឆ៖** អត់ទេ ព្រោះអីមានសុទ្ធតែភ្ញៀវនៅភ្នំពេញ។ អត់មានភ្ញៀវទៅ មានតែចាស់ៗ។ ចាស់ៗខ្លះជាបងប្អូនសាច់ញាតិ ចាស់ៗទៅមួយចំនួន តែភ្ញៀវហូប គឺភ្ញៀវភ្នំពេញ។

**ស៖** ចុះប្ដីលោកស្រីវិញ លោកស្រី គីមឡូន តើប្ដីលោកស្រី<ឈ្មោះសួស ខឹម>កើតនៅភូមិលាយបូរហ្នឹងដែរឬ?

**ឆ៖** ប្ដីខ្ញុំស្រុកកំណើតនៅជាមួយគ្នា ឃុំលាយបូរដូចគ្នា។ ជាប់សាច់ញាតិដែរ។

**ស៖** តើលោកស្រីដឹងថាប្ដីលោកស្រី គាត់រស់នៅធំដឹងក្ដីនៅឯលាយបូរហ្នឹងដែរ រហូតដល់ពេលជួបលោកស្រី ឬយ៉ាងម៉េច?

[១០:៤៤:៤៤]

**ឆ៖** គាត់រៀនៗហើយ គាត់ធ្វើការនៅ -- ពីដំបូងគាត់ធ្វើការនៅកំពង់ឆ្នាំង ហើយបានគាត់ធ្វើការនៅភ្នំពេញ។ ចាស សង្គមលន់ នល់ហ្នឹងមកធ្វើការភ្នំពេញ។

**ស៖** តើត្រឹមត្រូវទេដែលថា លោកស្រី និងប្ដីលោកស្រីមករស់នៅភ្នំពេញនៅឆ្នាំ១៩៧២ ឬ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** បើសង្ខេបមកវិញ តើវាត្រឹមត្រូវទេ វាសុក្រឹតទេបើសិនណាជាខ្ញុំនិយាយថា លោកស្រី និងប្តីរបស់លោកស្រីរស់នៅលាយបូរ ភូមិលាយបូរ រហូតដល់ឆ្នាំ១៩៧២ ពេលដែលលោកស្រីមករស់នៅភ្នំពេញ។ ត្រឹមត្រូវទេ?

**ឆ៖** មិនមែនទេ។ គាត់រស់នៅធ្វើការនៅកំពង់ឆ្នាំង កំពង់ស្ពឺ ហើយបានគាត់រស់នៅភ្នំពេញ។ ដល់ពេលខ្ញុំរត់មកភ្នំពេញបានរៀបការជាមួយគាត់។ ចាស ឆ្នាំ១៩៧២ ហ្នឹងបានខ្ញុំរៀបការជាមួយគាត់។ រស់បែកគ្នា គាត់ធ្វើការ ខ្ញុំនៅផ្ទះជាមួយឪពុកម្តាយ។

**ស៖** តើលោកស្រីដឹងថា ប្តីលោកស្រីពាក់ស័ក្តិ៣ ឬក៏ស័ក្តិ៤ គឺវរសេនីយ៍ឯក ឬក៏អនុសេនីយ៍ទោនេះ គឺលោកស្រីដឹងៗថាអ៊ីចឹងទេ?

**ឆ៖** ចាស ដឹង។ គាត់ពាក់ស័ក្តិ៣ ចូលដល់ស័ក្តិ៤ បែកភ្នំពេញតែម្តង។

**ស៖** អ៊ីចឹងនៅខែមេសា ឆ្នាំ១៩៧៥ នៅពេលលោកស្រី និងប្តីលោកស្រី ជាមួយនឹងឪពុកម្តាយបងប្អូនប្រុសស្រីត្រឡប់មកភូមិកំណើតនេះ គឺថាគាត់ពាក់ស័ក្តិ៤ ត្រឹមត្រូវទេ? គាត់គឺជា<>វរសេនីយ៍<ត្រី>?

[១០:៤៧:៣០]

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** រឿងដែលខ្ញុំសួរពាក់ព័ន្ធទៅនឹងបុណ្យស័ក្តិនេះ គឺខ្ញុំព្យាយាម<យល់>អំពីមុខងារតួនាទីរបស់ប្តីលោកស្រី និងសមាជិកក្នុងគ្រួសារ។ លោកស្រីបាននិយាយជាច្រើនលើកច្រើនសាថាលោកស្រីត្រូវបានគេចាត់ទុកថាជាប្រជាជនថ្មី ដោយសារលោកស្រីជាអ្នកដែលចេញពីភ្នំពេញនៅ<ថ្ងៃ១៧>ខែមេសា ១៩៧៥។ ហើយម្យ៉ាងវិញ គឺថាលោកស្រី និងសមាជិកក្រុមគ្រួសារទាំងអស់បានត្រឡប់មកកាន់ភូមិកំណើតដែលលោកស្រីបានធំដឹងក្តីនៅទីនោះ។ តើ<ធ្វើម៉េចទើប>ប្រជាជនដទៃដឹងថាលោកស្រីជាប្រជាជនថ្មី មិនមែនជាប្រជាជនមូលដ្ឋាន<ដែលបានរស់នៅទីនោះមួយជីវិតហើយនោះ>?

**ឆ៖** ចាស ដឹងទាំងអស់ៗគ្នា។

**ស៖** ប៉ុន្តែក្រុមគ្រួសារ<លោកស្រី>រស់នៅ<ភូមិ>លាយបូរ លោកស្រីធំដឹងក្តីនៅទីនោះ <ខ្ញុំជឿថា លោកស្រីស្គាល់មនុស្សជាច្រើន ដូចជាអតីតមិត្ត>រៀនថ្នាក់ជាមួយលោកស្រី មិត្តភក្តិប្រុសស្រី តើប្រជាជនទាំងនោះ<>គេចាត់ទុក<>លោកស្រីគឺជាអ្នកថ្មី និងមិនមែនជាប្រជាជនមូលដ្ឋានបានដោយរបៀបណា?

[១០:៤៩:២៤]

**ឆ៖** គេដឹងយើងរស់នៅភ្នំពេញ ហើយយើងរស់នៅក្នុងទីក្រុងខេត្តតាកែវ គេដឹងថា យើងអ្នកថ្មី អ្នក១៧។ បើយើងរត់ចូលព្រៃ អាហ្នឹងអ្នក១៨។ យើងរត់ចូលក្រុង ចាស។

**ស៖** <ប៉ុន្តែលោកស្រីអត់មានអត្តសញ្ញាណប័ណ្ណ ដែលបញ្ជាក់ថា លោកស្រីជាប្រជាជនថ្មី ឬ លោកស្រីមិនមានអ្វីសម្គាល់ថា ជាប្រជាជនថ្មីទេ។ ដូច្នេះសំណួររបស់ខ្ញុំគឺថា តើគេអនុវត្តយ៉ាងម៉េចទៅ? តើអ្នកទទួលខុសត្រូវគេអាចដឹងយ៉ាងម៉េចបាន?>

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ អត់មាន -- អត់មានបកប្រែភាសាទេ មន្ត្រីតុលាការសម្របសម្រួលជាមួយអង្គភាពបកប្រែភាសា។

*(សម្រាករយៈពេលខ្លី)*

[១០:៥០:៥២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តលោក វ៉ិចទ័រ កូប៉េ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ សំណួរខ្ញុំសួរទៅលោកស្រីអម្បាញ់មិញគឺអ៊ីចេះ នៅក្នុងការរស់នៅប្រចាំថ្ងៃ តើប្រជាជនដែលគេធ្វើការ<ឱ្យ>អាជ្ញា<ធរ>មូលដ្ឋានដឹង<>ថា លោកស្រីជាប្រជាជនថ្មី មិនមែនជាប្រជាជនចាស់ដោយរបៀបណា?

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** យើងជាប្រជាជនថ្មី គេរាយការណ៍មកតាំងពីគេបញ្ជូនយើងមកពីភូមិក្នុងខាងជើងសាលាឃុំលាយបូរ គេបញ្ជូនមកកង៣។ បញ្ជូនខ្ញុំចេញមកកង៣ ហ្នឹង គេរាយការណ៍ប្រាប់ហើយ ព្រោះយើងវាចំណាប់ខ្មាំងដែលគេទើបតែយកប្តីទៅរៀនសូត្រ រៀនសូត្របាត់។ ហើយអ្នកទាំងអស់នោះ ក៏គេតាមដានអង្កេតថាយើងជាអ្នកថ្មី។ តែអ្នកថ្មីមានច្រើន មិនមែនតែខ្ញុំមួយគ្រួសារទេ នៅកង៣ហ្នឹងច្រើន។

**ស៖** ឧទាហរណ៍ថា លោកស្រីធ្វើដំណើរនៅភូមិលាយបូរ ហើយគឺមានអ្នកណាគេសួរថា លោកស្រីជាអ្នកណា? លោកស្រីថា ជាអ្នកភូមិលាយបូរ ធ្លាប់រស់នៅទីហ្នឹង ធំដឹងក្តីនៅទីនោះ <ធ្លាប់ទៅរៀននៅទីនោះ ហើយគ្រួសារលោកស្រីរស់នៅទីនោះ>។ បើលោកស្រីប្រាប់អ៊ីចឹង <> តើធ្វើម៉េច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាន<ជា>រដ្ឋអំណាចមូលដ្ឋានហ្នឹង<នៅតែចាត់ទុកថា>លោកស្រីជាប្រជាជនថ្មី?

**ឆ៖** អ្នកដែលនៅក្បែរសាលាឃុំទាំងអស់ គេស្គាល់ឪពុកខ្ញុំទាំងអស់។ អ្នកមូលដ្ឋាន អ្នក១៨ អ្នកចាស់ហ្នឹង គេស្គាល់ទាំងអស់។ ដល់ឪពុកខ្ញុំ ជូ ទឹម អត់មានលាក់ប្រវត្តិរូបបានទេ ស្គាល់ទាំងអស់ ចាស។ គាត់រស់នៅភ្នំពេញជាមួយកូន គាត់រត់ពីតាកែវទៅ។

[១០:៥៣:១២]

**ស៖** បាទ ខ្ញុំសូមបន្តទៅសំណួរទាក់ទងទៅនឹងមរណភាពកូនស្រីរបស់លោកស្រី។ តើលោកស្រីចាំបានទេថា ក្រោយ<ថ្ងៃ១៧>ខែមេសា<>ហ្នឹង គឺថាកូនស្រីលោកស្រីស្លាប់នៅពេលណា?

**ឆ៖** ឆ្នាំ១៩៧៦ ចាស។

**ស៖** តើលោកស្រីចាំទេ ពេលដែលកូនស្រីលោកស្រីស្លាប់ទៅហ្នឹង គឺថាគេមានអាយុប៉ុន្មានដែរ?

**ឆ៖** អាយុចូលបីឆ្នាំហើយ ចាសបីឆ្នាំ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកស្រីបានផ្តល់សក្ខីកម្មថាកូនស្រីរបស់លោកស្រី គឺថាស្លាប់ដោយសារតែការអត់អាហារ គឺមិនមែនដោយសារតែជំងឺទេ។ ត្រឹមត្រូវទេ?

**ឆ៖** ចាស ដោយសារអត់អាហារ។ អត់អាហារហ្នឹងធ្វើឲ្យឈឺ អត់អាហារអត់មានអីហូបឆ្អែត ធ្វើឲ្យឈឺ ហើយទើបស្លាប់។

**ស៖** បាទ វាជារឿងមួយដែលគួរឲ្យសោកសង្រេងណាស់លោកស្រី។ ប៉ុន្តែខ្ញុំព្យាយាមស្វែងយល់ ថាតើហេតុអីបានជាលោកស្រីមិនអាចរកចំណីអាហារណាបាននៅក្នុងតំបន់នុ៎ង គឺនៅក្នុងតំបន់ដែលកើតហើយធំដឹងក្តីស្គាល់អ្នកភូមិ អ្នកស្រុកជាច្រើន ហើយមិនអាចស្វែងរកចំណីអាហារណាបាននោះ? តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបន្តិចបានទេ ម៉េចបានជាលោកស្រីមិនអាចរកចំណីអាហារដើម្បី<>ឲ្យកូនស្រីរបស់លោកស្រីអាយុបីឆ្នាំនុ៎ង វាៗមានហូបចុករស់រៀនមានជីវិតបាន?

[១០:៥៥:២៦]

**ឆ៖** ១៩៧៦ គឺយើងមិនអាចរកអាហារក្រៅបានទេ។ គឺអត់ អស់លទ្ធភាព ហើយឈឺទៅវាអត់អាហារដូចថា មុនដំបូងកើតកញ្ជ្រឹលអីចឹងលាប់ ១កញ្ជ្រឹលអីចឹងអាចទៅជាឈឺ ១ហើយជ្រុះសក់ៗ ហើយទើបយើងយកទៅពេទ្យទៅស្លាប់។ អត់មានថ្នាំព្យាបាលចាស ដើមមកពីអត់អាហារហ្នឹងតែម្តង ពីព្រោះវារើសដីហូប វារើសសម្បកក្តាមហូប ចាស។

**ស៖** ប៉ុន្តែលោកស្រីនិយាយថា កូនស្រីរបស់លោកស្រីហ្នឹងគឺឃ្លានចំណីអាហារ <ពេលលោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រីឃើញអ៊ីចឹង> តើ<>លោកស្រី<មិនបានព្យាយាមសុំអាហារពីប្រជាជនដែលលោកស្រីស្គាល់នៅតំបន់នោះទេ>? ប្រហែលជាខ្ញុំគួរតែផ្អាកពីរបីនាទីសិន ដើម្បីឱ្យលោកស្រីសម្រួលអារម្មណ៍បានស្រួលបួលមកវិញ។

**ឆ៖** ចាស មានការឈឺចាប់ ឈឺចាប់និងក្តុកក្តួលក្នុងចិត្ត ចាសតែប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់អារម្មណ៍លោកស្រីថាសំណួរនេះគឺជាសំណួរមួយធ្វើឱ្យលោកស្រីមានអារម្មណ៍មិនល្អ ប៉ុន្តែខ្ញុំព្យាយាមស្វែងយល់ ថាតើកូនស្រីលោកស្រីស្លាប់ដោយសារការអត់អាហារ ឬក៏ដោយសារជំងឺកញ្ជ្រឹល ឬក៏ដោយសារបញ្ហាណាផ្សេងទៀត? អ៊ីចឹងហើយបានជាស្នើសុំ ថាតើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ <ថា>លោកស្រី<បាន>ព្យាយាមដើរសុំចំណីអាហារពីអ្នកភូមិ ឬសាច់ញាតិដែលលោកស្រីស្គាល់?

[១០:៥៧:៣៨]

**ឆ៖** ដល់ពេលឈឺអ៊ីចឹង វាហូបអីអត់កើតទេ ដល់ពេលវាលាប់អ៊ីចឹង វាហូបបាយហូបអីអត់កើតចាស ត្រូវដាច់ៗចំណីដែលយើងគ្មានរបស់អ្វីដែលជាសម្រាប់ប៉ូវ ហូបបាយអត់កើតដល់ពេលដាច់ចំណីពេលហ្នឹងចាស។ អត់មានថ្នាំពេទ្យ អត់មានអីទាំងអស់។

**ស៖** តើត្រឹមត្រូវទេបើខ្ញុំនិយាយថា ប្រសិនបើកូនស្រីរបស់លោកស្រី អាចរកចំណីអាហារ អាចមានចំណីអាហារ <>គេប្រាកដជានឹងអាចនៅរស់រៀនមានជីវិត។ បាទ ខ្ញុំសុំសួរម្តងទៀត។ <តើនាងមិនអាចហូបបាន> ដោយសារមិនមានអាហារនៅក្នុងឃុំ ឬក៏ដោយសារតែកូនស្រីរបស់លោកស្រីគេមិនអាច<>ហូបចំណីអាហារអីបាន?

**ឆ៖** ចំណីអាហារ បើទោះបីជាមាន ក៏ឈឺហើយយើងអត់មានថ្នាំ។ ជាពិសេសគឺអត់មានថ្នាំហ្នឹងតែម្តង អត់ថ្នាំព្យាបាល ម្ល៉ោះហើយគឺទៅតាមហ្នឹង គឺត្រូវស្លាប់ដោយសារអត់មានថ្នាំ និងហូបចំណីអាហារអត់ លែងកើតចាស។

**ស៖** បាទ ខ្ញុំសូមបញ្ចប់សំណួរដែលធ្វើឱ្យលោកស្រីសោកសង្រេងនេះទៅចុះ។ តើត្រឹមទេបើសិនជាខ្ញុំនិយាយថា កូនស្រីរបស់លោកស្រីស្លាប់ដោយសារកញ្ជ្រឹល <> មិនមែនដោយសារអត់អាហារទេ គឺដោយសារតែជំងឺកញ្ជ្រឹល?

**ឆ៖** គួបផ្សំជាមួយគ្នា ទាំងពីរមុខ។ អត់ចំណីអាហារហូបគ្រប់គ្រាន់ ហើយនិងមានជំងឺកើតកញ្ជ្រឹល គួបផ្សំជាមួយគ្នានិងអត់ថ្នាំពេទ្យបូករួមបញ្ចូលគ្នា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៥៩:៥៩]

**ស៖** ចុះកូនផ្សេងៗទៀត លោកស្រី គឹមឡូន តើអ្នកផ្សេងទៀត គេមានអាហារ មានអ្វីហូបដែរទេ?

**ឆ៖** កូនផ្សេងទៀត គេទៅកង។ គេនៅកង តែខ្ញុំនៅភូមិ ចំណែកអាហារ គឺមិនមានគ្រប់គ្រាន់ដូចតែគ្នានៅកងកុមារ អត់មានចំណីអាហារគ្រប់គ្រាន់ទេ។

**ស៖** ខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេងទៀត លោកស្រី គឹមឡូន គឺនិយាយពីការចាប់ខ្លួនប្ដីរបស់លោកស្រី។ លោកស្រីបានផ្ដល់សក្ខីកម្មពីខាងដើមអំពីហេតុការណ៍នោះមួយចំនួនហើយ ខ្ញុំមិនទាន់យល់ច្បាស់ទេថា តើកាលបរិច្ឆេទណាមួយដែលគេយកគាត់ចេញទៅនោះ<>?

**ឆ៖** ចាស ខ្ញុំចាំ រឿងគាត់យកទៅ -- គេយកគាត់ទៅនៅពេលយប់ម៉ោងប្រាំបួន ឆ្នាំ១៩៧៥។ ៧៥ គាត់ចុះមកបានប្រហែលបីបួនខែហ្នឹង គេយកគាត់ពេលយប់ម៉ោងប្រាំបួន–ប្រាំបួនយប់។

[១១:០១:៣៥]

**ស៖** ដូច្នេះ គឺអាចក្នុងខែសីហា ឆ្នាំ១៩៧៥ តើអាចជាការបរិច្ឆេទត្រឹមត្រូវទេ?

**ឆ៖** ចាស វាត្រឹមត្រូវហើយ ខែ៨ ព្រោះគេគ្រាន់តែយកគាត់ទៅ គេបញ្ជូនខ្ញុំទៅនៅកង៣ គេចាប់ផ្ដើមស្ទូងដាំស្រូវ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថាគេយកគាត់ទៅក-៣?

**ឆ៖** កង៣ មិនមែន “ក” ទេ។ កង៣ ហ្នឹងជាកងឈ្មោះភូមិដែលយើងនៅនោះ។ យើងនៅហ្នឹងជិតខាងត្បូងសាលាឃុំ ខាងជើងវត្តវិហារខ្ពស់ហ្នឹង គេហៅ “កង៣”។ ពីខាងលិចនុ៎ងទៀត កង៤។ គេមានកង អត់មានហៅភូមិទេ។ គេហៅ កង៣, កង៤, កង២, កង១ អ៊ីចឹង ។

**ស៖** ប្រហែលជាដោយសារការបកប្រែ ឬក៏ខ្ញុំយល់មិនត្រូវ គឺថាពេលដែលគេយកប្ដីរបស់លោកស្រីទៅ គឺថាគេយកទៅ ក-៣។ តើ ក-៣ ឬក៏កន្លែងណា? សូមលោកស្រីបញ្ជាក់។

**ឆ៖** គេយកប្ដីខ្ញុំទៅរៀនសូត្រ យកទៅសម្លាប់ អត់មានយកទៅកង៣ទេ គេយកទៅសម្លាប់។ យកទៅសម្លាប់នៅខាងលិចវត្តលាយបូរ គេសម្លាប់ហើយបានគេបញ្ជូនខ្ញុំទៅនៅ កង៣។

**ស៖** នៅក្នុងចម្លើយរបស់លោកស្រី គឺថា <E3/5635 ERN 00678302> និយាយអំពីប្រវត្តិរបស់លោកស្រីនោះ គេចាប់ប្ដីរបស់លោកស្រី ហើយគេបញ្ជូនទៅអប់រំកែប្រែ។ តើលោកស្រីចង់និយាយថាដូចម្ដេចនៅពេលដែលឆ្លើយដូចខាងដើមនេះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គេចាប់អប់រំកែប្រែមិនមែនជាការពិតទេ គឺគេចាប់គាត់ទៅ គេចង។ យកខ្សែគោចងស្លាបសេកគាត់ ហើយគេបណ្ដើរគាត់ទៅ ហើយបងៗគាត់ទាំងអស់លបមើលឃើញទាំងអស់ តែអត់ប៉ាន់ទេ ម្ដាយគាត់ក៏លបឃើញដែរ ព្រោះម្ដាយគាត់បងគាត់ជាអ្នក១៨ ជាអ្នកចាស់។ អត់ប៉ាន់ធ្វើអ្វីទាំងអស់។

**ស៖** តើពិតប្រាកដនោះ គេប្រាប់លោកស្រីថាពួកគាត់បានឃើញអ្វីឲ្យច្បាស់នោះ?

[១១:០៤:៥៧]

**ឆ៖** ពួកគាត់អ្នកមូលដ្ឋាន គាត់អ្នកចេះ អ្នកមូលដ្ឋាន អ្នក១៨។ គាត់ប្រាប់ខ្ញុំថា គេសម្លាប់ហើយ។ គេសម្លាប់ប្ដីខ្ញុំហើយ គេយកទៅសម្លាប់ហើយ ចងស្លាបសេក ស្ពាយកាំភ្លើងបណ្ដើរយកទៅហើយ។ ហើយគាត់យំមួយយប់ទល់ភ្លឺ ទាំងខ្ញុំទាំងគាត់។

**ស៖** សូមអភ័យទោសលោកស្រី គឺមឡូន គឺមានចំណុចមួយដែលខ្ញុំមិនទាន់យល់។ លោកស្រីនិយាយថា ពួកគាត់ហ្នឹងដឹង ដោយសារពួកគាត់ជាអ្នកមូលដ្ឋាន។ បើតាមពិនិត្យទៅលោកស្រីមិនជាអ្នកមូលដ្ឋានទេ ប៉ុន្តែមានស្រុកកំណើតនៅហ្នឹង វាប្រហាក់ប្រហែលនឹងដូចអ្នកមូលដ្ឋានទេ។ អ៊ីចឹង សូមពន្យល់តុលាការមើល៍ថាហេតុអីបានជាពួកគាត់ដឹង បែរជាលោកស្រីមិនបានដឹងដោយខ្លួនឯងផ្ទាល់ទៅវិញ?

**ឆ៖** ខ្ញុំជាអ្នកថ្មី ទើបតែចេញទៅពីភ្នំពេញ អត់មានដឹងពាក្យថា "គេយកទៅរៀនសូត្រ"ហ្នឹងរបៀបម៉េចទេ ព្រោះគាត់នៅហ្នឹងយូរហើយ គាត់អ្នកមូលដ្ឋានគាត់ដឹងទាំងអស់។ ពាក្យ "យកទៅរៀនសូត្រ" ហ្នឹងគឺ "យកទៅសម្លាប់"។ យកទៅរៀនសូត្រ យកទៅសម្លាប់ បើទោសធ្ងន់គេអាចសម្លាប់នៅក្បែរៗហ្នឹង បើទោសរៀងស្រាលគេយកទៅដាក់នៅមន្ទីរឃុំឃាំងណាមួយដែលយើងមិនអាចដឹងនៅបង្ខំកៗការងារនិងពលកម្ម ដល់ថ្ងៃក្រោយបានគេកម្ទេចជាក្រោយ។ ហ្នឹងអ្នកដែលតូចៗ បើអ្នកដែលមានបុណ្យស័ក្តិធំ ដូចប្ដីខ្ញុំគឺគេកម្ទេចចោលនៅជិតៗហ្នឹង អត់បានយកទៅរៀនសូត្រឆ្ងាយទេ។ អ្នកចាស់ប្រាប់ខ្ញុំ អ្នកម្ដាយគាត់ បងប្អូនគាត់។

**ស៖** តើមាននរណាម្នាក់ប្រាប់លោកស្រីថា ពួកគាត់ ឬគាត់ណាម្នាក់បានឃើញដោយផ្ទាល់ភ្នែកពីរឿងសម្លាប់ប្ដីរបស់លោកស្រីថា គេសម្លាប់ហ្នឹងគេឃើញផ្ទាល់ភ្នែក។ មាននរណាប្រាប់ផ្ទាល់អ៊ីចឹងមកលោកស្រីទេ?

[១១:០៧:៣៥]

**ឆ៖** គេប្រាប់ខ្ញុំផ្ទាល់ ដល់ពេលបែក១៧ មេសា ៧៩ បានគេប្រាប់។ គេប្រាប់ខ្ញុំថា គេសម្លាប់ប្ដី

ខ្ញុំនៅខាងលិចវត្តបូរ។ អាហ្នឹងកូន -- ឪពុកវាប្រាប់កូន កូនគេយកប្រាប់ខ្ញុំ។ គេថានោះសម្លាប់បង នួន នៅនោះ នៅព្រៃ ព្រៃដើមឈើទាលគុម្ពឫស្សី។ បានខ្ញុំដឹង ព្រោះសង្គមនោះអត់មានអ្នកណាហ៊ានហើប ទេ។ ដល់មកសង្គម៧៩ហ្នឹង យូរណាស់ គេទើបប្រាប់ខ្ញុំៗប្រហែលជាឆ្នាំ៩០ហើយហ្នឹង គេទើបនឹង ហ៊ានប្រាប់។ ស្លាប់ពួកហ្នឹងអស់ហើយ ស្លាប់ពួកដែលសម្លាប់ៗប្ដីខ្ញុំស្លាប់បាត់អស់ហើយ។ ហើយរត់ និរទេសចេញ អត់ហ៊ាននៅភូមិហ្នឹងទេ ព្រោះខ្លាចៗ ខ្ញុំមានបងប្អូនសងសឹក។ ចាស អត់មានហ៊ាននៅ កន្លែងឃុំលាយបូរហ្នឹងទេ រត់ទៅនៅបាត់ដំបង នៅមោងអីណានោះ។ ប៉ុន្តែខ្ញុំអត់មានហ៊ានសងសឹកទេ ព្រោះជាតិសាសន៍ខ្ញុំជាខ្មែរ អ្នកស្រឡាញ់ខ្មែរដូចគ្នា អត់មានទៅសងសឹក កាប់សម្លាប់គាត់។ ដឹងថា សម្លាប់ប្តីយើងហើយ ខ្ញុំអត់មានហ៊ានសងសឹកទេ ខ្ញុំខ្លាចបាប។

**ស៖** តើនៅពេលណា នៅក្នុងឆ្នាំ១៩៧៩ ដែលគេប្រាប់លោកស្រីថា គេសម្លាប់ប្តីលោកស្រីនោះ បាទ?

**ឆ៖** យូរ គេទើបនឹងប្រាប់តើ។ ៧៩នេះ គេអត់ទាន់ហ៊ានប្រាប់ទេ ដល់មកឥឡូវនេះ ទើប ប្រហែល១៩៨៩ ហើយក៏ ១៩៩០អីនេះ គេទើបប្រាប់ៗឥឡូវៗហ្នឹង គេចេញបាត់អស់ហើយអ្នកសម្លាប់ ប្តីខ្ញុំ។

[១១:០៩:៥៥]

**ស៖** កាលពីម្សិលមិញ តាមខ្ញុំយល់បើមិនខុសទេ លោកស្រី គឹមឡន លោកស្រីបានប្រាប់ តុលាការថា "បន្ទាប់ពីគេយកប្តីលោកស្រីចេញពីផ្ទះទៅ លោកស្រីបានឮគេបាញ់បីគ្រាប់កាំភ្លើង" ឬក៏ខ្ញុំ អាចយល់ច្រឡំ។ ប៉ុន្តែខ្ញុំយល់ថាលោកស្រីចង់បញ្ជាក់ប្រាប់តុលាការថា ក្រោយពីគេយកប្តីលោកស្រីទៅ ឮបីគ្រាប់ គឺគេសម្លាប់នៅពេលនោះតែម្តង។ អ៊ីចឹង ថាតើសក្ខីកម្មរបស់លោកស្រីហ្នឹង -- ខ្ញុំសួរសំណួរ តើចម្លើយរបស់លោកស្រីយ៉ាងដូចម្តេច អំពីហេតុការណ៍ទាក់ទងទៅនឹងការសម្លាប់ប្តីរបស់លោកស្រី ហ្នឹង សូមបញ្ជាក់ប្រាប់ខ្ញុំឱ្យច្បាស់បាទ?

**ឆ៖** ហេតុការណ៍ដែលដឹងថាសម្លាប់ហ្នឹង បាញ់បីគ្រាប់ហ្នឹង ព្រោះកាលយកចេញពីខ្ញុំទៅ ខ្ញុំ បានឃើញ។ ឃើញគាត់ស្ពាយកាំភ្លើងមួយដើម ហើយនិងពីរនាក់ទៀតដើរទទេ។ ហើយចេញទៅ គាត់ អត់ទាន់ចងទេ បណ្តើរទៅ គាត់កៀកជាប់ហ្នឹង ហើយកាំភ្លើងមួយដើមស្ពាយ។ ហើយទៅដល់ដើមដូង ជិតផ្ទះបងគាត់ និងម៉ែគាត់ គេស្រាយខ្សែគោនៅដើមដូងហ្នឹង ចងស្លាបសេក បងៗគាត់និងម្តាយគាត់ ឃើញគាត់ យំរហូតដល់ទន់ខ្លួន ស្លាប់បាត់ឆ្នាំ៧៦ គាត់ស្លាប់។

[១១:១១:៤៣]

**ស៖** ដើម្បីបញ្ចប់សំណួរមួយចំនួននេះថា តើត្រឹមត្រូវទេ បើខ្ញុំសង្ខេបថា សូរកាំភ្លើងបីគ្រាប់ដែលលោកស្រីបានឮហ្នឹង គឺវាមិនទាក់ទងអ្វីទៅនឹងការសម្លាប់ប្ដីរបស់លោកស្រីទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ទាក់ទងនឹងការសម្លាប់ ព្រោះកាំភ្លើងស្ពាយទៅមួយដើម ហើយសម្លាប់ហ្នឹងមិនមែនតែបាញ់តែកាំភ្លើងទេ មានរ៉ៃនឹងត្បូងចបទៀត គេអ្នកមូលដ្ឋានប្រាប់ខ្ញុំ។ យកចបទៅឲ្យជីករណ្ដៅទៀត។

**ស៖** ប្រសិនបើវាអ៊ីចឹងមែន លោកស្រី គឹមឡូន តើត្រូវដែរឬទេ ខ្ញុំប្រាប់ថា លោកស្រីបានឮពីរឿងសម្លាប់ប្ដីរបស់លោកស្រីនេះ គឺថានៅក្នុងខែ៨ ឆ្នាំ១៩៧៥ ឬក៏ហេតុការណ៍ហ្នឹង កើតនៅថ្ងៃនុំងបាទ?

**ឆ៖** ចាស កើតនៅថ្ងៃហ្នឹង ១៩៧៥ ខ្ញុំនៅកំព្រារហូតដល់សព្វថ្ងៃ។

**ស៖** ខ្ញុំនឹងបន្តទៅប្រធានបទមួយទៀត លោកស្រី គឹមឡូន។ និយាយអំពីទស្សនកិច្ចរបស់ថ្នាក់លើដែលលោកស្រីផ្ដល់សក្ខីកម្មជម្រាបតុលាការខាងដើមនេះ។ ខ្ញុំមានសំណួរពីរបីបន្តពីសំណួរកាលមុនៗ។ អ៊ីចឹងសួរថា តើប្រធានកងនិយាយប្រាប់លោកស្រីដោយប្រើពាក្យអ្វីខ្លះ? ពន្យល់ថាអ្វីខ្លះដែលថាក្នុងចំណោមកម្មាភិបាលដែលមកហ្នឹង គេប្រាប់ថាដូចម្ដេចបានលោកស្រីច្បាស់ថាគាត់ជា នួនជា នោះ?

[១១:១៣:៥៥]

**ឆ៖** គេប្រាប់យើងថា អង្គការថ្នាក់លើ កម្មាភិបាលនៅ -- អ្នកដឹកនាំប្រទេសកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម។ គាត់មកពីភ្នំពេញ គាត់ជាអ្នកមេដឹកនាំជាន់ខ្ពស់ គាត់ចុះមូលដ្ឋាន។ ហើយយើងទាំងអស់គ្នា គឺធ្វើការអត់មានរើសមុខសញ្ញា គឺយើងអត់មានត្អូញត្អែរ យើងគឺសម្រុកការងារ។

**ស៖** តើប្រធានកងនោះ ប្រាប់ពីមុខងារ ឬក៏តំណែងរបស់ថ្នាក់លើដែលមកហ្នឹងទេ តើគាត់មានតួនាទីអី? តំណែងអ្វីទេ?

**ឆ៖** ចាស គាត់ប្រាប់ គាត់តួនាទីគាត់ជាអ្នកដឹកនាំនៅប្រទេសកម្ពុជាប្រជាធិបតេយ្យរបស់សង្គមខ្មែរក្រហម។

**ស៖** ថាតើប្រធានកងលោកស្រីប្រាប់ថា ជាមុខតំណែងអ្វីនៅក្នុងរដ្ឋាភិបាលថាជាមេដឹកនាំហ្នឹងគឺមុខតំណែងអីនៅក្នុងរដ្ឋាភិបាល ឬក៏ក្នុងស្ថាប័នអ្វី?

**ឆ៖** មុខតំណែងជាអ្នកដឹកនាំនៅប្រទេសកម្ពុជាទាំងមូល គឺប្រធានកង គេប្រាប់អ៊ីចឹងថាគាត់ទាំងបីនាក់ហ្នឹងជាអ្នកដឹកនាំនៅប្រទេសកម្ពុជាប្រជាធិបតេយ្យសង្គមរបបខ្មែរក្រហម អ្នកដឹកនាំជាន់ខ្ព

ស់។ គេធ្វើការរាល់ថ្ងៃតាមអង្គការបក្សដាក់មក ដាក់ចុះមកតាមលំដាប់ថ្នាក់។

**ស៖** លោកស្រី គឹមឡូន ប៉ុន្តែឥឡូវនេះ គឺថាយើងនៅប្រទេសកម្ពុជា ដូចយើងមាននាយក រដ្ឋមន្ត្រី ប្រធានព្រឹទ្ធសភា ហើយនិងរដ្ឋមន្ត្រីក្រសួងការបរទេស។ អ៊ីចឹងត្រឡប់ទៅសម័យកម្ពុជាប្រជាធិបតេយ្យវិញ ថាតើមេកងហ្នឹងបានបញ្ជាក់ថានៅក្នុងចំណោមថ្នាក់ដឹកនាំថ្នាក់លើហ្នឹង អ្នកណាកាន់អី មុខតំណែងអីទេ?

**ឆ៖** គេអត់បានបញ្ជាក់ថាអ្នកណាកាន់មុខតំណែងអីទេ។ គេគ្រាន់តែប្រាប់យើងថាមេដឹកនាំកម្ពុជា អ្នកដឹកនាំប្រទេសកម្ពុជាទាំងមូល គឺស្មើនឹងសម្តេចឪ។ ថាអ្នកណាជាកាន់អី គេអត់បានបញ្ជាក់ប្រាប់យើង។

[១១:១៦:៣៧]

**ស៖** តើលោក<ស្រី>នៅចាំ<ឈ្មោះមនុស្ស> ដែលមេកង<ធ្លាប់>ប្រាប់លោកស្រី<ថា មេដឹកនាំនេះគឺជា នួន ជា>?

**ឆ៖** ប្រាប់លោក ប៉ុល ពតៗ និង ខៀវ សំផន, នួន ជា។ ចាស គាត់ប្រាប់ប៉ុណ្ណឹង។

**ស៖** អ៊ីចឹងប្រធានកងនោះបានប្រើពាក្យដោយផ្ទាល់មាត់គាត់ថា នួន ជា អ៊ីចឹងទេ?

**ឆ៖** ចាស។

**ស៖** លោកស្រី គឹមឡូន តើលោកស្រីស្គាល់ វន វ៉េត ដែរឬទេ?

**ឆ៖** អត់ ចាស អត់បានស្គាល់ទេព្រោះអ្នកជំនាន់ក្រោយ ខ្ញុំអត់ដែលឃើញអត់បានស្គាល់ទេ។

**ស៖** តើលោកស្រីធ្លាប់ស្គាល់ឈ្មោះ សុន សេន ដែរឬទេ?

**ឆ៖** ចាស ធ្លាប់ឮ ធ្លាប់ស្គាល់។ ស្គាល់យើងស្គាល់ទើបស្គាល់មកយើងបែកហើយនេះទេ។ ស្គាល់សង្គមឥឡូវ។

**ស៖** តើលោកស្រីធ្លាប់ឮឈ្មោះ សោ ភឹម ស្គាល់ទេ?

**ឆ៖** ឮឈ្មោះឥឡូវៗនេះ ហ្នឹងពីមុនអត់ស្គាល់ទេ។ ស្គាល់តែគាត់បីនាក់ ស្គាល់ពីមុន។

**ស៖** តើលោកស្រីនៅចាំ<ទេ ពេល>ដែលគេប្រកាសថា ប៉ុល ពត, នួន ជា ជាអ្នកគ្រប់គ្រងប្រទេសកម្ពុជា មិនមែនអង្គការ<>?

**ឆ៖** អ្នកមូលដ្ឋានទាំងអស់ គេដឹងទាំងអស់។ គេថាលោក ប៉ុល ពត, នួន ជា, ខៀវ សំផន ហ្នឹង ជាអ្នកដឹកនាំប្រទេសកម្ពុជា ជាអ្នកអំណាចក្តោបក្តាប់លើកិច្ចការអ្វីៗទាំងអស់ ដែលដាក់ផែនការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឲ្យថ្នាក់ក្រោមៗ គាត់ជាមេបញ្ជាការសម្រាប់ដាក់ផែនការឲ្យកូនចៅតូចៗ។

[១១:១៩:៣៨]

**ស៖** លោកស្រី គឹមឡួន នេះជាចំណុចសំខាន់ណាស់ ពេលដែលលោកស្រីផ្តល់សក្ខីកម្មប្រាប់តុលាការអំពីអ្វីៗដែលលោកស្រីចងចាំកាលពីនោះមក។ គឺមិនផ្តែកទៅលើអ្វីដែលលោកស្រីបានឮក្រោយពីឆ្នាំ១៩៧៩ទេ។ តើលោកស្រីអាចនឹកឃើញអ្វីដែលលោកស្រីចងចាំតាំងពីឆ្នាំ១៩៧៧ដែរឬទេ? <តើលោកស្រីនៅចាំ>ព្រឹត្តិការណ៍នៅក្នុងឆ្នាំ<នោះទេ ដែលគេបានដឹងថា មិនមែនអង្គការជាអ្នកគ្រប់គ្រងប្រទេសទេ ប៉ុន្តែជាការពិតគឺ>គឺបក្សកុម្មុយនីស្តកម្ពុជា<ទៅវិញទេ>?

**ឆ៖** ចាំហើយ ចាំថា គាត់ហ្នឹងជាអង្គការអ្នកដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺគាត់ ព្រោះគេនិយាយគ្រប់មាត់ទាំងអស់។ ៧៥, ៧៧ គាត់ជាមេដឹកនាំជាន់ខ្ពស់។

**ស៖** អ៊ីចឹងសក្ខីកម្មរបស់លោកស្រីហ្នឹងគឺថា លោកស្រីបានដឹងហើយតាំងពីឆ្នាំ១៩៧៥, ១៩៧៦ ថាលោក នួន ជា ជាមេដឹកនាំ។

**ឆ៖** នួន ជា, ខៀវ សំផន, ប៉ុល ពត អាហ្នឹងថ្នាក់ៗរដ្ឋមន្ត្រី។ ដល់ពេល តាម៉ុក ថ្នាក់ខេត្ត។

**ស៖** លោកស្រី គឹមឡួន តើធ្វើឲ្យលោកស្រីភ្ញាក់ផ្អើលទេ បើខ្ញុំប្រាប់លោកស្រីថាមិនមាននរណាម្នាក់ទេ ក្នុងកម្ពុជា ឬក្នុងពិភពលោកបានដឹងថា លោក នួន ជា មានឋានៈអ្វីរហូតដល់ដើមខែវិច្ឆិកា ឆ្នាំ១៩៧៧ទេ ទើបបានគេដឹង។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ ព្រោះសំណួរហ្នឹងឲ្យសាក្សីឆ្លើយដោយស្មានៗប៉ុណ្ណោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របជាមួយលោកប្រធាន។ ខ្ញុំនឹងបន្តទៅមុខទៀត។ ប៉ុន្តែដោយមិនទាន់បញ្ចប់សំណួរចុងក្រោយទេ។

[១១:២២:៣៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរលោកស្រី ថាតើអាចទៅរួចទេ នៅពេលដែលលោកស្រីបានឃើញមេដឹកនាំនៅក្នុង <ខែកុម្ភៈ>ឆ្នាំ១៩៧៧ នោះជាមេដឹកនាំ ហើយក្រោយពីឆ្នាំ១៩៧៩ ដែលលោកស្រីគិតថា អ្នកទាំងអស់

ហ្នឹងគឺអាចជាប៉ុល ពត, នួន ជា, តាម៉ុក? <តើអាចទៅរួចទេ?>

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** ចាស ព្រោះខ្ញុំបានឃើញគាត់ចុះទៅការដ្ឋាន។ ឃើញគាត់ចុះទៅការដ្ឋានហ្នឹងខ្ញុំស្គាល់គាត់។ ហើយគឺការទាំងអស់ហ្នឹងហើយគឺគាត់ -- ខ្ញុំអាចដឹងគាត់ជាអ្នកដឹកនាំនៅរដ្ឋកម្ពុជា -- កម្ពុជាប្រជាធិបតេយ្យ។

**ស៖** សូមអរគុណ លោកស្រី គឹមឡុន។ ខ្ញុំនឹងមានសំណួរខ្លីៗមួយចំនួនទៀត។ ហើយសំណួរមួយសួរទៅលោកស្រី តើ "ក្លាយក្រោម" ហ្នឹងគឺនៅកន្លែងណា? ទីតាំងមួយឈ្មោះ "ក្លាយក្រោម"។

**ឆ៖** អត់ៗបានឮទេ កន្លែងហ្នឹងចាស។ "ស្វាយក្រម"ម៉េច អត់មានឮទេ។

**ស៖** ប្រហែលជាខ្ញុំអានមិនច្បាស់។ ខ្ញុំយោងទៅរកកថាខណ្ឌ១៤ នៃឯកសារ <E3/5635> ដែលជាចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលគាត់និយាយថា ERN 00678304 ខ្ញុំបានឃើញគេចាប់មនុស្សមួយចំនួន គេបញ្ជូនទៅ "ក្លាយក្រោម"។ <សំណួររបស់ខ្ញុំគឺ តើ "ក្លាយក្រោម" នៅឯណា?>

**ឆ៖** តើស្វាយក្រោម ហ្នឹង ជាខ្ញុំនៅខាងឃុំលាយបូរ អត់មានឮទេ ស្វាយក្រោមហ្នឹង មិនដឹងជាស្វាយក្រោមហ្នឹងនៅស្រុកកៀនស្វាយ ឬស្វាយក្រោម ឯណា ខ្ញុំមិនបានដឹងទេ។

[១១:២៥:០៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអនុញ្ញាត ខ្ញុំគិតថា <អ្នកបកប្រែភាសាខ្មែរ>អត្ថបទ E3<នៅពីមុខខ្លួនហើយ> <ក្នុង> កថាខណ្ឌ១៤ <ខ្ញុំអានក្នុងអត្ថបទជាភាសាអង់គ្លេស> "ក្ដៅក្រអឿម"បាទ។ <ប៉ុន្តែខ្ញុំមិនច្បាស់ថា តើការបកប្រែនោះ បានត្រឹមត្រូវឬទេ។>

**ប្រធានអង្គជំនុំ៖**

មេធាវីជាតិការពារក្ដីលោក នួន ជា អាចជួយបានទេ បញ្ជាក់លើភាសាខ្មែរ ទីតាំងជាភាសាខ្មែរដើម្បីឲ្យបានច្បាស់លាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយក្នុងអត្ថបទខ្មែរសរសេរថាបញ្ជូនទៅ "ក្ដៅក្រអឿម"។ បាទ គឺដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ខ្លួនឯងថា៖ "ខ្ញុំបានឃើញប្រជាជនជាច្រើនត្រូវគេចាប់ខ្លួន ហើយបញ្ជូនទៅក្ដៅក្រ<អឿ>ម"។

**ប្រធានអង្គជំនុំ៖**

មេធាវីជាតិហ្នឹងទំនងជាអានតាមភាសាអង់គ្លេសដែរ? មិនរកភាសាខ្មែរដើម្បីបញ្ជាក់ភាសាដើម យកភាសាបកប្រែអង់គ្លេសអានអ៊ីចឹងដែរ មិនច្បាស់ទេណា។ ភាសាដើមជាភាសាខ្មែរនុះសរសេរថា ម៉េចនុ៎ង? ភាសាបកប្រែនុ៎ង ខ្មែរក៏និយាយស្តាប់មិនបានដែរណា។

[១១:២៦:៥៨]

**លោក សុន អរុណ៖**

នៅក្នុងឯកសារខ្មែរ លោកប្រធានសរសេរថា "ក្តៅក្រអឿម"។

**ប្រធានអង្គជំនុំ៖**

ក្តៅក្រអឿម! អ៊ីចឹងមែនទេ? ស្គាល់ទេ?

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** ស្គាល់តែខ្លាគ្រហឹម និង ក្រាំងតាចាន់។ ខ្លាគ្រហឹម ហើយក្រាំងតាចាន់ គុកក្រាំងតាចាន់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីខ្ញុំសួរទៅលោកស្រី។ បាទ ដើមបណ្តឹងរដ្ឋប្បវេណី តើខ្លាគ្រហឹមនោះនៅកន្លែងណា?

**ឆ៖** ខ្ញុំអត់ដែលបានទៅទេ ខ្ញុំទៅតែក្រាំងតាចាន់។ នៅខ្លាគ្រហឹមហ្នឹងអត់ដែលបានទៅទេ ឮតែតាមគេថាទេ។ ក្រាំងតាចាន់ ខ្ញុំទៅញឹកញាប់។

[១១:២៨:២៦]

**ស៖** ប៉ុន្តែនៅក្នុងចម្លើយរបស់លោកស្រីនៅក្នុងកថាខណ្ឌ១៤នេះ ថា "ខ្ញុំបានឃើញប្រជាជនជាច្រើនត្រូវបានគេចាប់ខ្លួន ហើយគេបញ្ជូនទៅខ្លាគ្រហឹម"។ អ៊ីចឹង តាមដែលលោកស្រីបញ្ជាក់អំមិញ លោកស្រីមិនបានដឹងថា ខ្លាគ្រហឹមនៅឯណានោះទេ ប៉ុន្តែហេតុអីក៏អាចបញ្ជាក់ថា ឃើញគេបញ្ជូនអ្នកហ្នឹង ទៅខ្លាគ្រហឹមបាន?

**ឆ៖** ខ្ញុំអត់បានដឹងថា -- ខ្លាគ្រហឹមហ្នឹងដឹងថានៅពីខាងលិចអង្គតាសោម ប៉ុន្តែខ្ញុំអត់បានដឹងថា គេបញ្ជូនទៅនុ៎ងទេ ខ្ញុំដឹងតែថាបញ្ជូនទៅក្រាំងតាចាន់ ដោយសារអ្នកមូលដ្ឋានគេប្រាប់។ អ្នកដែលទោសបញ្ជូនទៅ គឺទៅក្រាំងតាចាន់។

**ស៖** តើលោកស្រីបានឮ<ដែរឬទេ>ថា ប្តីរបស់លោកស្រីក៏អាចគេបញ្ជូនទៅខ្លាគ្រហឹម ឬក៏

ក្រាំងតាចាន់ដែរឬទេ?

**ឆ៖** មិនៗបានទៅដល់នុងទេ ព្រោះប្តីខ្ញុំគេមានទោសថា ក្បត់នឹងអង្គការ យើងពាក់ស័ក្តិអត់ប្រាប់គេ។ គេសម្លាប់នៅហ្នឹង ព្រោះគេយកទៅមានកាំភ្លើង ហើយនិងមានចប។ ហ្នឹងពេលដែលម្តាយគាត់និងបងគាត់ប្រាប់ខ្ញុំ។ តែបើបងប្រុសខ្ញុំមួយទៀត ដែលគេចងទៅប្រហែលជាអាចទៅម្តុំហ្នឹងហើយ បងប្រុសខ្ញុំ–ហៀម ថៅហ៊ី។

**ស៖** ខ្ញុំមើលទៅដូចជាជិតដល់ម៉ោងហើយ ខ្ញុំមានសំណួរចុងក្រោយមួយ។ យើងអាចនឹងមានបញ្ហាបកប្រែ នៅបញ្ហានេះពីព្រោះថា យើងមានអត្ថបទបីខុសគ្នាដែលមានឈ្មោះខុសគ្នា ខ្ញុំយោងទៅរកឯកសារ D22/250211 (sic) ជារបាយការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ERN 00550930 ហើយដល់ 31។ នៅក្នុងឯកសារនេះ គឺថាមាន<>ប្រអប់ដែលនិយាយថា <“>ព្យសនកម្ម<ដែលបានចោទប្រកាន់” ហើយអត្ថបទជាភាសាអង់គ្លេស> គឺថា <“អ្នកដាក់ពាក្យសុំមានជំងឺផ្លូវចិត្ត> ដោយសារ <ការបាត់បង់>ប្តីរបស់គាត់ ហើយគាត់បានពិការដៃដោយសារធ្វើការនៅក្នុង<របបខ្មែរក្រហម”> គឺថានៅក្នុងអត្ថបទខ្មែរនិយាយថាដូចជាគាត់កំបុតម្រាមដៃ<> ប៉ុន្តែភាសាបារាំងដូចជាដាក់ថា គាត់កំបុតដៃឬក៏បាត់ដៃ។ តើហេតុការណ៍ដែលកើតមានឡើងចំពោះលោកស្រីលើរាងកាយ ឬក៏ម្រាមដៃ ប្រអប់ដៃ ឬក៏ពិការដៃម្ខាងយ៉ាងដូចម្តេច? សូមលោកស្រីពន្យល់ប្រាប់តុលាការ។

[១១:៣១:៥៧]

**ឆ៖** ចាស ខ្ញុំនិយាយជាការពិត គឺម្រាមដៃមិនមែនក្នុងរបបដែលខ្មែរក្រហមកំពុងតែប្រយុទ្ធទេ គឺពេលដែលរត់ខ្ចាត់ខ្ចាយគ្នាដោយខែច្រូត អាហ្នឹង១៧ មេសា។ ខែច្រូតហ្នឹងយើងមាន ខែច្រូតហ្នឹងយើងរត់ដល់កន្លែងណាយើងច្រូតស្រូវកន្លែងហ្នឹង យកមកបុកជាន់ជាអង្ករ។ ហើយពេលនោះគឺសម្រុកដណ្តើមគ្នាជាន់ហ្នឹងគេមានខូចត្បាល់ធ្លាក់មកដាច់ដៃ អាហ្នឹងមកពីបំបាត់វប្បធម៌ខ្មែរទាំងអស់ដោយសង្គមខ្មែរក្រហម យើងជាន់អង្ករដោយត្បាល់ដាច់ដៃខ្ញុំមួយ។

**ប្រធានអង្គជំនុំ៖**

ក្រោយព្រឹត្តិការណ៍ ១៧ មេសា ៧៥ ឬក៏ ៧ មករា ៧៩?

**លោកស្រី ជូ គឹមឡន៖**

**ឆ៖** ៧ មករា ៧៩។ ច្រលំ។

[១១:៣៣:០៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាមិនចាំបាច់ទេនៅពេលនេះ គឺដើម្បីកំណត់ត្រាតុលាការនេះគឺ ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញ<ម្រាម>ដៃរបស់គាត់ហើយ គឺមិនមែនដូចការបកប្រែក្នុងអត្ថបទថាគាត់ពិការដៃម្ខាងទេ<>។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញវេលាម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញ ឱ្យបានមុននៅម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តទៅនេះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រី គីមឡុន ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ហើយខ្ញុំចោទសំណួរទៅលោកស្រី ដើម្បីសូមការបំភ្លឺទៅនឹងចម្លើយរបស់លោកស្រី ដែលលោកបានឆ្លើយនៅទីនេះរហូតដល់ពេលនេះ។ ខ្ញុំសូមបញ្ជាក់ថាមានសំណួរមួយចំនួនដែលខ្ញុំចង់ចោទសួរទៅលោកស្រី ហើយដែលត្រូវបានចោទសួរទៅលោក<ស្រី> ដោយចៅក្រម ហើយនិងមេធាវីរបស់ នួន ជា។ ខ្ញុំមិនសួរវែងឆ្ងាយទេ។ ខ្ញុំសូមបញ្ជាក់ផងដែរថាខ្ញុំធ្វើយ៉ាងណាសួរតែសំណួរច្បាស់លាស់ ដើម្បីឲ្យបានចម្លើយច្បាស់លាស់ដែរ។ បើសិនជាលោកស្រីមិនយល់សំណួរណាមួយរបស់ខ្ញុំ លោកស្រីកុំឲ្យអល់អែកសួរឲ្យខ្ញុំបញ្ជាក់ឡើងវិញ។ ខ្ញុំ ដោយសារពេលវេលាមានខ្លីនេះ អ៊ីចឹងសូមឲ្យលោកស្រីឆ្លើយខ្លីៗ។

**ស៖** ជាបឋម ខ្ញុំសូមត្រឡប់មកនិយាយអំពីព្រឹត្តិការណ៍ឆ្នាំ១៩៧៧ ដែលលោកស្រីបានឆ្លើយនៅទីនេះ ដែលថាហ្នឹងកើតឡើងនៅឆ្នាំ៧៧នោះ លោកស្រីបានឃើញមេដឹកនាំខ្មែរក្រហមបួននាក់មកដល់ការដ្ឋានការងាររបស់លោកស្រី នៅកន្លែងដែលលោកស្រីធ្វើការ។ សំណួរទី១ របស់ខ្ញុំទាក់ទងនឹងកាលបរិច្ឆេទ នៅពេលដែលលោកស្រីឆ្លើយទៅនឹងសហមេធាវីនាំមុខ<តំណាងដើមបណ្តឹងរដ្ឋប្បវេណី> លោកស្រីបានឆ្លើយថា គឺខែកុម្ភៈ មីនា មេសា <ឬឧសភា> ឆ្នាំ១៩៧៧។ តើខ្ញុំយល់យ៉ាងដូច្នេះ ជាការយល់ត្រឹមត្រូវដែរឬទេលោកស្រី?

[១៣:៣៣:២៨]

**លោកស្រី ជូ គីមឡុន៖**

**ឆ៖** ចាស ត្រឹមត្រូវៗ។

**ស៖** បើខ្ញុំយល់ស្របថា ការងារដែលលោកស្រីធ្វើនៅពេលនោះ គឺការជីកប្រឡាយក្នុងបំណង<ត្រៀមសម្រាប់>រដូវវស្សា <> ហើយជីក<ប្រឡាយ គឺ>ក្នុងពេលរដូវប្រាំងទេ។ ពេលរដូវវស្សាដើម្បីឲ្យមានទឹកនៅក្នុងប្រឡាយ។ អ៊ីចឹងមែនទេលោកស្រី?

**ឆ៖** ជីកប្រឡាយហ្នឹង ដើម្បីខ្វះទឹកនៅរដូវណាមួយអាចបូមទឹកពីស្ពានីយហ្នឹងទៅដាក់តាមតម្រូវដែលយើងត្រូវការ។ ខែប្រាំង ឬខែវស្សា គឺថាអូរចំបក់ហ្នឹងនៅទឹក គឺអាចបូមដាក់បានទាំងអស់។

**ស៖** ក៏ប៉ុន្តែពេលដែលលោកស្រីបានចាប់ផ្តើមជីកប្រឡាយនោះ គឺនៅរដូវប្រាំង អ៊ីចឹងមែនទេលោកស្រី?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** អម្បាញ់មិញនៅពេលដែលលោកស្រីឆ្លើយតបទៅនឹងសំណួរ ទៅសហមេធាវីលោក នួន ជា លោកស្រីបានឆ្លើយថា លោកស្រីបានចូលរួមទៅក្នុងការជីកប្រឡាយនុ៎ងក្នុងរយៈពេលប្រហែលជា ១៥ថ្ងៃ – ពី១០ ទៅ ១៥ថ្ងៃ ហើយបន្ទាប់មកទៀត លោកស្រីទៅធ្វើការនៅការដ្ឋានមួយទៀត។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ លោកស្រី?

**ឆ៖** ចាស ត្រឹមត្រូវពិតប្រាកដ។

**ស៖** លោកស្រី<ដើមបណ្ដឹងរដ្ឋប្បវេណី តាម>កាលបរិច្ឆេទដែលយើងបានលើកឡើងអម្បាញ់មិញនេះគឺថា <>ខែកុម្ភៈ មីនា មេសា <និងឧសភា>នេះ តើមានលទ្ធភាពអីរំឮកការចងចាំលោកស្រីឬទេ។ អ៊ីចឹងសំណួរ ខ្ញុំចង់សួរថា តើលោកស្រីមានចាំថាមុនពេលធ្វើការ<>ជីកប្រឡាយហ្នឹង ដែល<លោកស្រីនិយាយថា លោកស្រីបានឃើញ>អ្នកតំណាងមេដឹកនាំខ្មែរក្រហមទាំងបួនរូបហ្នឹង តើលោកស្រីបានធ្វើការជីកប្រឡាយផ្សេងទៀតទេនៅក្នុង<រយៈពេលដូចគ្នាហ្នឹង ឬក៏នៅក្នុង>រដូវប្រាំងហ្នឹង ឬក៏ការជីកប្រឡាយ<ហ្នឹង>ជាការជីកប្រឡាយលើកទី១ <ដែលលោកស្រីធ្វើ>?

[១៣:៣៦:១៧]

**ឆ៖** ជីកប្រឡាយនៅតាមប្រព័ន្ធភ្លឺស្រែជិតភូមិហ្នឹង ច្រើនលើកច្រើនសាមិនមែនទើបលើកទី១ទេអានេះជាលើកច្រើនដងហើយ ជីកប្រឡាយនៅប្រព័ន្ធតាមភូមិ តាមកង តាមក្បែរព្រៃលើ ក៏មានជីកប្រឡាយដែរ តាមផ្លូវគេធ្វើខ្វាត់ខ្វែង។ នេះជាលើកទីប៉ុន្មានទេ ជីកនៅស្ពានីយបូមទឹកហ្នឹង មិនដឹងលើកទីប៉ុន្មានទេចាស។

**ស៖** អ៊ីចឹង តើលោកស្រីចាំទេ <ការងារអ្វីដែលលោកស្រីធ្វើដំបូងគេ ក្នុងចំណោមការការងារទាំងអស់ហ្នឹង ថាតើវា>នៅខែកុម្ភៈ ឬក៏ខែឧសភា <នៃកាលបរិច្ឆេទដែលលោកស្រីបានបញ្ជាក់>?

**ឆ៖** ចាស ជីកប្រឡាយលើកទី១ យើងច្រូតហើយ។ ចប់ច្រូតហើយយើងដើរធ្វើប្រឡាយៗ ធ្វើប្រព័ន្ធភ្លឺ ធ្វើប្រឡាយៗក្នុងជិតៗភូមិ។ ដល់ហើយជិតៗភូមិ យើងមកប្រឡាយធំតាមថ្នល់ជាតិ ចាស។

**ស៖** ខ្ញុំសូមអរគុណ។ ក៏ប៉ុន្តែសំណួរខ្ញុំ នោះអំមិញនោះ ខ្ញុំចង់ដឹងថា តើចន្លោះខែកុម្ភៈ ដល់ខែឧសភា ដែលលោកស្រីបានឆ្លើយមកតុលាការអម្បាញ់មិញនេះ មុនហ្នឹងនេះ <> លោកស្រីបាន<រៀបរាប់អំពីការងារផ្សេងដែលលោកស្រីបានធ្វើ>។ អ៊ីចឹង គ្រាន់តែចង់ដឹងថា តើពេលដែលលោកស្រី<ឃើញ>មេដឹកនាំទាំងប៉ុន្មាននាក់ហ្នឹង <នៅក្នុង>ខែកុម្ភៈ <ឬក៏នៅពេលជិតដល់ខែឧសភា>?

[១៣:៣៨:៣១]

**ឆ៖** ខែ -- ហ្នឹងវាយូរឆ្នាំពេក អាហ្នឹងខែកុម្ភៈ ឬខែមីនា ឬខែឧសភាហ្នឹង គឺខ្ញុំមិនបានចងចាំច្បាស់ទេ។ ដឹងតែខែប្រាំង រដូវប្រាំងហ្នឹងជីកៗរហូតដល់តែហើយប្រឡាយហ្នឹង បានដកកងខ្ញុំទៅទៀតក្នុងឆ្នាំ៧៧។

**ស៖** តើលោកស្រីមានចាំថា ធ្លាប់បាន<ពិភាក្សាតាម>ទូរសព្ទជាមួយការិយាល័យ<ជំនួយផ្នែកច្បាប់កម្ពុជា នៅខែមករា> ឆ្នាំ២០១១ <ដែរឬទេ>?

<វាមានការបញ្ហាការបកប្រែភាសា។ ដូច្នេះខ្ញុំនឹងសួរសំណួរខ្ញុំឡើងវិញ។>

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រី តើលោកស្រីចាំថា លោកស្រីធ្លាប់មានការពិភាក្សាតាមទូរសព្ទជាមួយបុគ្គលម្នាក់<នៅការិយាល័យជំនួយផ្នែកជំនួយច្បាប់កម្ពុជា> នៅខែ<មករា> ឆ្នាំ២០១១។ មានទេ?

**ឆ៖** <>ចាស មាន។ <គេ>សម្ភាស<ខ្ញុំ>តាមទូរសព្ទ។

[១៣:៤០:០៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាត ផ្ដល់សំណៅជាភាសាខ្មែរមួយច្បាប់នៃរបាយការណ៍នៃការសន្ទនាតាមទូរសព្ទរបស់គាត់ជាមួយនឹងអង្គការជំនួយការផ្នែកច្បាប់កម្ពុជាទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះលោកប្រធាន។ គឺឯកសារ E3/5635, ERN ជាភាសាបារាំងគឺ <00898378>, ERN ជាភាសាអង់គ្លេស 00678302, ERN ជាភាសាខ្មែរគឺ 00897420។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកទៅជូនដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:៤១:២៨]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅទំព័រទី១ នៃឯកសារនេះគឺថា មានកម្រងនៃការសម្ភាសជាតាមទូរសព្ទរបស់គាត់ហ្នឹងមានចំនួនបីដង ដែលគាត់បានផ្ដល់ទៅអ្នកជំនួយការ<ច្បាប់>នៃការិយាល័យជំនួយផ្នែកច្បាប់នៃ

កម្ពុជា។ ហើយមានកំណត់តាមប្រធានបទ ហើយមានលេខកថាខណ្ឌផងដែរ ខ្ញុំមិនបាច់ឲ្យលេខ ERN ទេ ខ្ញុំគ្រាន់តែបង្ហាញលេខជាកថាខណ្ឌទៅបានហើយ។ ខ្ញុំសូមឲ្យលោកស្រីអានកថា ខណ្ឌលេខ១៨ ផ្នែកដំបូង។

<ខាងក្រោមនេះ គឺជាអ្វីដែលកត់ត្រាដោយអ្នកសម្ភាសលោកស្រីតាមទូរសព្ទ៖> "នៅថ្ងៃមួយ <ក្នុង>ខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំបានឃើញ ប៉ុល ពត, នួន ជា, ខៀវ សំផន និងតាម៉ុក (អ្នកមេដឹកនាំទាំងបួននាក់)ហ្នឹងនៅការដ្ឋានរបស់ខ្ញុំ។ នៅថ្ងៃនោះខ្ញុំធ្វើការជីកប្រឡាយនៅព្រៃលើ ក្នុងសហករណ៍ត្រាំកក់ ស្រុកតាកែវ"។ សូមបញ្ចប់ការដកស្រង់។

សំណួរខ្ញុំដូចតទៅនេះលោកស្រី។ ឥឡូវនេះ ខ្ញុំចង់ដឹងថាកាលពីឆ្នាំ២០១១ហ្នឹង លោកស្រីនៅចាំច្បាស់ជាងឥឡូវហ្នឹង ដូចកាលបរិច្ឆេទដែលមានគេកត់ត្រាទុកនេះ ពេលដែលគេសម្ភាសលោកស្រីតាមទូរសព្ទហ្នឹង និង -- ថានឹងការដែលគេកត់ត្រាហ្នឹងត្រូវទេ? លោកស្រីបានឆ្លើយអ៊ីចឹងមែនឬកាលដែលគេសម្ភាសលោកស្រីតាមទូរសព្ទហ្នឹង?

**ផ៖** មិនមែនទេ ខ្ញុំសម្ភាសតាមទូរសព្ទនៅស្ថានីយអូរចំបក់ តែគាត់ស្តាប់ទូរសព្ទដោយមិនច្បាស់ដោយដាច់សេវា គាត់ដាក់នៅ "ព្រៃលើ"។ ខ្ញុំអត់មានថាដាក់ព្រៃលើទេ។ នៅតែស្ថានីយបូមទឹកអូរចំបក់តែមួយកន្លែងទេ ជួបគាត់ចាស។

[១៣:៤៣:៣៩]

**ស៖** ដូច្នេះ ខ្ញុំត្រូវយល់យ៉ាងម៉េច យល់ថាព័ត៌មាននៅក្នុងឯកសារហ្នឹង មិនត្រូវ ឬក៏យ៉ាងម៉េច?

**ផ៖** ជួបលោក ខៀវ សំផន ត្រឹមត្រូវពិតប្រាកដមែន តែខុសទីតាំង។ ទីតាំងគាត់ដាក់ព្រៃលើហ្នឹងគឺខុសទេ ប្រឡាយជីកព្រៃលើ ជីកជាធម្មតា តែអត់បានជួបមេដឹកនាំទេ មេដឹកនាំជួបតែនៅថ្នល់ជាតិ ស្ថានីយអូរចំបក់។

**ស៖** លោកស្រី ទាក់ទងនឹងកាលបរិច្ឆេទនៅពេលដែលគេសរសេរថា "នៅថ្ងៃមួយ <ក្នុង>ខែកុម្ភៈ ឆ្នាំ១៩៧៧" <តើ>នេះជាអ្វីដែលលោកស្រីបាននិយាយ ឬក៏គេកត់បញ្ចូលនៅក្នុងឯកសារនេះខុសទេ?

**ផ៖** ខ្ញុំនិយាយក្នុងទូរសព្ទខ្ញុំថា "ខ្ញុំចង់ភ្លេចហើយ មិនដឹងជាខែ២ ខែ៣ ឬក៏ខែ៤ ខែ៥ ព្រោះយូរពេក១ វា២០ឆ្នាំ ៣០ឆ្នាំហើយ យូរពេក។ ចាសបើថាចាំខែដឹងថាខែប្រាំង" តែទីតាំងកត់ខុស តែជួបជាការពិត។

[១៣:៤៥:១៩]

**ស៖** ដូច្នេះ ខ្ញុំត្រូវយល់ថាយ៉ាងម៉េចដែរ អ្នកដែលធ្វើកម្រងសម្ភាសរបស់លោកស្រីហ្នឹងផ្ដល់ព័ត៌មានមិនត្រឹមត្រូវទេនៅក្នុងឯកសារនេះ។ អ៊ីចឹង លោកស្រីចង់និយាយថាអ៊ីចឹង<នៅចំពោះមុខតុលាការ>?

**ឆ៖** ខ្ញុំចង់និយាយថា ផ្ដល់ព័ត៌មានឯកសារនេះដោយសារសម្ភាសតាមទូរសព្ទ។ ដូច្នេះការរអាក់រអួលវាអាចមានៗដោយគាត់មិនបានស្ដាប់យើងដោយច្បាស់លាស់។

**ស៖** <> អ៊ីចឹងតើលោកស្រីបាននិយាយប្រាប់គាត់ថាអាចខែកុម្ភៈ មីនា មេសា ឬក៏ឧសភា ក៏ប៉ុន្តែគាត់ហ្នឹងគាត់បានឮតែខែកុម្ភៈ។ អ៊ីចឹងលោកស្រី<យល់ស្របដែរឬទេថា លោកស្រីបានប្រាប់ទៅគាត់ថា លោកស្រី>មិនសូវច្បាស់<កាលបរិច្ឆេទ ប៉ុន្តែវាមិនត្រូវបានគេកត់ត្រាទុក>។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ព្រោះយូរឆ្នាំពេក មិនសូវជាច្បាស់ថាជាខែ៥ ឬខែ៣ ចាស។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វីដែលលោកស្រីបានឆ្លើយនៅក្នុងសវនាការនេះ គឺថាទាក់ទងទៅនឹងមេកងរបស់លោកគឺ តាអឿន ហើយ<ក៏ជា>អ្នកដែលប្រាប់លោកស្រីអំពីការមកដល់របស់មេដឹកនាំទាំងអស់នេះ។ សំណួរទី១របស់ខ្ញុំគឺ -- ការបកប្រែដូចជាមិនសូវជាច្បាស់<សោះ>។ អ៊ីចឹង ខ្ញុំសុំសួរថា តាអឿន ហ្នឹង គឺជាមនុស្សប្រុស ឬក៏មនុស្សស្រី? ព្រោះខ្ញុំយល់អត់សូវច្បាស់ដែរតាមរយៈការបកប្រែនេះ។

**ឆ៖** តាអឿន ហ្នឹងគឺជាមនុស្សប្រុស។ គាត់ជាមេកង កាន់កងផង គាត់រត់ការធ្វើការនៅពាណិជ្ជសាលាឃុំទៀត ជាមេកងធំជាងគេ។ ប្រុស គាត់ជាប្រុស។

**ស៖** ទាក់ទងនឹងទស្សនកិច្ចនេះ តើលោកស្រីយល់ស្របដែរឬទេថា លោកស្រីបានដឹងថាមានទស្សនកិច្ចរបស់បុគ្គលទាំងបួននាក់នេះ<នៅយប់>មុនពេល<ពួក>គាត់មកធ្វើទស្សនកិច្ច។ អ៊ីចឹងមែនទេ? លោកស្រីយល់ស្របទេ?

[១៣:៤៨:១៣]

**ឆ៖** ខ្ញុំយល់ស្របថា ខ្ញុំទៅធ្វើការអត់បានដឹងគាត់មកថ្ងៃហ្នឹងទេ។ ខ្ញុំទៅធ្វើការទើបឃើញគាត់មកៗទស្សនកិច្ច។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនខុសទេ គឺថាលោកស្រីដឹងតែៗពេលថ្ងៃដែលពួកគាត់មកធ្វើទស្សនកិច្ចតែម្ដង។ អ៊ីចឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** ខ្ញុំសូមឲ្យលោកស្រីអានកថាខណ្ឌទី២០ នៃកិច្ចសម្ភាសន៍តាមទូរសព្ទរបស់លោកស្រីដែលលោកស្រីមាននៅក្នុងដៃហើយ។ នេះគឺមានសរសេរដូចតទៅនេះ៖ "<ចំពោះ> ប៉ុល ពត, នួន ជា និង តាម៉ុក <>ហ្នឹង ខ្ញុំមិនដែលធ្លាប់បានឃើញគាត់ពីមុនមកទេ ប៉ុន្តែខ្ញុំដឹងថាគាត់ជាអ្នកណា ពីព្រោះថាមួយថ្ងៃមុនៗពួកគាត់មកដល់មកកន្លែងធ្វើការនេះ <ប្រធានក្រុម>កងចល័តគេបានប្រាប់ខ្ញុំថា <មេដឹកនាំចំនួនបួននាក់>នឹងមកធ្វើទស្សនកិច្ចនៅទីនេះ យើងត្រូវធ្វើការឲ្យបានហ្មត់ចត់ ដាំស្រូវ ធ្វើស្រែស្ទូងស្រូវនោះពេលដែលពួកគាត់ចុះមកមើល" <បញ្ចប់ការដកស្រង់>។

អ៊ីចឹងបើតាមមើលឯកសារនេះថា គេប្រាប់លោកស្រីមួយថ្ងៃមុន មុនពេលពួកគាត់មកធ្វើទស្សនកិច្ច។ អ៊ីចឹង ខ្ញុំចង់សួរថា តើនេះជា<កំហុស>របស់អ្នកដែលធ្វើកម្រងកិច្ចសម្ភាសន៍របស់លោកស្រី<ឬយ៉ាងណា>?

[១៣:៤៩:៥៤]

**ឆ៖** ខុសនឹងមតិខ្ញុំដែលបាននិយាយសម្ភាសតាមទូរសព្ទ ព្រោះលោក តាម៉ុក ខ្ញុំធ្លាប់ស្គាល់គាត់តាំងពីយូរហើយ។ តាំងពីខ្ញុំនៅហ្នឹងឃើញគាត់ជាញឹកញាប់មុនលោក ខៀវ សំផន និងលោក នួន ជា ហ្នឹងចុះទៅទៀត។ ខ្ញុំធ្លាប់ឃើញគាត់ជាញឹកញាប់។ តែគាត់កត់នេះ មូលហេតុគឺគាត់ស្ដាប់មិនឮក្នុងទូរសព្ទ ថាខ្ញុំមិនបានស្គាល់ខុស ខុសផ្ទុយនឹងខ្ញុំដឹង ខ្ញុំធ្លាប់ស្គាល់គាត់។ ចាស លោក តាម៉ុក ស្គាល់គាត់យូរហើយ។ តាំងចុះទៅដល់តាំងពីឆ្នាំចូល៧៧ គាត់ដើរចលនាគ្រប់ទីកន្លែង ខ្ញុំឃើញគាត់រហូត។

**ស៖** បាទ ឥឡូវ ខ្ញុំសូមចោទសំណួរមួយទៀតក្រៅពីចម្លើយរបស់លោកស្រី។ តើបន្ទាប់មកលោកស្រីបានដឹងថាមានកិច្ចប្រជុំដើម្បីរៀបចំការធ្វើទស្សនកិច្ចនេះទេ មុនពេលដែលពួកគាត់មកធ្វើមកទស្សនកិច្ច? តើ<>ប្រធានកង<របស់លោកស្រី> ឬអ្នកដទៃផ្សេងទៀត<នៅក្នុង>សហករណ៍ហ្នឹង <ឬក៏ខាងឃុំ> បានប្រាប់លោក<ស្រី>ថា គេមានធ្វើកិច្ចប្រជុំមួយដើម្បីរៀបចំទទួលទស្សនកិច្ចរបស់ពួកគាត់នោះ <ដែរឬ>ទេ?

**ឆ៖** ចាស អត់ទេ គេអត់មានប្រាប់ទេ។ យើងអត់មានដឹងទេ បើគេប្រាប់យើង គេអាចខ្លាចយើងហ្នឹងជាអ្នក១៧ មានបញ្ហា។ គេអត់មានប្រាប់ទេ។ គេដឹងតែឲ្យយើងធ្វើការ ដល់មកធ្វើការបានយើងឃើញវាក់តែម្ដង ឃើញតែម្ដង ចាស។

**ស៖** ឥឡូវ ខ្ញុំសូមត្រឡប់មកនិយាយ ថ្ងៃដែលថាលោកស្រីបានឃើញគាត់នៅការដ្ឋាន ពួកគាត់

01062997


ទាំងបួននាក់ហ្នឹង។ <តាមខ្ញុំយល់ គឺថា>លោកស្រីបានឃើញឡានដែលពួកគាត់ជិះនោះនៅលើផ្លូវនៅក្បែរកន្លែងដែលលោកស្រីធ្វើការ។ អ៊ីចឹងមែនទេ លោកស្រីបានឃើញឡានដែលគាត់ជិះមក?

[១៣:៥២:១៨]

**ធ៖** ចាស បានឃើញអ៊ីចឹងពិតមែន។ ឡានគាត់ពណ៌ខ្មៅ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ គឺថាកាលនោះឃើញមានឡានតែមួយទេ?

**ធ៖** ឡានពីរ តែគេ -- អ្នកសម្ភាសអត់មានសួរខ្ញុំ។ គេសួរថា ឃើញមេដឹកនាំខ្មែរក្រហមទៅដោយវិធីណា? ខ្ញុំថាគាត់ជិះឡានពណ៌ខ្មៅ។ តែ តាម៉ុក គាត់ជិះឡានអាហ្ស៊ីប។ ឡានពីរ តែអ្នកសម្ភាសអត់បានសួរ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺថាលោកស្រីបានឃើញមានឡានពីរ គឺថាឡានខ្មៅមួយដែលមាន <> ប៉ុល ពត ហើយនិង <ខៀវ សំផន> -- សុំទោស ក្នុងឡាននោះមាន នួន ជា, ខៀវ សំផន, ប៉ុល ពត ហើយនៅ ឡានហ្ស៊ីប ហ្នឹងមាន តាម៉ុក អ៊ីចឹងមែនទេ?

**ធ៖** ចាស ពិតប្រាកដមែន។

[១៣:៥៣:៣៤]

**ស៖** អម្បាញ់មិញនេះ លោកចៅក្រម ឡាវ៉េន៍ បានសួរ<>លោកស្រីថា តើមានបរទេសមកការដ្ឋានការងារហ្នឹងទេ? អ៊ីចឹងខ្ញុំសួរលោកស្រីថា ថ្ងៃដែលលោកស្រីឃើញឡានទាំងពីរហ្នឹង ក្រៅពី តាម៉ុក ហើយនិងមេដឹកនាំទាំងបីនាក់ផ្សេងទៀតហ្នឹង តើមានអ្នកណាផ្សេងទៀតមានវត្តមាននៅទីហ្នឹងទេ? ហើយខ្ញុំសួរថា នៅក្នុងឡានដែលមានមនុស្សបីនាក់ ហ្នឹងមានប៉ុល ពត, នួន ជា, ខៀវ សំផន ហ្នឹង តើមានអ្នកណាផ្សេងទៀត ដែលជិះនៅលើឡានហ្នឹងអមដំណើរគាត់ទេ <>?

**ធ៖** ក្នុងកញ្ចក់ឡានគឺខ្មៅ យើងមិនអាចមើលអ្នកអង្គុយនៅក្នុងហ្នឹង ឬមានសូហ្វ័រ មានអីអត់ដឹងទេ។ យើងឃើញតែពេលដែលគាត់ចុះមក បីនាក់។ ក្នុងហ្នឹងអត់មានដឹងថា មានសូហ្វ័រមានអី ឬអត់អត់ដឹងទេ ចាស។

**ស៖** ហើយនៅក្នុងឡាន តាម៉ុក នោះមានអ្នកណាផ្សេងទៀតទេ?

**ធ៖** ក្នុងកញ្ចក់ឡានយើងមិនអាចមើលឃើញបានទេ ព្រោះកញ្ចក់ឡាន គេដឹកអ្នកធំ អត់មានយើងមើលចូលទៅក្នុងឃើញទេ ព្រោះកញ្ចក់គេបិទជាខ្មៅ។ យើងនៅក្នុងប្រឡាយយើងមើលទៅមិនឃើញទេ ព្រោះឡានវានៅឆ្ងាយពីយើង តែមើលមេដឹកនាំចុះមកដើរក្បែរយើង។ ចាសអស់យោបល់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាបុគ្គលដែលលោកស្រីបានឃើញចុះពីលើឡាននោះ គឺមានតែ ខៀវ សំផន, ប៉ុល ពត, នួន ជា ហើយនិង តាម៉ុក ទេ។ អ៊ីចឹងត្រឹមត្រូវដែរឬទេ គឺមានតែបួននាក់ហ្នឹងទេ?

**ឆ៖** ចាសឃើញតែបួននាក់ហ្នឹង។ ត្រឹមត្រូវហើយ។

**ស៖** លោកស្រីបានឆ្លើយផងដែរ អម្បាញ់មិញហ្នឹងគឺថានៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួរ របស់លោកស្រីចៅក្រម ហ្វេនស៍ លោកស្រីបានឃើញៗគាត់ទាំងបួននាក់ហ្នឹង <មិនលើស> ១៥នាទីទេ។ អ៊ីចឹងមែនទេ លោកស្រីបញ្ជាក់ចម្លើយហ្នឹងទេ?

[១៣:៥៦:១៦]

**ឆ៖** ខ្ញុំឃើញគាត់ប្រហែលជា១៥នាទី ដោយសារគាត់ឈរនៅកន្លែងខ្ញុំកំពុងតែធ្វើការ ឈរឱ្យចែកទឹកត្នោតឱ្យហូបហ្នឹង ឱ្យដាក់កន្ទេលនិងដាក់ថែមស្ពាមួយចំណិតៗឱ្យវាផ្អែម។ ដល់ហើយគាត់ដើរទៅទៀត ហើយគាត់និយាយគ្នាដែរទៅ មិនដឹងជានិយាយអីទៀត ខ្ញុំមិនដឹងទេចាស។

**ស៖** ខ្ញុំអម្បាញ់មិញហ្នឹងខ្ញុំដូចជាយល់ឃើញថា វាយល់ថា -- សុំកែខ្ញុំ បើខ្ញុំយល់ខុស គឺថាបន្ទាប់ពីពេលដែលមានទស្សនកិច្ចរយៈពេលខ្លី នៅកន្លែងការដ្ឋានការងាររបស់លោកស្រី គឺថាមានកិច្ចប្រជុំមួយដែលគេកោះហៅប្រធានតាមមូលដ្ឋានហ្នឹងមកប្រជុំ។ តើការយល់របស់ខ្ញុំនេះជាយល់ត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ប្រធានមូលដ្ឋាន ប្រធានកង ប្រធានក្រុម កោះហៅ យើងពលករអ្នក១៧, ១៨ ទាំងអស់ ចូលរួមប្រជុំ មិនមែនកោះហៅមេកងមូលដ្ឋានទេ កោះហៅប្រជាជនអ្នកជីកប្រឡាយ។ ហ្នឹងមេកងយើងអ្នកហៅប្រជុំដើម្បីពង្រឹងគោលជំហរ និងប្ដេជ្ញាធ្វើការមហាអស្ចារ្យ មហាលោតផ្លោះ។

**ស៖** <>បើអ៊ីចឹងគឺខ្ញុំយល់ថា គឺថាមានកិច្ចប្រជុំមួយដែលគេធ្វើឡើងក្រោយទស្សនកិច្ចហ្នឹង <គឺជាកិច្ចប្រជុំដែលលោកស្រីបានលើកឡើងមុនហ្នឹង។ វាជាកិច្ចប្រជុំនៅអំឡុងពេល ឬមុនបាយថ្ងៃត្រង់បន្តិច>។ ក៏ប៉ុន្តែ<នេះ>មិនមែនកិច្ចប្រជុំហ្នឹងដែលខ្ញុំចង់និយាយ<នោះទេ> គឺខ្ញុំចង់ដឹងថាតើលោកស្រីដឹងថាមានកិច្ចប្រជុំមួយទេ ក្រោយពេលដែលអ្នកទាំងបួននាក់ហ្នឹងមកធ្វើទស្សនកិច្ចនោះ។ មានកិច្ចប្រជុំមួយដែលលោកស្រីមិនបានចូលរួមនោះទេ គឺជាកិច្ចប្រជុំរវាងមេដឹកនាំទាំងបួននាក់ហ្នឹង ហើយនិងអ្នកដឹកនាំថ្នាក់មូលដ្ឋាន។ លោកស្រីដឹងថាមានកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** ចាស កិច្ចប្រជុំដែលពួកមេកងខ្ញុំ និងប្រធានភូមិខ្ញុំ និងប្រធានកងខ្ញុំ និងប្រធានកងយុវជន

ប្រធានគណៈៗហ្នឹងទៅតាមលោកទាំងអស់គ្នា តែគាត់ប្រជុំនៅកន្លែងណា ក្រោមដើមឈើកន្លែងណា ក៏ខ្ញុំមិនដឹងដែរ តែគេហៅគាត់ទៅតាមទាំងអស់ហើយ។ ចាស មេកងគេហៅគ្នាទៅ មេៗកងគេហៅទៅតាម។ មួយសន្ទុះទេ ទៅបាត់មួយសន្ទុះទេ មេកងខ្ញុំមកវិញធ្វើការជាមួយគ្នាទាំងអស់។ តែគណៈឃុំ គណៈស្រុក អត់មានមកទេ។ គេដឹង គេទៅកន្លែងណាទៀត។ តាមដែលខ្ញុំដឹងថា គណៈឃុំ គណៈស្រុក ទៅដល់សាលាឃុំលាយបូរ ពាណិជ្ជ សាលាឃុំលាយបូរនិងសហករណ៍កង១។ ដល់ថ្ងៃៗ ថ្ងៃក្រោយមក ខ្ញុំដឹងថាលោកទាំងបីនាក់ហ្នឹង ទៅដល់កន្លែងហ្នឹង កង១ទៀត។

[១៤:០០:០០]

**ស៖** ឥឡូវខ្ញុំសូមអង្គន់សំណួរ ព្រោះអីលោកស្រីផ្ដល់ព័ត៌មានច្រើនណាស់អម្បាញ់មិញ។ សំណួរទី១ លោកស្រីបានលើកឡើងថាមានការកិច្ចប្រជុំមួយនៅក្រោមដើមឈើ។ តើលោកស្រីឃើញមេដឹកនាំទាំងបួនហ្នឹង ហើយនិងមេដឹកនាំថ្នាក់មូលដ្ឋានហ្នឹងនៅក្រោមដើមឈើហ្នឹងតែម្ដង ឬក៏លោកស្រីបានដឹងថាគេប្រជុំហ្នឹងពេលក្រោយ<មកទៀត>?

**ឆ៖** ដឹងថ្ងៃហ្នឹងថ្ងៃមេកងខ្ញុំ មេក្រុមខ្ញុំត្រលប់មកវិញហ្នឹងថា "ជួបជុំគ្នានៅ គាត់ទៅជួបជុំគ្នានៅក្រោមដើមស្វាយ" ពេលគាត់មកវិញ មកធ្វើការវិញ ប៉ុន្តែគ្រាន់តែជួបជុំប្រជុំពិភាក្សាអីក៏ខ្ញុំអត់ដឹងដែរ គ្រាន់តែពេលយើងសម្រាកមេកងយើងប្រជុំយើងការងារពលកម្ម។

**ស៖** ឥឡូវហ្នឹង ខ្ញុំសូមត្រឡប់ -- ខ្ញុំចង់ផ្ដោតទៅលើកិច្ចប្រជុំដែលលោកស្រីមិនបានចូលរួម ដែលក្នុងនោះមាននិយាយថាមានប្រធានកង <>ហើយនិងមានអ្នកផ្សេងគេប្រាប់លោកស្រី<អំពីរឿងនេះ>។ សំណួរទី១ ខ្ញុំចង់សួរ។ អម្បាញ់មិញលោកស្រីបាននិយាយអំពីឈ្មោះមួយចំនួន រៀបរាប់ឈ្មោះមួយចំនួនហើយនិងមុខងារមួយចំនួន ដោយខ្ញុំមិនយល់ថាអ្នកណាជាអ្នកណា ហើយអ្នកណាធ្វើអ្វី។ អ៊ីចឹងខ្ញុំសូមៗឲ្យលោកស្រីជួយបំភ្លឺបន្តិចត្រង់ចំណុចនេះ។ លោកស្រីបាន<និយាយអំពីបុគ្គលម្នាក់ឈ្មោះ> តាសាន<>។ អ៊ីចឹងសំណួរមួយខ្ញុំសួរថា មានស្គាល់ឈ្មោះពេញរបស់គាត់ទេ? ហើយមុខងារគាត់ហ្នឹងជាអ្វីដែរ គាត់ធ្វើអ្វីដែរ?

[១៤:០១:៥៩]

**ឆ៖** គាត់ឈ្មោះ តាសាន មិនដឹងជាត្រកូលគាត់ឈ្មោះអីទេ ខ្ញុំដឹងតែគាត់ឈ្មោះ តាសាន ហើយគាត់មុខងារគាត់ជាគណៈស្រុក ហើយគាត់កាលពីសង្គមដែលមិនទាន់មានរបបខ្មែរក្រហមគាត់ជាគ្រូបង្រៀន។

**ស៖** លោកស្រីមានឈ្មោះគាត់ពេញទេ ស្គាល់ឈ្មោះពេញគាត់ទេ?

**ឆ៖** អត់ស្គាល់ឈ្មោះពេញទេ ប៉ុន្តែគាត់រត់ទៅនៅអន្លង់វែង ប៉ុន្តែឥឡូវឮថាស្លាប់ហើយ ខ្ញុំអត់ដឹងដែរ។

**ស៖** លោកស្រីក៏បានរៀបរាប់ឈ្មោះ<តាហូញ។ <សម្រាប់អ្នកបកប្រែ គឺវានៅត្រង់កថាខណ្ឌ ២៥ នៃកំណត់ហេតុស្តាប់ចម្លើយសាក្សី>។ បើអ៊ីចឹងលោកស្រី<ស្គាល់ឈ្មោះពេញរបស់គាត់ទេ ហើយ>ដឹងថាគាត់មានមុខតំណែងអីទេកាលនោះ?

**ឆ៖** ខ្ញុំដឹង តាហូញ។ ឈ្មោះគាត់ តាហូញ ហ្នឹងជាមេឃុំៗឱបក្តាប់លើ តានៅ។ តានៅ ផ្នែកយោធា, តាហូញ គាត់មេឃុំ។ ហើយ តានៅ គាត់ហ្នឹងផ្នែកយោធា ហើយក្រោយៗមកទៀតបន្តបន្ទាប់ ខ្ញុំមិនបានដឹងច្បាស់ទេ ដឹងតែពីរនាក់ហ្នឹងធំជាងគេ គណៈឃុំ។

[១៤:០៣:៤៦]

**ស៖** ខ្ញុំសួរទៀត តាហូញ ហ្នឹង លោកស្រីស្គាល់ឈ្មោះពេញរបស់គាត់ទេ?

**ឆ៖** ដោយសារគាត់ជាអ្នកធំ គេហៅ "តាហូញៗ" អ៊ីចឹង គេអត់មានហៅត្រកូលទេ។ គេហៅតាៗ ដល់ពេលគេទៅបាត់បានគេហៅឈ្មោះតាមក្រោយ។ គេហៅ "តាហូញ"។ គាត់ក៏ទៅជម្រិតលោកឪពុកខ្ញុំដែរ តាហូញ គណៈឃុំ។

**ស៖** លោកស្រីក៏បាន<និយាយអំពី>ឈ្មោះ តានៅ។ នៅកថាខណ្ឌ២៥ហ្នឹង មានសរសេរឈ្មោះហ្នឹង។ អ៊ីចឹង ខ្ញុំសូមប្រាប់ដល់អ្នកបកប្រែឲ្យរកឈ្មោះហ្នឹងឲ្យឃើញ។ អ៊ីចឹងសួរសំណួរដដែលទេ តើគាត់ឈ្មោះពេញគាត់អីគេ ហើយគាត់មានមុខងារអ្វីដែរ?

**ឆ៖** គាត់ឈ្មោះ តានៅ ហ្នឹង គាត់មុខងារគាត់ៗធ្វើការនៅឃុំជាមួយតាហូញ។ តែឈ្មោះពេញខ្ញុំអត់ដឹង។ ដឹងថាគេហៅគាត់ តានៅៗ អ៊ីចឹងទៅ។ ឲ្យតែឃើញ តានៅ ម្នាក់ៗខ្លាចតែម្តង គឺខ្ញុំធ្វើការព្រឺបៗ ខ្លាច ព្រោះតានៅ នុំងគាត់រាងកាច។

**ស៖** ហើយលោកស្រីក៏បានរៀបរាប់ឈ្មោះ <តាអឿន> ដែលជាមេកងរបស់លោកស្រី ហើយលោកស្រីស្គាល់ឈ្មោះពេញគាត់ទេ?

**ឆ៖** អត់មាន គេអត់មានឲ្យយើងស្គាល់ត្រកូលទេ។ គេដឹងហៅ តាអឿនៗ មេកង – ប្រធានកង៣។ តាអឿន ឲ្យស្គាល់តែប្រធានកង។ ឈ្មោះ តាអឿន ត្រកូលគេអត់មានដែលប្រាប់យើងទេ។

**ស៖** អម្បាញ់មិញលោកស្រីបានឆ្លើយថា នៅក្នុងកិច្ចប្រជុំហ្នឹង គឺមានការចូលរួម<ពីមេកង>

យុវជន។ តើលោកស្រីចាំឈ្មោះទេ ចាំឈ្មោះអ្នកចូលរួមហ្នឹងទេ?

[១៤:០៦:៣២]

**ផ៖** មេកងយុវជន គេមេកងយុវជន គេឈ្មោះ បូ – ឈ្មោះសមមិត្តបូ ចាស។

**ស៖** បុគ្គលទាំងប៉ុន្មាននាក់នេះ ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ មានតាសាន, តាហ្វួញ, តានៅ, តាអឿន។ ខ្ញុំសូមទោសដែលអានឈ្មោះមិនសូវត្រូវ។ តើបុគ្គលទាំងអស់នេះ ឬក៏លោកស្រីដឹងថាអ្នកទាំងប៉ុន្មាននាក់នេះ បានចូលរួមក្នុងកិច្ចប្រជុំជាមួយមេដឹកនាំទាំងបួននាក់ហ្នឹង ក្រោមដើមស្វាយទេ លោកស្រីដឹងទេ?

**ផ៖** ខ្ញុំដឹងដោយសារគេនិយាយប្រាប់ ព្រោះខ្ញុំអ្នកថ្មី១៧ គឺខ្ញុំនៅធ្វើការ។ ដឹងដោយសារគេអ្នកចាស់ គេនិយាយប្រាប់ខ្ញុំចាស។

**ស៖** អ៊ីចឹងលោកស្រីចាំទេ ថាអ្នកណាបានប្រាប់លោកស្រីពីរឿងកិច្ចប្រជុំហ្នឹង?

**ផ៖** មេកងខ្ញុំឈ្មោះ អឿន ហ្នឹងៗ គេថាប្រជុំនៅ -- គេសួរថា៖ “ទៅកន្លែងណា?” គេថា៖ “ទៅនៅប្រជុំក្រោមដើមស្វាយ” ហើយគេមកវិញហើយហ្នឹង ចាស។

**ស៖** អ៊ីចឹង <តាអឿន> ហ្នឹងដែលប្រាប់លោកស្រីថា មានវត្តមានតាសាន, តាហ្វួញ, តានៅ អីនៅក្នុងកិច្ចប្រជុំហ្នឹង។ អ៊ីចឹង តាន៉ុងហើយដែលគាត់ប្រាប់លោកស្រី?

**ផ៖** ចាស តាហ្នឹងប្រាប់។

[១៤:០៨:៤៣]

**ស៖** ឈ្មោះ មេដឹកនាំមូលដ្ឋានទាំងអស់នោះ ក្នុងចំណោមហ្នឹងលោកស្រីមានស្គាល់ឈ្មោះ គិត ទេ?

**ផ៖** គិតៗអាម៉េចអត់ច្បាស់ទេ? អត់មានដឹងឈ្មោះ គិត ទេ។ គិត មួយណាអត់ អានអត់ច្បាស់ ឬក៏អាម៉េច?

**ស៖** សម្រាប់អ្នកបកប្រែ គិត ដែលខ្ញុំនិយាយអំមិញនេះ ជាភាសាបារាំងគេសរសេរ “K-I-T” អ៊ីចឹងសំណួរខ្ញុំសួរថា លោកស្រីស្គាល់ឈ្មោះ គិត ទេដែលគាត់ហ្នឹងជាមេដឹកនាំថ្នាក់មូលដ្ឋានដែរ?

**ផ៖** អត់ទេ។ អត់ស្គាល់ទេ មិនមែនថ្នាក់មូលដ្ឋានខ្ញុំអត់ស្គាល់ទេ ចាស។

**ស៖** តើលោកស្រីស្គាល់ឈ្មោះ ជឹម ទេ តាជឹម?

**ផ៖** ស្គាល់ ប្រធានភូមិ។ ចាស ប្រធានភូមិនៅមូលដ្ឋានខ្ញុំ។

**ស៖** លោកស្រីស្គាល់ឈ្មោះពេញគាត់ទេ?

**ឆ៖** អត់ស្គាល់ឈ្មោះពេញគាត់ទេ ឈ្មោះពេញមិនដឹងជាត្រកូលគាត់ម៉េចទេ ដឹងគេហៅ ពូជឹម ៗ។ តែគាត់មូលដ្ឋានតាមភូមិ គាត់មិនមែនធំទេ បើថ្នាក់ឃុំ ខ្ញុំរៀបរាប់អស់ហើយ។

**ស៖** តើលោកស្រីទេថា តើគាត់ហ្នឹងបានចូលរួមប្រជុំនៅក្រោមដើមស្វាយនឹងគេនឹងឯងទេ?

**ឆ៖** គាត់ទៅពីរនាក់ហ្នឹង គាត់ទៅ តាអឿន ហើយ តាជឹម ហ្នឹង គាត់ទៅជាមួយគ្នា។ តែឥឡូវ គាត់បាត់ស្រមោល គាត់នៅឆ្ងាយគាត់នៅៗលិចវត្តចំប៉ា។ គាត់នៅឯលិចវត្តចំប៉ា គាត់ចុះមកកាន់មេកង ខ្ញុំ សុទ្ធអ្នកនៅឆ្ងាយ។ លិចអង្គរកាៗ។

[១៤:១១:៣៧]

**ស៖** អ៊ីចឹងយើង -- គឺថា តាអឿន ហ្នឹងហើយដែលគាត់បានប្រាប់ថា តាជឹម ហ្នឹងមានចូលរួមប្រជុំនឹងគេដែរ។ តើលោកស្រីយល់ស្របទេ?

**ឆ៖** ចាស យល់ស្រប។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកស្រី ខ្ញុំសូមអរគុណ។ ខ្ញុំអស់សំណួរហើយប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោកគង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកស្រី ខ្ញុំបាទ គង់ សំអុន សូមសួរលោកស្រីមួយចំនួន។ ដំបូង ខ្ញុំចង់សួរថា តើអ្នកស្រីឈ្មោះ ជូ គឹមឡេង ឬក៏ជូ គឹមលន ឬក៏ ជូ គឹមឡន។ លោកស្រីអាចបញ្ជាក់ឲ្យច្បាស់បានទេ?

[១៤:១២:៣៨]

**លោកស្រី ជូ គឹមឡន៖**

**ឆ៖** ចាស ខ្ញុំជូ គឹមឡន បងស្រីខ្ញុំជូ គឹមឡេង។ គាត់អត់ចេញជាមួយខ្ញុំ គាត់ចេញផ្លូវជាតិលេខ

១។ តែពាក់ព័ន្ធរឿងគាត់ឆ្លើយមកមេធាវីកត់ចូលច្រឡំ។ គាត់អង្គុយជិតខ្ញុំ គាត់ឆ្លើយពាក់ព័ន្ធ។

**ស៖** បាទ អរគុណ។ អ៊ីចឹងបានន័យថាឈ្មោះដែលមានកំណត់ត្រានៅលើឯកសារ E3/5635 នេះគឺខុសទេ មិនមែន ជូ គីមឡេង ទេ គឺត្រូវដាក់ថា ជូ គីមឡុន អ៊ីចឹងវិញណ៎ា។ ពីព្រឹកមិញ ខ្ញុំបាន (សូមទោស) ពីម្សិលមិញ ខ្ញុំបានស្ដាប់អ្នកស្រីមានប្រសាសន៍ពាក្យមួយឃ្លាជាភាសាខ្មែរ ដែលលោកស្រីមានប្រសាសន៍ថា "ក្បាលអ្នកណាសក់អ្នកហ្នឹង"។ អ្នកស្រីចាំបានថា អ្នកស្រីមានប្រសាសន៍ពាក្យនេះទេ?

**ផ៖** ខ្ញុំចាំបាន "ក្បាលអ្នកណា សក់អ្នកហ្នឹង" ក្នុងរបបខ្មែរក្រហម គេនិយាយតែអ៊ីចឹងរហូត។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចពន្យល់ពីខ្លឹមសារនៃពាក្យហ្នឹងបានទេ?

**ផ៖** ខ្ញុំអាចពន្យល់ប្រាប់បាន គឺក្បាលអ្នកសក់អ្នកហ្នឹង មូលហេតុមកពីដាក់លក្ខខណ្ឌបែបនេះ គឺមិនអាចមានបង ឬមានប្អូន មានឪពុក មានម្ដាយ ជួយកូនណាបាន ជួយបងប្អូនណាបានឡើយ។ តែអ្នកណាខុស អ្នកហ្នឹងត្រូវអង្គការចាប់ចងយកទៅ អត់មានអ្នកណាមកធានាជួយបានជាដាច់ខាត។ នេះជាថា "ក្បាលអ្នកណាសក់អ្នកហ្នឹង"។ ចាស សូមជ្រាប។

[១៤:១៤:៥២]

**ស៖** បាទ សូមអរគុណ។ តើពាក្យនេះ វាមានអត្ថន័យទៅលើការទទួលខុសត្រូវទេ ទាក់ទងទៅនឹងការងាររបស់បុគ្គលម្នាក់ៗនៅក្នុងសម័យខ្មែរក្រហមនោះ?

**ផ៖** ពាក្យនេះតាំងពីខ្ញុំចូលទៅរស់នៅក្នុងសម័យខ្មែរក្រហម គឺពាក្យនេះមានឮរហូតជាប់ត្រចៀក ជាប់ជានិច្ច។ តែបុគ្គលណា អ្នកប្រឌិតពាក្យនេះឡើង ឬអ្នកដាក់ពិន័យនៃពាក្យនេះឡើងក៏ខ្ញុំមិនបានដឹងដែរ ដឹងតែពីថ្នាក់លើ មេកង មេក្រុមខ្ញុំ ពេលប្រជុំថាអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ លោកស្រីអាចជម្រាបថា មេកង មេក្រុមដែលប្រជុំប្រាប់អ្នកស្រីពីពាក្យថា "ក្បាលអ្នកណាសក់អ្នកហ្នឹង" ធ្វើឡើងនៅពេលណាដែរ?

**ផ៖** ជាទូទៅៗប្រជុំសាមញ្ញ ១០ថ្ងៃម្ដង ប្រជុំធំមួយខែម្ដង។ ប្រជុំធំមីទ្ទិង គឺមានពាក្យហ្នឹងជាសាមញ្ញទូទៅ។

**ស៖** បាទ ដំបូងបំផុតអ្នកស្រីឮនៅពេលណាអាចបញ្ជាក់បានទេ?

**ផ៖** ឮពេលដែលចូលទៅដល់ក្នុងទឹកកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម៧៥ – ១៩៧៥ ឮរហូត។

**ស៖** បាទ សូមអរគុណ។ ពាក្យនេះមានការយល់ជ្រួតជ្រាបពីប្រជាជននៅទីនោះយ៉ាងដូចម្ដេច

ដែរ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ពាក្យនេះជាពាក្យមួយគួរឲ្យភ័យខ្លាច តក់ស្លុតជាទីបំផុត គឺមិនអាចមានអ្នកណាជួយអ្នកណាបានជាដាច់ខាត។

[១៤:១៧:១២]

**ស៖** បាទ សូមអរគុណ។ ពីម្សិលមិញម៉ោងប្រហែលដប់មួយកន្លះ លោកស្រីបានលើកអំពីឈ្មោះ អ៊ុំ វណ្ណារ៉ា ដែលលោកស្រីបានរៀបរាប់ពីការដែលលួចដំឡូងគេ ហើយក្រោយមកត្រូវគេយកទៅសម្លាប់។ អ្នកស្រីអាចបញ្ជាក់បានទេថា អ្នកស្រីបានដឹងពីការសម្លាប់នេះក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីការសម្លាប់?

**ឆ៖** ខ្ញុំបានដឹងរយៈពេលយូរ មកដល់ -- បងខ្ញុំមកប្រាប់ៗហ្នឹងមិនដឹងជាប្រហែលជាកន្លះខែជាង។ បងខ្ញុំគាត់នៅសំរោងៗហ្នឹងគាត់មកប្រាប់ថា ហូបមិនឆ្អែតលួចដកដំឡូងគេដុតហូបជាញឹកញាប់មិនមែនមួយដងពីរដងទេ លួចដកដំឡូងគេជាញឹកញាប់ ហើយត្រូវគេចាប់ចងសម្លាប់ហើយ ចងសម្លាប់។

**ស៖** បាទ សូមអរគុណ។ ក្នុងរយៈពេលចាប់ពីគេចាប់រហូតដល់ពេលសម្លាប់ហ្នឹង តើមានរយៈពេលប៉ុន្មានថ្ងៃដែរ អ្នកស្រីដឹងទេ?

**ឆ៖** រយៈពេលដែលគេចាប់ទៅសម្លាប់ គឺគេចាប់ទៅថ្ងៃហ្នឹង យប់ឡើងគេសម្លាប់ហើយ អត់មានទុកយូរទេ។ បងខ្ញុំថាគេចាប់យកទៅសម្លាប់ គេមិនដែលទុកយូរទេ យើងខ្លាំងលួចដំឡូង។

**ស៖** អ្នកស្រីដឹងថាអ្នកណា អ្នកសម្លាប់ទេ ពេលហ្នឹង?

**ឆ៖** គេនៅ១០៧ ហើយខ្ញុំនៅ១០៥ គឺខុសទីតាំងគ្នា។ ខ្ញុំមិនអាចដឹងអ្នកណាជាអ្នកសម្លាប់ខ្ញុំអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងប្ដីរបស់អ្នកស្រី – ប្ដីរបស់អ្នកស្រីមានស្រុកកំណើតនៅឯណាដែរ?

**ឆ៖** នៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** មានន័យថា នៅក្នុងស្រុកកំណើតជាមួយនឹងអ្នកស្រី។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស នៅស្រុកកំណើតជាមួយគ្នាពិតប្រាកដ។

**ស៖** ប្ដីរបស់អ្នកស្រីរស់នៅក្នុងស្រុកលាយបូរ -- ឃុំលាយបូរហ្នឹង ស្រុកត្រាំកក់ហ្នឹងក្នុងរយៈ

ពេលប៉ុន្មានឆ្នាំដែរមុននឹងចាកចេញ?

**ឆ៖** មុននឹងចាកចេញទៅនៅភ្នំពេញ ឬក៏មុនចាកចេញគេយកទៅសម្លាប់?

**ស៖** មុននឹងចាកចេញមកភ្នំពេញ។

**ឆ៖** មុននឹងចាកចេញមកភ្នំពេញ គាត់នៅរៀនៗអ៊ីចឹង ដល់គាត់រៀនហើយគាត់បួស។ ដល់គាត់បួសហើយ គាត់ប្រឡងចូលធ្វើការ ធ្វើការហើយបានគាត់ចាកចេញពីស្រុកកំណើត នៅភ្នំពេញ នៅកំពង់ស្ពឺៗហើយភ្នំពេញ-កំពង់ស្ពឺ-កំពង់ឆ្នាំង-ភ្នំពេញ។

**ស៖** បាទ អ្នកស្រីចាំឆ្នាំដែលគាត់ចាកចេញទៅធ្វើការទេ នៅឆ្នាំណា?

**ឆ៖** ខ្ញុំអត់បានចាំច្បាស់ទេ។ គាត់ចាកចេញទៅធ្វើការ ខ្ញុំនៅតូចៗ ខ្ញុំប្រហែលជាអាយុប្រហែល ១០ឆ្នាំអីហ្នឹង ខ្ញុំអត់ចាំទេ។

[១៤:២១:១៤]

**ស៖** ប្ដីអ្នកស្រីដែលត្រលប់ទៅលេងស្រុកហ្នឹងវិញទេ នៅពេលដែលចាកចេញហើយ?

**ឆ៖** ចាកចេញទៅធ្វើការ គាត់ត្រលប់មកលេងស្រុកជាការធម្មតា។ យើងមិនទាន់មានរបបខ្មែរក្រហម។ លេងស្រុកជាធម្មតាចាស។

**ស៖** ពីព្រឹកមិញ អ្នកស្រីបានជម្រាបអង្គជំនុំជម្រះថា ប្ដីអ្នកស្រីជាទាហាន។ អ៊ីចឹងមែនទេ?

**ឆ៖** ទាហានតែក្នុងរបបលន់ នល់ទេ។ បើសង្គមសម្ដេច កាលគាត់ទើបតែធ្វើការដំបូង គាត់ធ្វើប៉ូលិស។ គាត់ធ្វើប៉ូលិសហ្នឹងក៏គាត់មានរៀនច្បាប់ពេទ្យទៀត។ រៀនពេទ្យអ៊ីចឹង ដល់ពេលរបប លន់ នល់ គេឲ្យគាត់ធ្វើពេទ្យទាហានអ៊ីចឹងទៅ គាត់ចេះពេទ្យចាស។

**ស៖** បាទ សូមអរគុណ។ រយៈពេលដែលប្ដីលោកស្រីធ្វើជាប៉ូលិស ជាទាហាន ហើយនិងជាពេទ្យទាហានហ្នឹង សរុបទៅរយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** រយៈពេលយូរឆ្នាំណាស់ យូរឆ្នាំតាំងពី១៩៦០ ប៉ុន្មានទេ ១៩៦០ជាង តាំង៦៥-៦៦អី – ៦៤-៦៥ហ្នឹង។

**ស៖** បាទ អរគុណ។ អ៊ីចឹង សរុបមក ខ្ញុំអាចនិយាយបានថា មិនតិចជាង១០ឆ្នាំ។ ត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រុកខាងគ្រួសាររបស់លោកស្រី ក៏ដូចជាអ្នកភូមិរបស់អ្នកស្រីគេស្គាល់ប្រវត្តិរបស់ប្ដីអ្នកស្រីហ្នឹងទេ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** គេស្គាល់ច្បាស់ទាំងអ្នកថ្មីទាំងអ្នកចាស់ ស្គាល់ទាំងអស់ ស្គាល់គាត់ធ្វើប៉ូលិស ហើយដល់សង្គមលន់នល់ គាត់ធ្វើជាទាហាន ពេទ្យទាហាន។ គេស្គាល់គ្រប់គ្នាទាំងអស់ទាំងអ្នកថ្មីទាំងអ្នកចាស់ ព្រោះស្រុកនៅហ្នឹងដូចគ្នា ចាស។

[១៤:២៤:០០]

**ស៖** បាទ សូមអរគុណ។ ពីព្រឹកមិញ តាមខ្ញុំបានស្តាប់ចម្លើយរបស់អ្នកស្រីឆ្លើយជាមួយនឹងអង្គជំនុំជម្រះ ថាគ្រួសារអ្នកស្រីត្រូវបានគេចាប់ក្រោយពីគេឆែកឃើញមានស័ក្តិនៅក្នុងហោប៉ៅអាវ។ តើអ្នកស្រីមានប្រសាសន៍អ៊ីចឹងមែនទេ?

**ឆ៖** ចាស មែន ឆែកឃើញរូបថតមានពាក់ស័ក្តិនៅក្នុងហោប៉ៅអាវ។

**ស៖** បាទ ខ្ញុំសូមឲ្យច្បាស់ថាឃើញរូបថតដែលមានពាក់ស័ក្តិ មិនមែនឃើញស័ក្តិទេ។ អ៊ីចឹងមែនទេលោកស្រី?

**ឆ៖** ឃើញរូបថតមានពាក់ស័ក្តិ រូបថតគេស្គាល់ រូបថត មុខហ្នឹងស័ក្តិហ្នឹង គេស្គាល់ហើយ។ ដល់ពេលយប់ឡើងគេមកចាប់យកទៅតែម្តង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចពន្យល់បានទេថា ហេតុអីបានជាអ្នកស្រុកគេស្គាល់ប្រវត្តិរបស់ប្តីអ្នកស្រីក្នុងរយៈពេលកន្លងមក នៅពេលដែលតាំងពីអ្នកស្រីជម្លៀសពីភ្នំពេញទៅនៅក្នុងឃុំលាយបូរ រហូតមកដល់មុនពេលឃើញរូបថតដែលមានពាក់ស័ក្តិហ្នឹង គេមិនបានធ្វើអ្វីប្តីអ្នកស្រី ហើយរហូតដល់ពេលឃើញរូបថត ទើបគេចាប់ខ្លួន។ តើអ្នកស្រីអាចពន្យល់បានទេ ថាហេតុអីបានជាការដឹងពីប្រវត្តិក្នុងរយៈពេលកន្លងមក គេអត់បានធ្វើអ្វីប្តីអ្នកស្រី រហូតមកដល់ពេលឃើញរូបថតទើបគេចាប់ប្តីអ្នកស្រី?

**ឆ៖** ខ្ញុំសូមពន្យល់ប្រាប់ឲ្យច្បាស់។ មកដំបូងគេសួរប្រវត្តិរូបយើង យើងអត់មានបានប្រាប់គេថាយើងធ្វើពេទ្យទាហានមានពាក់ស័ក្តិទេ។ យើង គេកត់ប្រវត្តិ ប្រាប់គេថាយើងធ្វើជាពេទ្យៗ នៅពេទ្យព្រះកេតុមាលា ពេទ្យបុរីកីឡាព្យាបាលអ្នករបួសទូទៅ។ ហើយក៏រួចអ៊ីចឹងទៅ អត់មានអីទេ។ ដល់ពេលផាត់ចេញពីភូមិ -- នៅចុះមកដល់លាយបូរ បញ្ជូនមកនៅជិតសាលាឃុំ ខាងជើងសាលាឃុំលាយបូរ គេត្រូវអនុវត្តឆែកឆេរម្តងទៀត ពួកអ្នកថ្មីចូលមកដល់។ គេអនុវត្តឆែកឆេរម្តងទៀត ក៏គេឃើញរូបថតនៅក្នុងហោប៉ៅអាវ ដែលចាក់ចេញរើពីបង្វិចយើងទាំងអស់ ចាក់ចេញទៅហោប៉ៅអាវហ្នឹង ក៏អាកូនៗវាខោអាវព្យួរៗ ប្រមូលច្រកស្បោងៗ ដោយមកទាំងរូបថត។ ចាស ដល់ឃើញរូបថតអ៊ីចឹង អាហ្នឹងគេ

ថា យើងមានបុណ្យស័ក្តិអត់មានប្រាប់អង្គការទេ គេក៏យកទៅពេលយប់។

[១៤:២៧:១៥]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានប្រសាសន៍អំមិញថា មានអ្នកថ្មីចូលមក។ ពាក្យថា "អ្នកថ្មីចូលមក" នេះ អ្នកស្រីចង់សំដៅទៅអ្នកថ្មីណា? អ្នកដឹកនាំ ជាកម្មាភិបាលថ្មី ឬក៏ប្រជាពលរដ្ឋថ្មី?

**ឆ៖** អ្នកថ្មី ពួកអ្នក១៧មេសា ចេញមកពីភ្នំពេញ។ ហ្នឹងគេហៅពួកអ្នកថ្មី ១៧មេសា។ ពួកគេជាអ្នកមូលដ្ឋានចាស់ គេមកឆែកឆេរ ពួកអ្នកថ្មី ១៧មេសា ចូលមកនៅភូមិគេ ចាស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចពន្យល់ពីប្រជាពលរដ្ឋបន្តិចទេ អំមិញលោកស្រីមានប្រសាសន៍អំពីអ្នក១៧មេសា ហើយកាលពីព្រឹកមិញ និងម្សិលមិញជាដើម ខ្ញុំបានឮអ្នកស្រីរៀបរាប់អំពីអ្នក១៨។ តើ១៨ នេះ អ្នកស្រីចង់សំដៅទៅ ១៨អី? ហើយជាមនុស្សយ៉ាងម៉េច បាទ?

**ឆ៖** ១៨ ជាអ្នកចាស់ អ្នកមូលដ្ឋាន។ អ្នកមូលដ្ឋានគេហៅអ្នក១៨។ យើងថ្មីសុទ្ធតែពួកចេញមក ១៧មេសា អ្នកថ្មី។ គេហៅ "មីថ្មុតសី–ពួកមីថ្មុតសី" ចាស។

**ស៖** សុំទោសអ្នកស្រី ខ្ញុំអត់យល់ពាក្យថា "ថ្មុតសី" អ្នកស្រីអាចពន្យល់ពាក្យនេះបានទេ?

**ឆ៖** ពួកអ្នកថ្មីសុទ្ធ ពាក្យបកប្រែ "អ្នកថ្មីសុទ្ធ" ជាពាក្យដែលគេកំពុងនឹងសម្រិតសម្រាំង។ គេអ្នកចាស់ យើងអ្នកថ្មី គេហៅ "ថ្មីសុទ្ធ"។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅចំណុចមួយទៀតទាក់ទងទៅនឹងករណីមួយដែលអ្នកស្រីបានរៀបរាប់ជូនអង្គជំនុំជម្រះពីស្ត្រីម្នាក់ដែលបានវះពោះប្តីរបស់ខ្លួន អ្នកស្រីនៅចាំបានករណីហ្នឹងទេ?

**ឆ៖** ចាំបាន។ ចាស វះពោះប្តីរបស់ខ្លួនឯង។

[១៤:២៩:៥៤]

**ស៖** បាទ អ្នកស្រីបានជម្រាបរួចហើយថា អ្នកស្រីបានដឹងករណីនេះពី -- តាមរយៈជីដូនរបស់ជាប្តី។ ខ្ញុំសូមសួរបន្ថែមថា តើអ្នកស្រីដឹងនៅពេលណា ក្រោយពីការចាប់ខ្លួនសម្លាប់ភ្លាម ឬមួយក៏ក្នុងរយៈពេលមួយដូចលោកស្រីបានជម្រាបជូនករណី សុវណ្ណា នោះបាទ?

**ឆ៖** ដឹងនៅពេលដែលខ្មែរក្រហមគេវ៉ៃបែកទីក្រុងតាកែវៗហើយ បែក -- រំដោះកងទ័ពវៀត-ណាមមករំដោះហើយ រំដោះខ្មែរក្រហម រំដោះយើងចេញពីនឹមខ្មែរក្រហម បានជាជីដូនហ្នឹងមកប្រាប់ម្តាយខ្ញុំនៅជើងសានត្រាណនេះ ជើងសានត្រាណប្រហែលជាឆ្នាំ៨២ -- ៨១-៨២។ ឆ្នាំ១៩៨០-៨១ គាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មក១ប្រាប់។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ចម្លើយរបស់អ្នកស្រីឡើងវិញ។ គឺអ្នកស្រីបានដឹងពីករណីនេះរហូតមកដល់ឆ្នាំ៨២ ហើយ មិនមែនលោកស្រីដឹងនៅពេលព្រឹត្តិការណ៍កើតឡើងភ្លាមៗទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ ខ្ញុំទើបតែដឹង៨១-៨២ហ្នឹង ព្រោះគាត់បានដល់ -- គាត់មកប្រាប់ៗម្ដាយខ្ញុំជាជីដូនដូចគ្នា។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមចូលប្រធានបទមួយទៀត ទាក់ទងទៅនឹងការ -- ពេលដែលលោកស្រីបានឃើញមេដឹកនាំរបស់ខ្មែរក្រហមទៅកន្លែងការដ្ឋានរបស់អ្នកស្រី–កន្លែងដែលអ្នកស្រីធ្វើការ។ អ្នកស្រីបានជម្រាបជូនសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន អម្បាញ់មិញថា លោកស្រីបានឃើញរថយន្តពីរគ្រឿងដែលមួយគ្រឿងជារថយន្តរបស់ តាម៉ុក មួយគ្រឿងទៀតជារថយន្តដែលមាន ប៉ុល ពត, នួន ជា និង ខៀវ សំផន ជិះ។ ហើយលោកស្រីបានបញ្ជាក់ថារយថយន្តរបស់ តាម៉ុក ជារថយន្តហ្ស៊ីប។ ហើយអ្នកស្រីមើលមិនឃើញទេនៅក្នុងនោះថា មានអ្នកណាខ្លះនៅខាងក្នុងដោយសាររថយន្តពណ៌ខ្មៅ មានកញ្ចក់ពណ៌ខ្មៅ។ អ្នកស្រីអាចបញ្ជាក់បានទេថា រថយន្តដែល១ចតនោះ ទាំងពីរនោះនៅចម្ងាយប៉ុន្មានពីអ្នកស្រី?

[១៤:៣២:៥២]

**ឆ៖** ចម្ងាយប្រហែល ១០០ម៉ែត្រ។ រថយន្ត តាម៉ុក មានតែគាត់ម្នាក់ឯងទេ គាត់ចុះមករថយន្តនៅទទេស្អាត។

**ស៖** អ៊ីចឹង ខ្ញុំបញ្ជាក់ឡើងវិញថា រថយន្តនោះនៅចម្ងាយ ១០០ម៉ែត្រ។ ហើយរថយន្ត តាម៉ុក មានតែម្នាក់ឯងទេ អត់មាននរណានៅក្នុងហ្នឹងទេ។ បានន័យថា អត់មានសូហ្វ័រ ឬក៏តែកុងឡានជាអ្នកបើកបរឲ្យគាត់ទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** រថយន្ត តាម៉ុក ហ្នឹងមានកញ្ចក់បាំងជុំវិញទេ អ្នកស្រី?

**ឆ៖** ឡានហ្ស៊ីបអត់មានកញ្ចក់ទេ មានតែកញ្ចក់ពីមុខ ដល់ចំហៀងប្រហោងធ្លុង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង នៅពេលដែលអ្នកស្រីឆ្លើយជាមួយនឹងមេធាវីអង់តា ហ្គីសសេ អម្បាញ់មិញនេះគឺមិនសំដៅទៅលើឡានរបស់ តាម៉ុក ទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំឆ្លើយរថយន្តខ្មៅ សំដៅឡានរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ តែឡានហ្ស៊ីប ឡានតាម៉ុក។ តែលោកសួរពីឡានខ្មៅ ខ្ញុំឆ្លើយឡានខ្មៅ។

**ស៖** បាទ អរគុណ។ ក្នុងចម្ងាយ ១០០ម៉ែត្រដែល--

[១៤:៣៤:២៩]

**ប្រធានអង្គជំនុំ៖**

លោក១ មេធាវីអាចឲ្យមានពេលវេលាឃ្លាតបន្តិច ដើម្បីឲ្យមានការបកប្រែហ្នឹងបានបកប្រែទាន់ ព្រោះគាត់និយាយចប់ទៅបកប្រែមិនទាន់អស់ផង លោកមេធាវីចាប់ផ្ដើមទៅមិនធ្វើឲ្យមានការបញ្ឈប់ស្ដាប់ផ្នែកខាងភាសាបកប្រែ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ្នកស្រីអាចបញ្ជាក់បានទេថា ឡានទាំងពីរគ្រឿងដែលអ្នកស្រីបានឃើញហ្នឹងចតនៅទីតាំងដូចម្ដេចដែរ?

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** ចតនៅចិញ្ចើមថ្នល់កាច់ជ្រុង១ផ្លូវបត់មកពីភ្នំពេញផ្លូវជាតិលេខ២។

**ស៖** នៅលើផ្លូវជាតិលេខ២ហ្នឹងតែម្ដង ឬក៏មានផ្លូវផ្សេងទៀតនៅក្បែរផ្លូវជាតិលេខ២?

**ឆ៖** ផ្លូវជាតិលេខ២អត់មានផ្លូវផ្សេងទៀតទេ គឺផ្លូវជាតិលេខ២មកពីភ្នំពេញហើយបត់មកលិច គឺបត់ទៅស្រុកត្រាំកក់ គាត់ចតនៅផ្លូវបត់មកលិច ឡានមុខទៅលិច។

**ស៖** បាទ អ៊ីចឹងខ្ញុំសូមសួរបញ្ជាក់លោកស្រី។ លោកស្រីបញ្ជាក់ថាកន្លែងដែលឡានចតនោះគឺមានទីតាំងនៅលើផ្លូវពីលិចទៅកើត។ បានន័យថាពីចេញ ពីទីរួមខេត្តតាកែវទៅខាងអង្គតាសោម។ តើអ៊ីចឹងត្រឹមត្រូវទេ?

[១៤:៣៦:២១]

**ឆ៖** ត្រឹមត្រូវចាស១។

**ស៖** បាទ អរគុណ។ អ៊ីចឹងមិនមែនពីផ្លូវពីភ្នំពេញបត់ទៅរកខេត្តតាកែវទេហ្ន៎? ខ្ញុំចង់បញ្ជាក់អាហ្នឹងឲ្យបានច្បាស់។

**ឆ៖** ចាស មិនមែនទេ ជាផ្លូវបត់ទៅឃុំលាយបូរ សំដៅកង១ ផ្លូវបត់ទៅលិច។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេពីរយៈផ្លូវ ពីផ្លូវកែងបត់ផ្លូវជាតិលេខ២ ដែលផ្លូវមួយបត់ទៅទីរួមខេត្តតាកែវ ហើយផ្លូវមួយទៀតមកខាងភ្នំពេញ ហើយរយៈពីផ្លូវបត់ពីកែងហ្នឹង មកអង្គតាសោមហ្នឹង តើកន្លែងដែលឡានចតហ្នឹងនៅចំៗកន្លែងណា? ទីតាំងប្រហែលប៉ុន្មាន? ជាចំណុចកណ្តាល ឬមួយក៏វាកៀកទៅខាងណាជាង អ្នកស្រីអាចពន្យល់បានទេ?

**ឆ៖** ឡានឈប់ចំណុចកៀកមកខាងខេត្តតាកែវ។ ចាស បើដល់សាលាឃុំលាយបូរ គឺពាក់កណ្តាលតាកែវ អង្គតាសោម។

**ស៖** បាទ សូមអរគុណ។ ពេលដែលឡានឈប់នោះគឺឡានហ្នឹងឈប់បែរមុខទៅលិច។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** អ្នកស្រីមានឃើញអ្នកណាផ្សេងទៀត ក្រៅពីក្រុមឡានពីរគ្រឿងហ្នឹងដែលមកមុន ឬក៏ក្រោយឡានហ្នឹងក្នុងរយៈពេលខ្លី បានន័យថាអាច ១០នាទី ២០នាទី ឬកន្លះម៉ោង បានន័យថាក្នុងពេលព្រឹកនៅថ្ងៃហ្នឹងតែមួយ។ មាន លោកស្រីមានឃើញក្រុមណាមកមុន ឬក៏ពេលក្រោយហ្នឹងទេ?

**ឆ៖** អត់ៗមានទាំងអស់ គឺថ្នល់គឺស្ងាត់ឈឹងអត់មានទេ មានតែរទេះសេះគេបរដឹកអីៗគេ អត់មានអ្នកធ្វើដំណើរដោយម៉ូតូ ដោយឡាន ឬកង់អីអត់មានទេ ស្ងាត់ជ្រងំ។

**ស៖** បាទសូមអរគុណ។ នៅពេលដែលឡានឈប់ ហើយចត អ្នកស្រីបានឃើញឡានហ្នឹងឈប់ ហើយចតទេ ឬមួយក៏អ្នកស្រីពេលដែលមើលទៅឃើញមនុស្សដើរចេញពីក្នុងឡានហ្នឹងរួចទៅហើយ?

[១៤:៣៩:១៧]

**ឆ៖** ខ្ញុំឃើញៗពេលឡានហ្នឹងមកៗពីជើងមកអ៊ីចឹង ឡានមកដល់បរតិចៗអ៊ីចឹងឈប់។ រួចដល់ពេលឡានបរតិចៗដល់ឈប់ហើយ គេនាំគ្នាមើលឃើញ គេមើលឃើញ ក៏ខ្ញុំក៏មើលឃើញ ឡានឈប់ក៏ឃើញគាត់ចុះមកចុះពីលើឡាន។

**ស៖** បាទ សូមអរគុណ។ ពេលឡានបរមកហ្នឹង អ្នកស្រីនៅក្បែរនរណាខ្លះក្នុងកន្លែងការដ្ឋានអ្នកស្រី មានមិត្តភក្តិផ្សេងទៀតដែលនៅជាមួយអ្នកស្រីទេ? នៅក្បែរអ្នកស្រីទេ?

**ឆ៖** មានច្រើន ព្រោះជាអ្នកធ្វើពលកម្ម រែកដី អ្នកខ្លះអ្នកកាប់ អ្នកខ្លះដាក់បង្គីរែកច្រើន ច្រើនគ្នា។

**ស៖** បាទ សូមអរគុណ។ អ្នកទាំងអស់នោះ មានចាប់អារម្មណ៍ពីរឿងឡានដែលបើកមកដល់ហ្នឹងទេ? ហើយមានបាននិយាយគ្នាថាម៉េចខ្លះ?

**ផ៖** និយាយគ្នា ដូចខ្ញុំបានជម្រាបហើយខាងលើថា "ពួកលោកមេដឹកនាំរដ្ឋកម្ពុជា អ្នកដឹកនាំនៅកម្ពុជាភ្នំពេញ អ្នកដឹកនាំប្រទេសស្មើហ្នឹងប្រមុខរដ្ឋ បានចុះមកមើលការដ្ឋានយើងជាគំរូ ព្រោះអីការដ្ឋានលាយបូរ ភូមិលាយបូរជាគំរូ ធ្វើការបានល្អ មានផលប្រយោជន៍ស្រូវបានល្អ" គេនិយាយអ៊ីចឹង។

**ស៖** បាទ អរគុណ។ លោកស្រីចាំបានថា អ្នកណាអ្នកនិយាយអ៊ីចឹង ឬក៏និយាយទាំងអស់គ្នា?

**ផ៖** មេកង ប្រធានភូមិ ប្រធានក្រុម អ្នកនិយាយ។

**ស៖** អំមិញអ្នកស្រីរៀបរាប់ មេកង ប្រធានក្រុម មេភូមិ។ អ៊ីចឹងបីនាក់ ឬក៏មានច្រើនជាងហ្នឹងទៀត?

[១៤:៤១:៣៨]

**ផ៖** ក្នុងមួយក្រុមហ្នឹង មានតែប្រធានក្រុមមួយទេ ដែលប្រធានភូមិមួយហ្នឹង គេឈរខាងក្រុមមេម៉ាយបន្តិច ក្រុមនោះបន្តិចៗ ហើយមេក្រុម មួយក្រុមហ្នឹង គឺ១០នាក់ហ្នឹង មេក្រុមតែមួយទេ។ ហើយដែលក្រុមទៀត គេក្តោបក្តាប់ ក្រុមខ្លះ១០នាក់ ក្រុមខ្លះ១២នាក់អ៊ីចឹងទៅ។

**ស៖** បាទ សូមៗទោស ខ្ញុំសូមកាត់។ ខ្ញុំចង់ដឹងពីចំនួនអ្នកដែលនិយាយថា "មេដឹកនាំមកពីភ្នំពេញមកមើល"។ ខ្ញុំចង់ដឹងពាក្យហ្នឹងថាអ្នកណាខ្លះ អ្នកបាននិយាយ។ អ្នកស្រីអាចរៀបរាប់បានទេ?

**ផ៖** ខ្ញុំរៀបរាប់បាន។ ប្រធានកង ហើយនិងប្រធានភូមិ។ ចាស គាត់អ្នកនិយាយ។

**ស៖** បាទ មេកង មេភូមិ ហើយមេក្រុមអត់និយាយទេ។

**ផ៖** មេក្រុមក៏និយាយដែរ និយាយទាំងអស់។

**ស៖** និយាយក្នុងពេលតែមួយ ឬក៏និយាយផ្លាស់គ្នាម្តងម្នាក់ៗ?

**ផ៖** និយាយពេលតែមួយហ្នឹង ពេលថ្ងៃដែលគាត់ចុះការដ្ឋានហ្នឹង ថ្ងៃតែមួយហ្នឹង។

**ស៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

បាទ ឥឡូវដល់ពេលម៉ោងសមរម្យសមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដើមបណ្តឹងរដ្ឋប្បវេណី ដល់រូបដើមបណ្តឹងរដ្ឋប្បវេណីរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅកន្លែងផ្តល់សក្ខីកម្មនេះវិញ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សម្រាកសិនចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរជាចុងក្រោយចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណលោកប្រធាន។

ជម្រាបសួរ។ បាទ ឥឡូវខ្ញុំសួរពេលវេលាសួររបស់ខាងភាគីការពារក្តីព្រោះថា ឥឡូវនេះរយៈពេល ២ម៉ោង <៤០>នាទី ហើយដែលគាត់សួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះហើយ ខាងព្រះរាជអាជ្ញានេះ យើងបានប្រើតែ ២ម៉ោង ១០នាទីទេ <គឺគិតទៅបានតែពីរវគ្គត្រឹម>។ អ៊ីចឹងៗ ខ្ញុំគិតថា មើលទៅដូចជាខាងភាគីការពារក្តីនេះប្រើពេលវេលាហ្នឹងវាហួសទៅហើយ។ អ៊ីចឹងចង់ដឹងថាតើគាត់សួរដល់រយៈពេលប៉ុន្មានទៀត? អ៊ីចឹង សូមឲ្យអង្គជំនុំជម្រះធ្វើការសម្រេចមើលទៅ ថាតើត្រូវបន្តឲ្យសួរទៀត ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

យើងអនុញ្ញាតឲ្យសួរទៀត ដោយសារមូលហេតុនៃពេលវេលាដែលត្រូវបានទៅភាគីមេធាវី

ការពារក្ដីសួរត្រូវថៅក្រមចំណាយអស់ ៥០នាទី ក្នុងការតាំងសំណួរ ដែលប្រើប្រាស់ពេលវេលាសម្រាប់មេធាវីការពារក្ដី។

សូមអញ្ជើញលោកមេធាវី!

[១៥:០៣:៣៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមអនុញ្ញាតបន្តសួរ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ្នកស្រី មុននឹងសម្រាកយើងបានជជែកគ្នាអំពីការមកទស្សនកិច្ចរបស់អ្នកដឹកនាំក្នុងសម័យ ខ្មែរក្រហមនៅក្នុងការដ្ឋានរបស់អ្នកស្រី។ ហើយជាពិសេសយើងបានជជែកគ្នាអំពីពេលដែលមកដល់ គឺពេលដែលចត ឈប់ឡាន បាទ។ ខ្ញុំសូមសួរបន្ថែមថានៅពេលដែលអ្នកទាំងបីនាក់ អ្នកទាំងបួននាក់ អាចថាទាំង តាម៉ុក គាត់មកក្នុងពេលតែមួយ ឬមួយក៏ឡានពីរហ្នឹងមានឡានណាមកដល់មុនក្រោយ។ អ្នកស្រីអាចបញ្ជាក់បានទេ?

**លោកស្រី ជូ គឹមឡូន៖**

**ឆ៖** ពេលខ្ញុំក្រឡេកមើលទៅឃើញឡានគាត់ឈប់ទាំងពីរនាក់ ឡានគាត់ឈប់មុខ ឡានតាម៉ុកឈប់ក្រោយ ពីក្រោយ។

**ស៖** បាទ សូមអរគុណ។ ក្រោយពីឡានទាំងពីរនោះឈប់អ្នកស្រីឃើញអ្នកដែលនៅក្នុងឡានហ្នឹងចុះដំណាលគ្នាតែម្ដង។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** ពេលដែលគាត់ចុះពីលើឡានមក គាត់ធ្វើដំណើរចេញទៅខាងណា? ខាងត្បូង ឬក៏ខាងជើងផ្លូវ?

**ឆ៖** គាត់ធ្វើដំណើរពីខាងជើងផ្លូវ ខាងស្ដាំដៃ។ គាត់និយាយគ្នាជាមួយ តាម៉ុក។ ដើរបណ្ដើរនិយាយគ្នាបណ្ដើរ ចង្អុលក្នុងប្រឡាយ។

**ស៖** បាទ សូមបញ្ជាក់ម្ដងទៀតថា គាត់ដើរតម្រង់ទៅទិសខាងជើង។ តើអ៊ីចឹងមែនទេអ្នកស្រី?

**ឆ៖** គាត់ដើរតម្រង់ទៅទិសខាងលិច តែគាត់ដើរពីខាងស្ដាំដៃ។ ដើរទៅលិច ដើរថ្នល់ហ្នឹង ទៅលិច គាត់ដើរពីខាងស្ដាំដៃ។ ព្រោះការដ្ឋានខ្ញុំជីកប្រឡាយពីខាងជើងផ្លូវថ្នល់ជាតិ។

**ស៖** បាទ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឡើងវិញ។ នៅពេលដែលគាត់ទាំងបួននាក់ចុះពីលើរថយន្តគឺគាត់ទៅទិសខាងលិច។ បានន័យថា ដើរនៅលើចិញ្ចើមផ្លូវជាតិ។ តើអ៊ីចឹងត្រឹមត្រូវទេ?

[១៥:០៦:១៩]

**ឆ៖** គាត់ដើរចុះពីថ្នល់ជាតិ លើចិញ្ចើមមាត់ប្រឡាយ។ គាត់ដើរចុះពីថ្នល់ជាតិ លើចិញ្ចើមប្រឡាយ ជិតពលករវែកដីដែរហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង គាត់ចុះពីផ្លូវជាតិដើរលើចិញ្ចើមមាត់ប្រឡាយ។ តើចិញ្ចើមមាត់ប្រឡាយនោះ ពីត្បូងទៅជើង ឬពីលិចទៅកើត? អ្នកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចិញ្ចើមមាត់ប្រឡាយ គឺចិញ្ចើមទៅលិច ដើរទៅលិច។ ចិញ្ចើមមាត់ -- លើទំនប់ ទំនប់ប្រឡាយហ្នឹង យើងវែកក្នុងប្រឡាយចាក់លើទំនប់ ប៉ុន្តែទំនប់ហ្នឹងមានទំហំធំណាស់។ គាត់ដើរលើទំនប់ហ្នឹងទៅលិច។ ចិញ្ចើមទំនប់ ត្រង់ត្បូងកន្លែងយើងកំពុងតែធ្វើពលកម្ម។ ទៅលិច។

**ស៖** បាទ សូមអរគុណ។ លោកស្រីថា ដើរទៅលិច ដើរស្របនឹងផ្លូវជាតិ ឬក៏កាត់ទទឹងនឹងផ្លូវជាតិដែលលោកស្រីមានប្រសាសន៍អម្បាញ់មិញនេះ?

**ឆ៖** ដើរបណ្តោយផ្លូវជាតិ។ តែសំណួរនេះបញ្ជាក់ច្រើនសាហើយ។ ដើរបណ្តោយផ្លូវជាតិទៅលិច ទៅស្រុកត្រាំកក់។ ទៅអង្គតាសោមនេះ បញ្ជាក់បីសាហើយ។

**ស៖** បាទ ពីព្រោះខ្ញុំអត់ៗយល់ច្បាស់ ពីព្រោះលោកស្រីថាចុះពីផ្លូវជាតិ។ អ៊ីចឹងបើចុះពីផ្លូវជាតិវាត្រូវចុះទៅតាមផ្លូវណាមួយ។ ចុះតាមមាត់ប្រឡាយ ដែលអ្នកស្រីបញ្ជាក់អម្បាញ់មិញនេះណ៎ះ! អ៊ីចឹងបើមាត់ ចុះទៅមាត់ប្រឡាយ បើសិនជាប្រឡាយហ្នឹងវាស្របនឹងផ្លូវជាតិ ម៉េចអាចចុះទៅបាន។ វាទាល់តែផ្លូវហ្នឹងវាកាត់ផ្លូវជាតិ បានអ្នកស្រីអាចដើរកាត់លើផ្លូវប្រឡាយហ្នឹងបាន។ អ៊ីចឹង បានខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថាតើប្រឡាយហ្នឹង វាស្របនឹងផ្លូវជាតិ ឬមួយក៏វាកាត់ទទឹងនឹងផ្លូវជាតិ? អ្នកស្រីយល់សំណួរខ្ញុំទេ?

[១៥:០៨:៥២]

**ឆ៖** ផ្លូវថ្នល់កៅស៊ូ វានៅថ្នាក់លើ ដល់ចិញ្ចើមថ្នល់កៅស៊ូ វាចុះមកអ៊ីចេះ គេវែកប្រឡាយអ៊ីចេះវែកចាក់លើទំនប់ប្រឡាយ ស្របផ្លូវជាតិ។ ហើយគាត់ចុះពីថ្នល់កៅស៊ូ គាត់ដើរលើទំនប់ប្រឡាយ។ ប្រឡាយដែលយើងកំពុងតែវែកចាក់ ចាស។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង បានន័យថាប្រឡាយនោះស្របនឹងផ្លូវជាតិ។ អ្នកស្រីអាច

បញ្ជាក់អ៊ីចឹងបានទេ?

**ឆ៖** ចាស ស្របផ្លូវជាតិ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ចម្ងាយដែលគាត់ដើរពីឡាន ហើយដើរលើទំនប់ហ្នឹង ប្រវែងប៉ុន្មានម៉ែត្រដែរ រហូតមកដល់ផុតពីអ្នកស្រី? ដើរ គាត់ដើររហូត -- ខ្ញុំនិយាយអំពីការដែលគាត់ដើរ អត់និយាយពីពេលដែលគាត់ឈប់ទេ។ តើដើរហ្នឹងដើរក្នុងចម្ងាយប្រហែលប៉ុន្មាន? អ្នកស្រីអាចចាំបានទេ?

**ឆ៖** គាត់ៗដើរហ្នឹង ខ្ញុំឃើញគាត់ដើរចុះពីឡានគាត់មក គាត់ដើរឆ្លងកាត់មុខសញ្ញាខ្ញុំ ហើយឆ្លងកាត់មុខសញ្ញាទៅលិចៗទៀត ហើយក៏សន្និដ្ឋានថាខ្ញុំលែងបានមើលគាត់ហើយ គាត់ដើរឆ្លងកាត់មុខសញ្ញាដែលពលករធ្វើការរែកទាំងអស់នោះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានពេលប្រាំនាទីទៀតក្នុងការសួរនេះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកស្រីមានឃើញមានអ្នកណាទៅទទួលក្រុមទាំងបួននាក់ហ្នឹងទេ?

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** ចាស មាន។ នៅកងមុខខ្ញុំហ្នឹង គឺក្រុមកងយុវជនៗ និងមេកងយុវជន ហើយនិងមេក្រុមមេកងយុវជនគេចាប់ផ្តើមឃើញមុនគេ។ ហើយបានជាមេកងតាមមុខសញ្ញាខ្ញុំ បានទៅទទួលគេទាំងអស់គ្នាចាស។

**ស៖** បាទ សូមអរគុណ។ គេដើរមកដល់ហើយ បានចេញទៅទទួល ឬមួយក៏ទៅទទួលពីចុះពីឡានភ្លាម?

**ឆ៖** ចុះពីឡានៗ ពេលដែលគាត់ចុះពីឡាន ដល់ហើយបានកង ប្រធានកងយុវជនបានទៅជាក្រោយ គាត់ចុះបានមួយសន្ទុះ។ អ៊ីចឹងបានកងមេកងៗគេទៅទទួលគាត់បណ្តើរគាត់តាមមាត់ប្រឡាយ។

**ស៖** បាទ សូមអរគុណ។ មួយសន្ទុះហ្នឹងបើគិតជាសាច់ដែលគាត់ដើរវិញបានចម្ងាយដីប៉ុន្មាន?

[១៥:១២:២១]

**ឆ៖** គាត់ចុះដើរមួយសន្ទុះ បានចម្ងាយប្រហែលយើងទៅៗមាត់ទ្វា ត្រឹមហ្នឹង ត្រឹមជិតហ្នឹង។ ដល់ហើយមេកងយុវជន និងគណៈគេអ្នកនៅត្រួតពិនិត្យហ្នឹងគេឃើញ គេចុះទៅទទួលគេទទួលគាត់ចុះមកពិនិត្យត្រួតពិនិត្យមាត់ប្រឡាយដើរទៅលិចតាមស្របថ្នល់ជាតិ។

**ស៖** បាទ អរគុណ។ អ្នកស្រីអាចបញ្ជាក់បានច្បាស់ទេថាពេលហ្នឹងអ្នកស្រី ក៏ដូចជាក្រុមរបស់អ្នកស្រីក្នុងកងរបស់អ្នកស្រីហ្នឹងកំពុងធ្វើអី?

**ឆ៖** ខ្ញុំបានបញ្ជាក់ច្រើនសា ច្រើនលើក ថាខ្ញុំកំពុងតែជីកប្រឡាយ កាប់ដី រែកដី។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E3/ --

**ប្រធានអង្គជំនុំ៖**

កុំអាលទទួល កុំអាលសាកសួរ។ សូមអញ្ជើញលោកស្រី ហើយមានបញ្ហាអ្វីទៅលោកស្រីគួរតែត្រូវបានជំទាស់ទៅលើការអ្វីដែលមេធាវីសួរសំណួរ។ ឥឡូវលោកស្រីចង់និយាយរឿងអី?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងមិនមែន<និយាយថាជា>សំណួរច្រំដែលៗទេ <ប៉ុន្តែ>វាហួសពីច្រំដែលទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយបួន -- បីបួនដងហើយទៅនឹងសំណួរប្រភេទហ្នឹង។ ហើយខ្ញុំគ្រាន់តែសុំឱ្យ អស់លោក លោកស្រីថៅក្រម <ក្រើនរំឭកដល់មេធាវីការពារក្តីចំពោះ កុំឱ្យ>តាំងសំណួរដដែល<ៗ>នេះទៅលើដើមបណ្តឹងរដ្ឋប្បវេណី<រូប>នេះ<ទៀត>។

[១៥:១៤:០៨]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីការពារក្តីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីមានសិទ្ធិពេញទីក្នុងការជំទាស់ទៅនឹងការតាំងសំណួរដេញដោយរបស់ភាគីម្ខាងទៀតដោយមិនពឹងផ្អែកទាំងស្រុងមកលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទេ។ ប៉ុន្តែយើងអង្គុយរហូតមកដល់ម៉ោងនេះ លោកស្រីអត់មានតជំទាស់អំពីបញ្ហាថាសំណួរនេះគឺជាសំណួរច្រំដែលទេ។ នីតិវិធីបើកចំហានៅក្នុងភាគីដែលជំទាស់តវ៉ាទៅនឹងការតាំងសំណួររបស់ភាគីម្ខាងទៀត។ នោះអង្គជំនុំជម្រះនឹងពិចារណាសម្រេច។

សូមអញ្ជើញ!

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ឯកសារដែលសហមេធាវីអន្តរជាតិបានជូនអ្នកស្រីមុននេះ គឺឯកសារ E3/5635 ត្រង់កថាខណ្ឌ២០។ ខ្ញុំសូមអានជូននៅផ្នែកដំបូង៖ "ខ្ញុំមិនធ្លាប់បានឃើញ ប៉ុល ពត, នួន ជា និង តាម៉ុក ពីមុនមកទេ។ ក៏ប៉ុន្តែខ្ញុំបានស្គាល់ថាពួកគេជានរណា ព្រោះនៅមុនពួកគេ មេដឹកនាំទាំងបួនបានចុះមកការងារការដ្ឋានរបស់ខ្ញុំមួយថ្ងៃ ប្រធានកងចល័តរបស់ខ្ញុំបានប្រាប់ថាពួកមេ ដឹកនាំ

ទាំងប្អូននាក់នឹងចុះមកពិនិត្យការដ្ឋានការងារនោះ និងប្រាប់ឲ្យពួកយើងខិតខំស្ទូងស្រូវឲ្យបានខ្លាំងក្លានៅពេលពួកគេចុះមកពិនិត្យ"។ ខ្ញុំចង់បញ្ជាក់ថានៅក្នុងអត្ថបទនេះ អ្នកស្រីនិយាយអំពីស្ទូងស្រូវ មិនមែនការដឹកប្រឡាយទេ។ ដូច្នេះសូមអ្នកស្រីពន្យល់មើលថាតើមួយណាពិតប្រាកដ?

**ឆ៖** ខ្ញុំសូមបដិសេធ ថាស្ទូងស្រូវអត់មានទេ មានតែជីកប្រឡាយៗហ្នឹងបានជួបគាត់។ ស្ទូងស្រូវអត់មានគាត់ទេ ស្ទូងស្រូវមានតែកម្មាភិបាល តាមភូមិ តាមឃុំ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានផងដែរទេថា នៅពេលដែលមេកង មេភូមិរបស់អ្នកស្រីបានជម្រាបអ្នកស្រីពីការមកទស្សនកិច្ចរបស់មេដឹកនាំ ក្នុងសម័យខ្មែរក្រហម ដោយប្រើពាក្យថា "មេដឹកនាំ" មិនមែនជា "អង្គការ"? អ្នកស្រីអាចបញ្ជាក់ផងទេថា តើពាក្យណាជាពាក្យត្រឹមត្រូវដែលមេក្រុម ឬមេកង មេភូមិរបស់អ្នកស្រីបានប្រាប់អ្នកស្រីនៅពេលនោះ?

**ឆ៖** ពាក្យមេកង ខ្ញុំបានប្រាប់គឺថា អង្គការថ្នាក់លើ មេដឹកនាំថ្នាក់លើ ដើម្បីគេចុះមកពង្រឹងគោលជំហរ។ នេះជាការត្រឹមត្រូវ។

[១៥:១៧:៣០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អស់ពេលហើយ។

លោកស្រី ជូ គឹមឡន ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណង ជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតខាងរាងកាយ សម្ភារៈ ផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតឡើងពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ននេះ។ នេះប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

**លោក ជូ គឹមឡន៖**

ចាស ខ្ញុំ ជូ គឹមឡន សូមគោរព អង្គការ -- អង្គសវនាការ តុលាការជាទីគោរព!

គឺខ្ញុំនៅថ្ងៃ១៧ មេសា ១៩៧៥ បានកំពុងតែនៅក្នុងផ្ទះ កំពុងតែដាំបាយហូបពេលដែលកងទ័ព

រំដោះខ្មែរក្រហមគេចូលមក គេក្បួនដង្ហែជារថយន្ត គេបានដង្ហែគ្នាស្រែកជយោឃោស ទ្រហឹងអឺងកង ពេញរាជធានីភ្នំពេញ។ គេដាក់មីក្រូៗ ស្រែកប្រកាស ឲ្យប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញទាំងអស់ រៀបចំបង្វេច មួយបង្វេចៗម្នាក់ ដើម្បីនឹងចាកចេញពីទីក្រុងភ្នំពេញ ដាក់តែឆ្នាំងបាយ និងអង្ករសម្រាប់ហូបតាមផ្លូវ ៣ថ្ងៃ ឬយូរ ៥ថ្ងៃ។ របស់ដែលល្អៗ គឺអត់ឲ្យយកទៅទេ។ ដូច្នេះ ខ្ញុំក៏ដាំបាយហើយ ក៏មិនបានជាហូបដែរ លើកឆ្នាំងបាយលើកអី លើកអង្ករដែលនៅដីហ្នឹងបន្តិចដាក់យកមកនឹងចានបន្តិចបន្តួច យកមកហូបបាយតាមផ្លូវ។

[១៥:២០:០១]

ម្ដាយចាស់ជរា ឪពុកចាស់ជរា ក៏ធ្វើដំណើរមកជាមួយខ្ញុំទាំងអស់ហ្នឹង បងប្រុស បងថ្លៃ និងកូនតូចៗ មានម្នាក់ប្អូនៗ។ ធ្វើដំណើរមកនឹង ម្ដាយឪពុកខ្ញុំៗមានប្អូនប្រុសពីរទៀត មករៀបចេញមកហ្នឹង នឹកឃើញថាគេឲ្យទៅតែបីថ្ងៃ មិនបាច់យកអីទៅច្រើនទេ គឺរបស់ល្អៗគឺចាក់សោរទុកលើផ្ទះទាំងអស់។ ខ្ញុំចុះមកដោយបាតដៃទទេ និងខោអាវម្នាក់មួយស្បោង និងមុង កន្ទេល ប្រមូលដាក់សម្រាប់មកដេកតាមផ្លូវ។

ចេញមកបានបន្តិចឃើញពួកកងទ័ពគេតូចៗ ក្មេងតូចៗបើកឡានយ៉ាងលឿន គ្មានហ្រ្វាំង គ្មានជាន់ហ្វ្រាំងជាន់អីទេ បុកប្រជាជនឆ្វេកឆ្វាចស្លាប់ក្បែរថ្នល់ មានច្រើនកន្លែងដែលខ្ញុំដើរមក។ ភ័យរន្ធត់នឹកឃើញថា យ៉ាងណាទេ ដើរមកៗក៏ឈប់តាមក្រោមដើមឈើហូបបាយ ឈប់ហូបបាយដើរមកៗយូរណាស់ ព្រោះឪពុកខ្ញុំចាស់មានជំងឺលើសឈាម។ ដើរទម្រាំដល់ស្រុកត្រាំកក់។ ស្រុកត្រាំកក់ហ្នឹងអង្គតាសោមខាងលិចសាលាដើមចំបក់១ឧសភា មកដល់ហ្នឹងក៏២២ថ្ងៃ។ ដល់ហ្នឹងគឺអង្ករដាក់មក គឺកន្លះស្បោងគឺអស់ហើយ ដើរមកប្រមាណបីគ្រួសារ ហើយរយៈពេល២២ថ្ងៃ ដល់ពោធិ៍ព្រះសង់ហ្នឹងជាកន្លែងដែលស្នាក់លើកទី១ ហូប អត់អីហូបគេចែកពោត។ ចែកពោតហូបៗមិនបាន គឺមានការឈឺចុកចាប់គឺស្ដាយស្រណោះដែលគាត់ -- បដិវត្តន៍គេធ្វើដោយអត់មានបាយ អត់មានអង្ករចែកយើង អត់មានបាយបានអង្ករ គេធ្វើបដិវត្តន៍ដោយរបៀបណាទេ។

[១៥:២២:២១]

បន្តមកគេនៅដល់អង្គនរាយហ្នឹងភ្នំរលើងហ្នឹង ក៏បានប៉ុន្មានថ្ងៃក៏គេចងប្ដីទៅសម្លាប់ទៀតៗ។ គេក៏បញ្ជូនខ្ញុំចេញពីភូមិហ្នឹងទៀត ដោយសារគេឃើញមុខខ្ញុំចេះតែឃើញយំរាល់ថ្ងៃ ក៏គេបញ្ជូនខ្ញុំចេញពីហ្នឹងទៅនៅខាងត្បូងសាលាឃុំ។ ខាងត្បូងសាលាឃុំ ក៏ប្រសូតបានកូនប្រុសៗហើយក៏គេប្រើធ្វើទារុណ

កម្មដើម្បីឲ្យ -- គ្មាននឹកថាយើងជាកូនខ្ចី អត់មានពេទ្យ អត់មានថ្នាំ អត់មានអីទេ គឺថាគេឲ្យយើងទៅច្រូតបាន ២៧ថ្ងៃគេឲ្យខ្ញុំទៅច្រូត។ ដូច្នេះការឈឺចាប់ហ្នឹងវាមិនអាចបំភ្លេចបាន។ រហូតដល់យើងធ្វើច្រូតហើយ ដល់ច្រូតហើយគេឲ្យយើងកាយអាចម៍ៗលាយ។ ដល់ច្រូតហើយដល់ពេលគេប្រមូលឆ្នាំងបាយរួមហើយ គេប្រមូលឆ្នាំងបាយរួម គេឲ្យហូបរួម។ ហូបរួមហើយគេឲ្យយើងកាយ កាយលាមកហាលនៅជុំវិញសហករណ៍ ដែលយើងហូបបាយហ្នឹង គេធ្វើបង្គន់ជុំវិញហ្នឹង ហូបបាយហើយត្រូវទៅបង្គន់ហ្នឹងអត់ឲ្យចូលតាមផ្ទះទេ ហើយយើងកាយហាល ៗហើយយើងចិញ្ច្រាំសន្សំជី ខ្ញុំកូនខ្ចីគេឲ្យសន្សំជី ចិញ្ច្រាំទន្រ្ទានខែត្រ ហើយនិងកាយលាមកហ្នឹងទៅចាក់ក្នុងរណ្ដៅទន្រ្ទានខែត្រហ្នឹង ហើយពេញមួយរណ្ដៅៗគេលុប។ ដល់ខែស្ទូង គេឲ្យយើងរែកជីដាក់ស្រែស្ទូង មានការលំបាក ហើយយើងៗមានកើត -- ពេលខែស្ទូងហ្នឹង គេឲ្យយើងស្ទូងហ្នឹង ៗជើងយើងហ្នឹងកើតដំបៅយួន ឈឺ ហូរទឹក មានខ្ទុះហូរទឹកក៏យើងអត់មានថ្នាំដែរ យើងត្រូវតែតស៊ូ ត្រូវតែស្ទូង ស្ទូងទាំងឈឺទាំងជា។

បន្ទាប់មកទៀតក៏ខែស្ទូងៗអីចឹង ស្ទូងហើយអីចឹង គេឲ្យយើងទៅកាស់គល់ឈើនៅព្រៃលើ កាស់ឈើ កាស់ចម្ការ លើងព្រៃៗដាំដំឡូង។ ដាំដំឡូង យើងជាស្រី យើងកូនខ្ចី យើងទៅកាស់ព្រៃគល់ឈើដាំដំឡូងដាំគល់ឈើ ដាំដំឡូង ដាំសណ្ដែកដី ដាំអំពៅ មានគ្រប់ ផលគេមានគ្រប់មុខទាំងអស់។ ដើរឆ្លងកាត់តាមព្រៃលើ បានឃើញខ្មោចដែលគេកប់អត់ជិត ដែលមានធុំក្លិនស្អុយ មិនដឹងជាគេយកពីណាទៅវ៉ៃចោលក៏អត់ដឹងដែរ ឃើញស្អុយរលួយតែ -- ចាប់ពីយើងធ្វើការនៅលើងគល់ឈើហ្នឹងហើយយើងដល់ខែច្រូតទៀត យើងច្រូតៗធម្មតាទៅចុះ។ ចប់ពីច្រូត យើងជីកប្រឡាយ។ ការងារមានគ្រប់មុខសញ្ញាទាំងអស់ អត់ យើងអត់មានម៉ោងនាទីណាដែលយើងសម្រាកបានហើយ ថាចប់ពីការងារមានពេលសម្រាកមួយខែ ឬកន្លះខែ ១០ថ្ងៃ អត់ទេ។ ដកតាមមុខសញ្ញារហូតៗៗ។ តើការឈឺចាប់ហ្នឹង និងចុកចាប់ទាំងអស់នេះយើងខ្ញុំៗមិនអាចបំភ្លេចបានទេ។

ហើយជាបន្តបន្ទាប់ក៏មានឮសូរបងប្អូនកូនក្មួយដែលត្រូវគេសម្លាប់ បងដែលត្រូវរត់ទៅវៀត-ណាម ត្រូវគេចាប់សម្លាប់បានទៀត។ ក្មួយដែលដកដំឡូងគេហូបក៏ត្រូវគេសម្លាប់។ ជីដូនមួយគ្រាន់តែនិយាយ វាច្រឡំមាត់ និយាយថា “ម៉ាក់។ ទៅមើលម៉ាក ចង់សុំច្បាប់ពីកងយុវជនទៅមើលម៉ាកនៅភូមិ” គេថាយើងមិនជម្រុះជម្រះពីពុករលួយ ពីសក្តិភូមិ ក៏គេចាប់យកទៅរៀនសូត្រ។ មិនដឹងជារៀនសូត្រនៅណា បាត់រហូតដល់សព្វថ្ងៃ។ ឈ្មោះ ចន្ទី ជីដូនមួយខ្ញុំប្រុស។ ក្មួយជីដូនមួយ។

[១៥:២៦:៥៨]

តែការចុកចាប់ដែលខ្មែរ ៗជាតិខ្មែរសម្លាប់ខ្មែរដូចគ្នា តើគាត់ធ្វើបដិវត្តន៍យ៉ាងណា? តើបដិវត្តន៍គាត់ថាគាត់វាយរំដោះទីក្រុងភ្នំពេញ។ គាត់ធ្វើបដិវត្តន៍ឲ្យមានឋានៈស្មើគ្នា រំដោះពីនឹមចក្រពត្តិអាមេរិកាំង។ ចុះបើគាត់រំដោះ មូលហេតុអ្វីក៏គាត់ចាំបាច់មានកាប់សម្លាប់? បើរំដោះឲ្យបាយហូប ឲ្យមានព្រះពុទ្ធសាសនា ឲ្យមានសាលារៀន វប្បធម៌ ហ្នឹងជាការត្រឹមត្រូវ។ ចុះគាត់រំដោះៗរបៀបណា? រំដោះហេតុអ្វីក៏បង្អត់បាយ? ហេតុអ្វីក៏អត់មានសាលារៀន អត់មានរៀនព្រះពុទ្ធសាសនា អត់មានវត្តអារាម។ វត្តអារាមក្លាយជាទីឃុំឃាំងរបស់ជនស្លូតត្រង់ តើចំណុចនេះតើគាត់យល់យ៉ាងណា? និងអង្គតុលាការសូមវែកញែក។ ហើយចំណុចមួយទៀត ដែលគាត់មិនព្រមទទួលសារភាពថាគាត់បានប្រព្រឹត្ត និងគាត់មិនបានដឹងថាមានកាប់សម្លាប់។ តើមូលហេតុអីបានគាត់ពោលពាក្យមួយម៉ាត់ដូច្នេះ មួយឃ្លានេះ? គាត់អត់បានកាប់សម្លាប់ អត់បានដឹងគេកាប់សម្លាប់ប្រជាជនទេ។ កាប់សម្លាប់ប្រជាជនមិនមែនទើបតែកាប់សម្លាប់នៅពេលនេះទេ កាប់សម្លាប់រហូតដល់តែ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ តើមូលហេតុអីបានជាគាត់ឆ្លើយបដិសេធយ៉ាងដូច្នេះ? ខ្ញុំសូមឲ្យអង្គតុលាការជួយបំភ្លឺរឿងនេះ និងរកយុត្តិធម៌ ហើយនិងខូចខាតរបស់ទ្រព្យខ្ញុំដែលមានសេសសល់នៅភ្នំពេញ គឺផ្ទះបីខ្នងនិងដី ហើយនិងមានកូនឡានតូចមួយទៀត។ តើជារបស់ទ្រព្យដែលខំសន្សំរកស៊ីតាំងពីណាពីណី ហើយដល់យើងមកបាតដៃទទេយើងនៅអត់ៗ រហេមរហាមដល់សព្វថ្ងៃ។ តើសូមតុលាការវែកញែករកយុត្តិធម៌ ជួយបំភ្លឺ តើមូលហេតុអីបានគាត់ឆ្លើយពាក្យអស់ទាំងពីរឃ្លានេះ។ សូមអស់យោបល់។

[១៥:៣០:០០]

**ប្រធានអង្គជំនុំ៖**

ពាក្យពីរឃ្លាដែលលោកស្រីបាននិយាយជាចុងក្រោយនេះ ជាសំណួរសួរចំពោះជនជាប់ចោទ។ អ៊ីចឹងមែនទេ?

**លោកស្រី ជូ គីមឡុន៖**

ចាស ពិតប្រាកដ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ជូន គីមឡុន អង្គជំនុំជម្រះកត់សម្គាល់ថាសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៥ ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្តការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះទទួលបាននូវព័ត៌មានជាក់ច្បាស់ផ្សេងពី

ជនជាប់ចោទ ឬពីសហមេធាវីការពារក្តីរបស់ជនជាប់ចោទ។ ហើយអង្គជំនុំជម្រះក៏បានដាក់ភារកិច្ចឲ្យជនជាប់ចោទនិងមេធាវីការពារក្តីជនជាប់ចោទ ត្រូវទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព បើសិនជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ ដែលសួរដេញដោលដោយអង្គជំនុំជម្រះ ឬភាគីពាក់ព័ន្ធ។ តែរហូតដល់ពេលនេះអង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទ ពីការសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅជាការយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។ ដូច្នេះ គឺមិនមានឱកាសនៅក្នុងការតម្រូវឲ្យជនជាប់ចោទឆ្លើយតបនឹងសំណួររបស់លោកស្រីបានទេ ពីព្រោះគាត់បានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

[១៥:៣១:៤៥]

ឥឡូវនេះ អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី ជូ គឹមឡុន ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយរហូតដល់ពេលនេះការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីបានចប់ហើយ។ វត្តមានរបស់លោកស្រីនៅចំពោះមុខអង្គសវនាការនៅពេលនេះលែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ សូមលោកស្រីធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ ហើយមន្ត្រីតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅវិញចុះ។ អញ្ជើញគាត់ចាកចេញចុះ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម TCW-954 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:៣៦:០៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**សៈ** ព្រះតេជគុណ តើព្រះតេជគុណព្រះនាម អែម ភឿង អ៊ីចឹង ពិតមែនដែរទេ?

**ព្រះតេជគុណ អែម ភឿង៖**

**ផៈ** ចម្រើនពរ! អែម ភឿង។

**សៈ** ព្រះតេជគុណអាចប្រាប់ដល់អង្គសវនាការបានទេថា ព្រះតេជគុណប្រសូត្រនៅថ្ងៃខែឆ្នាំណា? កុំអាលៗទាន់ឆ្លើយតបព្រះតេជគុណចាំ -- រង់ចាំក្បាលមេក្រូហ្វូនឲ្យភ្លើងសញ្ញាក្រហមសិន ពណ៌ក្រហម ទើបក្បាលមេក្រូហ្វូនប្រតិបត្តិការ ទើបប្រព័ន្ធសំឡេងដែលព្រះតេជគុណឆ្លើយតបហ្នឹង គឺអាចចែកចាយដល់អ្នកដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ជាពិសេសដល់អ្នកបកប្រែភាសានៅខាងលើនោះដើម្បីបកប្រែចេញជាភាសាបារាំង និង ភាសាអង់គ្លេសទៀត។ ម្តងទៀត។

ថ្ងៃខែឆ្នាំកំណើតរបស់ព្រះតេជគុណៗកើតនៅថ្ងៃខែឆ្នាំណា?

**ផៈ** ខែ០១ ឆ្នាំ១៩៣៨។

**សៈ** ហើយសព្វថ្ងៃនេះ តើព្រះតេជគុណគង់នៅវត្តណា? មាននៅវត្តណា ហើយព្រះតេជគុណមានមុខងារអ្វីដែលនៅក្នុងវត្តនោះ? សូមព្រះតេជគុណ រំឭកម្តងទៀត ព្រះតេជគុណរង់ចាំក្បាលមីក្រូហ្វូនហ្នឹងឲ្យសញ្ញាភ្លើងក្រហមជាមុនសិន។ មានន័យថា ក្បាលមេក្រូហ្វូនហ្នឹងចាប់ផ្តើមប្រតិបត្តិការសឹមព្រះតេជគុណមានសង្ឃដីកា ឆ្លើយតបទៅនឹងសំណួរ បើពុំដូច្នេះទេ យើងស្តាប់អត់បានទេបាទ។

ព្រះតេជគុណគង់នៅវត្តណាបច្ចុប្បន្ននេះ ហើយមានឋានៈអ្វីដែរ?

**ផៈ** នៅវត្តជុំក្រៀល ខេត្តកំពត ឋានៈជាមេគុណខេត្ត។

**សៈ** ឪពុករបស់ព្រះតេជគុណគាត់ឈ្មោះអី? ឪពុករបស់ព្រះតេជគុណគាត់ឈ្មោះអី?

**ផៈ** អែម លៀម (ស្លាប់)។

**សៈ** ចុះម្តាយព្រះតេជគុណគាត់ឈ្មោះអី?

**ផៈ** ប៊ុន ឡេង (ស្លាប់)។

[១៥:៣៩:០២]

**សៈ** ព្រះតេជគុណ អែម ភឿង តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថាតាមសមត្ថភាពដែលព្រះតេជគុណអាចដឹង គឺថាព្រះតេជគុណមិនមានឪពុកម្តាយ បុព្វញាតិ កូនបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ត្រូវបានទទួលស្គាល់យកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី០០២នេះទេ។ តើជាការពិតដែរឬទេ?

01063023


ក្រឡាបញ្ជីបានរាយការណ៍ថា តាមសមត្ថភាពដែលព្រះតេជគុណអាចដឹងបាន គឺថាព្រះតេជ-គុណមិនមានឪពុកម្ដាយ បុព្វញាតិ កូន ឬបច្ឆា ញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ត្រូវបានទទួលស្គាល់យកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២នេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតមែន។

**ស៖** ហើយថាព្រះតេជគុណបានធ្វើសច្ចាប្រណិធានរួចហើយ មុននឹងចូលមកផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ តើពិតដែរឬទេ?

**ឆ៖** ធ្វើហើយៗពរ សម្បថហើយៗ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះសូមទូលព្រះតេជគុណអំពីសិទ្ធិនិងករណីយកិច្ចក្នុងនាមជាសាក្សីអំពីសិទ្ធិព្រះតេជគុណ អែម ភឿង ក្នុងនាមព្រះអង្គជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ ព្រះតេជគុណអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឱ្យព្រះតេជគុណធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[១៥:៤០:៥៨]

អំពីករណីយកិច្ច ព្រះតេជគុណ ក្នុងនាមព្រះតេជគុណជាសាក្សីត្រូវផ្ដល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ ព្រះតេជគុណត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះព្រះតេជគុណ លើកលែងតែសំណួរណាដែលចម្លើយតបព្រះតេជគុណ ឬការធ្វើអធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចអង្គជំនុំជម្រះបានជម្រាបជូនខាងលើអម្បាញ់មិញនេះ។ ហើយក្នុងនាមព្រះតេជគុណជាសាក្សីត្រូវតែឆ្លើយតែការណាដែលពិត ដែលព្រះតេជគុណបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬការធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រម នៃអង្គជំនុំជម្រះសួរព្រះតេជគុណ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សំណួរបន្ត ព្រះតេជគុណ អែម ភឿង តើព្រះតេជគុណដែលធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះ

វិសាមញ្ញៗក្នុងតុលាការកម្ពុជាដែរឬទេកន្លងមក? ហើយប្រសិនបើមាន តើធ្លាប់ធ្វើប៉ុន្មានដង? ហើយធ្វើនៅទីកន្លែងណា?

[១៥:៤២:១១]

**ព្រះតេជគុណ អែម ភឿង៖**

**ឆ៖** ពរ សម្ភាសនៅវត្តជុំក្រៀល កំពតតែម្តង។

**ស៖** ហើយព្រះតេជគុណ អែម ភឿង មុនពេលចូលមកកាន់ចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើព្រះតេជគុណបានពិនិត្យមើលអាន នូវកំណត់ហេតុដែលព្រះតេជគុណ បានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់ ព្រះតេជគុណដែរឬទេ?

**ឆ៖** ពរ បានអានមើលហើយ បានអានហើយ។

**ស៖** ហើយតាមសមត្ថភាពដែលព្រះតេជគុណអាចដឹង និងចងចាំ តើព្រះតេជគុណអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលព្រះតេជគុណបានអាន ដើម្បីរំឭកការចងចាំនោះពិតជាត្រឹមត្រូវ ឬវាសមស្របទៅនឹងចម្លើយដែលព្រះតេជគុណបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** សមស្របហើយ ពរ សមសម្របហើយ។

**ស៖** ព្រះតេជគុណ អែម ភឿង តាមព័ត៌មានដែលអង្គជំនុំជម្រះទទួលបានពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា ព្រះតេជគុណមិនអាចនិមន្តមកផ្តល់សក្ខីកម្មបានទេនៅថ្ងៃទី២៩ នៅថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ខានស្អែកនេះ។ តើពិតមែនដែរឬទេ? ឬក៏ព្រះតេជគុណអាចមកចូលរួមផ្តល់សក្ខីកម្មបាន?

**ឆ៖** ចំរើនពរ អាត្មាសូមចំរើនពរថា មិនបានមកទេ ព្រោះខែនេះរវល់ណាស់។ ហើយខេត្តក៏ត្រូវការទៀតខេត្ត ត្រូវការ --ស្អែកនេះខេត្តហៅទៀតហើយ ហៅទៅប្រជុំកិច្ចការសាសនា។

**ស៖** ហើយទំនងជាពេលណាដែលពេលវេលាសមស្រប ដែលព្រះតេជគុណអាចមកផ្តល់សក្ខីកម្មបាន ហើយតាមផែនការ គឺអង្គជំនុំជម្រះស្តាប់សក្ខីកម្មព្រះតេជគុណតែរយៈពេលមួយថ្ងៃទេ។ តើពេលណាដែលសមស្របដែលព្រះតេជគុណអាចនឹងមកផ្តល់សក្ខីកម្មបាន?

**ឆ៖** កំណត់មក កំណត់ថ្ងៃៗណាពរ? ខែណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹង ទុកឱ្យ ទុកលទ្ធភាពឱ្យខាងអង្គជំនុំជម្រះសាលាដំបូងហ្នឹង កំណត់កាលវេលាសមស្របនាពេលខាងមុខ សម្រាប់ព្រះតេជគុណវិញ លើកលែងតែថ្ងៃ២៩ ខានស្អែកនេះ ដែលមិនអាចនិមន្តមកផ្ដល់សក្ខីកម្មបាន។ អ៊ីចឹងដែរទេ?

**ឆ៖** ចម្រើនពរ ប៉ុន្តែកុំឱ្យប៉ះមាឃបូជាណ៎ា។

**ស៖** វគ្គណាទៅ ដែលៗថាពេលណាកុំឱ្យគួរចៀសវាងនោះ។ តើពេលវេលាណាទៅ? ព្រះអង្គអាចផ្ដល់ព័ត៌មានឱ្យយើងបានទេ?

**ឆ៖** មាឃបូជា ទី៣ ខែ២ ពរ។ កុំឱ្យប៉ះពរ។ បើក្រោយបាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៦:៤៩]

**ប្រធានអង្គជំនុំ៖**

បើមានស្ថានភាពដូច្នេះ ព្រះតេជគុណ អង្គជំនុំជម្រះនឹងពិភាក្សាជាមួយនឹងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរៃពេលវេលាសមស្របសម្រាប់និមន្តព្រះតេជគុណមកផ្ដល់សក្ខីកម្មសម្រាប់ករណីព្រះតេជគុណនាពេលខាងមុខ។

ឥឡូវនេះ ពេលវេលាសមស្របនឹងសម្រាកហើយ ហើយពេលវេលានៅតិចតួចដែរ ដូច្នេះអង្គជំនុំជម្រះមិនអាចដំណើរការសវនាការបានទេ អង្គជំនុំជម្រះលើកទៅបន្តធ្វើសវនាការនៅថ្ងៃខានស្អែក ថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០១៥ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបថា អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-834។

ហើយឥឡូវនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ។ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០១៥ ចាប់ផ្ដើមពីពេលម៉ោងប្រាំបួនព្រឹកទៅ។ ហើយមន្ត្រីរដ្ឋបាលតុលាការ និមន្តព្រះអង្គ អែម ភឿង សហការជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដំណើរព្រះអង្គវិលទៅខេត្តវិញចុះ។ ហើយឱ្យព្រះអង្គរង់ចាំការកោះអញ្ជើញសាជាថ្មីពីអង្គជំនុំជម្រះ។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញ នៅព្រឹកថ្ងៃខានស្អែកថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០១៥។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៤៨ នាទី)*